**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economic

# សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍទីក្រុងរណបកោះនរា

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ជាង ចាន់រឹទ្ធ**

លោក **បេង សុធារិទ្ធ**

ណែនាំដោយ

លោកគ្រូ **យស បានចំរុង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economic

**សារណាបញ្ចប់ការសិក្សា**

# ការអភិវឌ្ឍទីក្រុងរណបកោះនរា

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ជាង ចាន់រឹទ្ធ**

លោក **បេង សុធារិទ្ធ**

ណែនាំដោយ

លោកគ្រូ **យស ចានចំរុង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ឆ្នាំចូលសិក្សា ២០២០

ជំនាន់ទី ២៤

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ជាង ចាន់រឹទ្ធ** និងខ្ញុំបាទឈ្មោះ **មេង សុធារិទ្ធ** ដែលជានិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបាន សិក្សាចាប់ពីឆ្នាំ២០២០ រហូតមកដល់ឆ្នាំ២០២៤។

ខ្ញុំបាទទាំងពីររូបមានសេចក្តីសោមនស្សយ៉ាងកក់ក្តៅ ដោយមានឱកាសថ្លែងអំណរគុណដល់លោក ឪពុក **សួន ជិត** អ្នកម្តាយ **រ៉ឹន សារូ** និង លោកឪពុក **មេង ទុយ្សី** អ្នកម្តាយ **ឆេង ស្រីឆា** ដែលលោកជា អ្នកមានគុណយ៉ាងធំក្រៃលែង ចំពោះកូនដែលមានគុណតម្លៃមិនអាចកាត់ថ្លៃបាន ព្រោះថាលោកទាំងពីរជាអ្នក ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាកូនៗតាំងពីថ្ងៃដែលកូនបានចាប់កំណើតក្នុងផ្ទៃ រហូតដល់ថ្ងៃ ដែលកូនកើត ហើយនៅពេលកូនធំដឹងក្តីបន្តិចឡើង លោកទាំងពីរបានទូន្មាន ណែនាំ អប់រំ ប្រៀនប្រដៅ ដាស់តឿនកូនឱ្យក្លាយជាកូនល្អ ប្រព្រឹត្តតែអំពើល្អជាដើម លើសពីនេះទៅទៀតលោកទាំងពីរបានខិតខំទាំង ថ្ងៃ ក្តៅ ថ្ងៃរងាសព្វគ្រប់បែបយ៉ាង ដើម្បីបានថវិកាមកទំនុកបម្រុងការសិក្សារៀនសូត្ររបស់កូន ព្រមទាំងផ្តល់ការ ស្រឡាញ់ ការថ្នាក់ថ្នម ភាពកក់ក្តៅ និងការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរដល់កូនៗទាំងអស់គ្នាទាំងនេះ គឺ ជាមហាគុណដ៏ធំដែលកូនពុំអាចបំភ្លេចបានឡើយក្នុងឆាកជីវិតរបស់កូន។

ខ្ញុំបាទទាំងពីរ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបង្ហាត់ បង្រៀនដល់រូបយើងខ្ញុំ តាំងពីបឋមសិក្សា រហូតដល់បញ្ចប់វិទ្យាល័យ ប្រកបដោយជោគជ័យ។ ជាពិសេសសូម ថ្លែងអំណរគុណចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យគ្រប់រូបនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានយកចិត្តទុកដាក់ដោយមានទំនួលខុសត្រូវយ៉ាងខ្ពស់ចំពោះការសិក្សា របស់និស្សិតទាំងអស់ ដោយលោកពុំគិតពីបញ្ហាលំបាកនឿយហត់អ្វីឡើយ ដោយលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ គ្រប់រូបក៏តែងតែខិតខំប្រឹងប្រែងក្នុងការសិក្សាស្រាវជ្រាវរិះរកបកគំហើញថ្មីៗ បន្ថែមដើម្បីផ្ទេរនូវពុទ្ធិ និងបទ ពិសោធន៍ល្អៗដល់សិស្សនិស្សិតគ្រប់គ្នាផងដែរ។

ជាចុងបញ្ចប់ខ្ញុំបាទសូមជូនពរឱ្យលោកឪពុក និងអ្នកម្តាយ លោកតា លោកពូ អ្នកមីង និង **ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ** មិត្តនិស្សិត និងបុគ្គល ដែលបម្រើការងារនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ មានតែសុខភាពល្អ សម្រេចបានជោគជ័យគ្រប់ភារកិច្ច។

# **អារម្ភកថា**

ខ្ញុំបាទទាំងពីររូបជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២៤ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** បន្ទាប់ពីបានឆ្លងកាត់នូវការសិក្សា និងក្រេបយកចំណេះដឹងអស់រយៈពេល ៤ឆ្នាំ មកនេះខ្ញុំបានទាំងពីររូបទទួលនូវចំណេះជាច្រើនលើជំនាញនីតិសាស្ត្រ ជាពិសេសទៅលើវិស័យនគរូបនីយកម្ម និងសំណង់។ ដោយខ្ញុំបាទទាំងពីររូបបានព្យាយាម និងបានខិតខំអស់ពីកម្លាំងកាយចិត្តសម្រាប់នូវការរៀបចំកិច្ចការស្រាវជ្រាវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះឡើងមកគួបផ្សំដោយការប្រព្រឹត្តនៅក្រោមពាក្យណែនាំ និងបង្ហាត់បង្ហាញដោយផ្ទាល់ពីសំណាក់លោកគ្រូ **យស បានចំរុង** ដែលជាលោកគ្រូដឹកនាំ ដោយបានសម្រេចចិត្តជ្រើសរើសក្រោមប្រធានបទស្តីអំពី «**ការអភិវឌ្ឍទីក្រុងរណបកោះនរា**»។

ការសម្រេចចិត្តជ្រើសរើសយកប្រធានបទខាងលើ មកសិក្សាស្រាវជ្រាវជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ ដោយសារតែខ្ញុំបាទទាំងពីររូបយល់ឃើញថា ការរៀបចំទីក្រុងរណបវាពិតជាមានសារៈសំខាន់ណាស់ដើម្បីឱ្យទីក្រុងមួយមានរបៀបរៀបរយ ស្តង់ដានៃការរស់នៅទីក្រុងស្អាត សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសធ្វើឱ្យដីនៅតំបន់នោះមានសោភ័ណភាព រួមទាំងការអភិវឌ្ឍល្អប្រសើរថែមទៀតផង។

ខ្ញុំបាទទាំងពីររូបសង្ឃឹមថាសារណាមួយនេះនឹងក្លាយជាអត្ថបទដែលមានសារៈប្រយោជន៍សម្រាប់ មិត្តនិស្សិត បញ្ញាវន្ត ដែលមានបំណងចង់សិក្សាស្វែងយល់អំពីការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពទីក្រុងរណបណាមួយ។ ខ្ញុំបានទាំងពីររូបក៏សង្ឃឹមផងដែរថា សារណាបញ្ចប់ការសិក្សាមួយនេះនឹងក្លាយជាឯកសារមួយដែររួមចំណែក និងជម្រុញឱ្យមានការរៀបចំទីក្រុងរណបឱ្យកាន់តែមានឥទ្ធិពលជាងមុន។

ជាទីអវសាននេះ សូមជូនពរដល់ **ឯកឧត្តមសាកលវិទ្យាធិការ** សាស្ត្រចារ្យ លោកគ្រូ អ្នកគ្រូ និងមិត្តអ្នកអានគ្រប់រូបឱ្យជួបប្រទះតែភាពសុខដុមរម្យនា រុងរឿងថ្កុំថ្កើង និងមានសុភមង្គលជានិរន្តរាយ កុំបីឃ្លៀងឃ្លាតឡើយ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំបាទទាំងពីរជានិស្សិតដែលមានចំណេះដឹងនៅមានកម្រិត ខ្ញុំបាទទាំងពីរ សូមអោនលំទនសុំការអភ័យទោសផងដែរ ចំពោះការខ្វះខាតក្នុងការសិក្សាស្រាវជ្រាវនៅប្រធានបទមួយនេះ ខ្ញុំបាទទាំងពីរនឹងរងចាំដោយរីករាយសម្រាប់ទទួលការរិះគន់ដើម្បីស្ថាបនាពីសំណាក់ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងមិត្តអ្នកអានជាទីគោរពគ្រប់រីនាទី។

# មាតិកា


**សេចក្តីផ្តើម** ........................................ ១

## ជំពូកទី១

## សញ្ញាណទូទៅនៃការបង្កើតទីក្រុងរណបកោះនរា

**១.១. ស្ថានភាពទូទៅ** ........................................ ៥

១.១.១. គោលបំណង ........................................ ៦

១.១.២. ទីតាំងភូមិសាស្ត្រ ........................................ ៦

១.១.៣. ប្លង់គោល ........................................ ៧

១.១.៤. តំបន់ទេសចរណ៍ ........................................ ៨

១.១.៥. តំបន់សេដ្ឋកិច្ចឧស្សាហកម្ម ........................................ ៩

**១.២. កត្តាជម្រុញនាំឱ្យមានការរៀបចំទីក្រុងរណបកោះនរា** ........................................ ១១

១.២.១. កំណើនប្រជាជន ........................................ ១៣

១.២.២. ស្តង់ដានៃការរស់នៅ ........................................ ១៤

**១.៣. រចនាសម្ព័ន្ធគ្រប់គ្រងទីក្រុងរណបកោះនរា** ........................................ ១៥

១.៣.១. អន្តរក្រសួងពាក់ព័ន្ធ ........................................ ១៦

១.៣.២. តួនាទី និងភារកិច្ចរបស់អន្តរក្រសួង និងមន្ទីរដែលពាក់ព័ន្ធ ........................................ ១៦

## ជំពូកទី២

## ការរៀបចំផែនការអភិវឌ្ឍ និងការអនុវត្តទីក្រុងរណបកោះនរា

**២.១. នីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីធ្លី** ........................................ ៣០

២.១.១. នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ........................................ ៣៤

២.១.២. ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ........................................ ៣៩

**២.២. គម្រោងការអាទិភាពក្នុងការអនុវត្ត និងការអភិវឌ្ឍ** ........................................ ៤០

២.២.១. ការអនុវត្តប្រព័ន្ធដឹកជញ្ជូន និងអភិវឌ្ឍន៍វិស័យទីក្រុងរណបកោះនរា ........................................ ៤១

២.២.២. ការតម្រង់ទិសក្នុងការអនុវត្តទីក្រុងរណបកោះនរា ........................................ ៤២

២.២.៣. ចក្ខុវិស័យសម្រាប់ការអភិវឌ្ឍ ......................................................................................................៤៣

## ជំពូកទី៣

## គោលនយោបាយ និងសកម្មភាពអាទិភាពក្នុងការអភិវឌ្ឍទីក្រុងរណបកោះនរា

**៣.១. លិខិតអនុញ្ញាតសាងសង់** ..............................................................................................................៤៦

៣.១.១. យុទ្ធសាស្ត្រអភិវឌ្ឍន៍ ......................................................................................................................... ៤៨

៣.១.២. ការអភិវឌ្ឍលើវិស័យដីធ្លី .................................................................................................................. ៥០

៣.១.៣. ការអភិវឌ្ឍលំនៅឋាន ........................................................................................................................ ៥១

៣.១.៤. ការអភិវឌ្ឍលើវិស័យទឹកស្អាត...........................................................................................................៥២

៣.១.៥. ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ភ្ញៀវទេសចរណ៍ និងប្រជាជន ......................................................៥២

៣.១.៦. ការធ្វើឱ្យទីក្រុងរណបកាន់តែមាននិរន្តរភាពខាងបរិស្ថាន ....................................................................៥៣

**៣.២. ការធានាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម**..........................................................................................៥៤

**៣.៣. បញ្ហាប្រឈម និងដំណោះស្រាយ** ..............................................................................................................៥៥

**សេចក្តីសន្និដ្ឋាន**.............................................................................................................................................៥៨

**អនុសាសន៍**.....................................................................................................................................................៥៩

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ននេះ បានកែប្រែខ្លួនយ៉ាងឆាប់រហ័សក្នុងការអភិវឌ្ឍរាជធានី ក្រុង ស្រុក ខណ្ឌ ដែលធ្លាប់ឆ្លងកាត់នៅសង្គ្រាមស៊ីវិលដ៏ញាំញីជាច្រើនទសវត្សន៍កន្លងមក បានក្លាយខ្លួនជាប្រទេសដែលកំពុងតែមានការអភិវឌ្ឍ ក្រោមសន្តិភាព ស្ថេរភាព សណ្តាប់ធ្នាប់សន្តិសុខសង្គម ប្រជាធិបតេយ្យ ការគោរពនូវសិទ្ធិសេរីភាពជាពិសេស គឺការអភិវឌ្ឍទៅលើសក្តានុពលនៃកំណើនសេដ្ឋកិច្ចជាតិ ដោយកាត់បន្ថយភាពក្រីក្ររបស់ប្រជារាស្ត្រ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជាតាមចក្ខុវិស័យតាមយុទ្ធសាស្ត្រត្រីកោណ និងគោលនយោបាយឈ្នះៗរបស់**សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន**នឹងចក្ខុវិស័យយុទ្ធសាស្ត្របញ្ចកោណរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ដែលជាថ្នាក់ដឹកនាំអាណត្តិថ្មី នីតិកាលទី៧របស់ប្រទេសកម្ពុជា។ ដោយបានសហការរួបរួមបង្កើតឱ្យមានភាពរីកចម្រើនគ្រប់វិស័យ ដែលរួមផ្សំជាមួយហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដូចជា វិស័យគមនាគមន៍ អប់រំ សុខាភិបាល សាសនា វប្បធម៌ ទេសចរណ៍ ពាណិជ្ជកម្ម នគរូបនីយកម្ម និងសំណង់។ល។ ដែលកំពុងតែមានការអភិវឌ្ឍយ៉ាងមុតមាំនៅលើផ្ទៃដីនៃព្រះរាជាណាចក្រកម្ពុជា។ អ្វីដែលគួរឱ្យកត់សម្គាល់ទាំងថ្នាក់ដឹកនាំនៃអាណត្តិចាស់នឹងរាជរដ្ឋាភិបាលអាណត្តិថ្មី បានខិតខំប្រឹងប្រែងក្នុងការបំពេញតួនាទី និងភារកិច្ចក្នុងការអភិវឌ្ឍបន្ថែមទៀតទៅលើតំបន់ទីក្រុងរណបផ្សេងៗដែលស្ថិតនៅរាជធានីភ្នំពេញនឹងតាមបណ្តាខេត្តនានា ក្នុងគោលបំណងតែមួយ គឺបំពេញតម្រូវការរស់នៅរបស់ប្រជាជនឱ្យកាន់តែមានភាពល្អប្រសើរជាងមុន។

ជាក់ស្តែងរយៈពេលចុងក្រោយកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងសោភ័ណភាពរបស់ទីក្រុងភ្នំពេញដែលជាទីក្រុងគោល ទីក្រុងរណប និងតាមបណ្តាខេត្តនានា។ ក្នុងនោះផងដែរទីក្រុងរណបកោះនរា គឺជាទីក្រុងរណបមួយដែលកំពុងតែមានការអភិវឌ្ឍឱ្យមានសក្តានុពលគ្រប់វិស័យ ដោយផ្អែកសំខាន់ទៅលើសន្តិភាព សុខសុវត្ថិភាព សន្តិសុខសណ្តាប់ធ្នាប់ ព្រមទាំងតំបន់ទេសចរណ៍ អាគារពាណិជ្ជកម្ម តំបន់ឧស្សាហកម្មសម្រាប់ស្តង់ដានៃការរស់នៅរបស់ប្រជាពលរដ្ឋ។ ជាពិសេសត្រូវបានគេទទួលស្គាល់ថា ជាទីក្រុងរណបមួយដ៏កំពុងទាក់ទាញភ្ញៀវទេសចរណ៍ទាំងភ្ញៀវជាតិនឹងអន្តរជាតិឱ្យចូលមកទស្សនាកម្សាន្ត លំហែកាយ និងការបំពេញការងាររអាជីវកម្ម ក៏ដូចជាការធ្វើវិនិយោគទុននៅព្រះរាជាណាចក្រកម្ពុជា។ តួយ៉ាងវាជាផ្នែកមួយយ៉ាងសំខាន់ក្នុងចូលរួមចំណែកឱ្យប្រទេសជាតិមានការរីកចម្រើនផ្នែកសេដ្ឋកិច្ចកាន់ខ្លាំងក្លា ព្រមទាំងធ្វើការលើកម្ពស់គុណភាពនៃការរស់នៅ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ទីក្រុងរណបកោះនរា គឺជាទីក្រុងដែលកំពុងមានការអភិវឌ្ឍគ្រប់វិស័យមិនថាវិស័យសាធារណៈ ឬវិស័យឯកជននោះទេ គឺរាជរដ្ឋាភិបាលកម្ពុជាទាំងអាណត្តិចាស់នឹងអាណត្តិថ្មីបានយកចិត្តទុកដាក់នឹងការរៀបចំទីក្រុងរណបមួយនេះជាខ្លាំងដោយរួមមាន សោភ័ណភាព សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ជាពិសេស គឺគិតគូរទៅលើវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម នឹងទេសចរណ៍។ យ៉ាងណាមិញដើម្បីឱ្យកាន់តែមានភាពស៊ីជម្រៅទៅលើប្រធានបទសារណាខាងលើនេះ ខ្ញុំបាទទាំងពីររូបបានធ្វើការចោទសួរទៅលើចំណោទបញ្ហាដើម្បីធ្វើការបកស្រាយនៃបញ្ហាទាំងអស់នោះរួមមានៈ

១. តើមានកត្តាអ្វីខ្លះដែលជម្រុញឱ្យមានការរៀបចំអនុវត្ត និងការអភិវឌ្ឍទីក្រុងរណបកោះនរា?

២. តើមាននីតិវិធីលម្អិត និងការតម្រង់ទិសអ្វីខ្លះក្នុងការរៀបចំផែនការប្រើប្រាស់ដីនៃទីក្រុងរណប?

៣. តើមានគោលនយោបាយ និងយុទ្ធសាស្ត្រអាទិភាពអ្វីខ្លះ ក្នុងការអភិវឌ្ឍទីក្រុងរណប? តើមានបញ្ហាប្រឈម និងដំណោះស្រាយអ្វីខ្លះ?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

គោលបំណងក្នុងការកំណត់យកនូវប្រធានបទដែលទាក់ទងជាមួយនឹងនីតិនគរូបនីយកម្ម និងសំណង់ដែលស្តីអំពី «**ការអភិវឌ្ឍទីក្រុងរណបកោះនរា**» យកមកសរសេរជាប្រធានបទសម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ គឺចង់ឆ្លុះបញ្ចាំងបង្ហាញអំពីសមិទ្ធផល ដែលបានយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍកន្លងមកនេះ ព្រមទាំងបានអនុវត្តតាមគោលនយោបាយឈ្នះឈ្នះ យុទ្ធសាស្ត្រត្រីកោណនឹងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានបង្ហាញអំពីសក្តានុពលខ្ពស់របស់ទីក្រុងរណបកោះនរា ហើយក៏ជាតំបន់សេដ្ឋកិច្ចមួយយ៉ាងសំខាន់សម្រាប់កំណើនសេដ្ឋកិច្ចជាតិ។

លើសពីនេះទៅទៀតខ្ញុំទាំងពីររូប មានគោលបំណងរួមគ្នាតែមួយ គឺបង្កើតស្នាដៃក្នុងការស្រាវជ្រាវទៅលើប្រធានបទសារណាមួយនេះ ដើម្បីជម្រុញឱ្យប្រទេសកម្ពុជាឆ្ពោះទៅរកភាពរីកចម្រើនលូតលាស់គ្រប់វិស័យមិនថាវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម គមនាគមន៍ ទេសចរណ៍ ព្រមទាំងគុណភាពក្នុងការរស់នៅក្រោមម្លប់សន្តិភាព។ល។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវរបស់ប្រធានបទនីមួយៗ គឺសុទ្ធសឹងតែបង្កប់នូវគោលគំនិត គោលបំណង គោលដៅ និងខ្លឹមសារសំខាន់ៗនៅក្នុងកិច្ចការស្រាវជ្រាវផ្សេងៗពីគ្នា។ យ៉ាងណាមិញការស្រាវជ្រាវដែលពាក់ព័ន្ធនឹងការអភិវឌ្ឍទីក្រុងរណបកោះនរា ខ្ញុំបាទទាំងពីររូបបចង់បង្ហាញពី ទិដ្ឋភាពនានាក្នុងការអភិវឌ្ឍទីក្រុងរណបកោះនរាក៏ដូចជាបណ្ដាទីក្រុងរណបផ្សេងៗ ដែលចង់ឃើញពីការជម្រុញនូវការអភិវឌ្ឍ និងកាលានុវត្តភាព ដែលជាវិធានការក្នុងដោះស្រាយរបស់អ្នកឧកញ៉ា **ពុង ឃាវសែ** ជាអគ្គនាយកក្រុមហ៊ុន OCIC ជាពិសេសទៅតាមចក្ខុវិស័យឆ្នាំ២០៣៥។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើអត្ថបទសារណាមួយនេះ វាពិតជាមានសារសំខាន់ និងមានសារប្រយោជន៍ចំពោះសិក្សានុសិស្ស និងមិត្តនិស្សិតគ្រប់ជំនាន់ អ្នកស្រាវជ្រាវ អ្នកអាន និងសាធារណជនគ្រប់រូបទាំងអស់ឱ្យយល់ដឹងកាន់តែច្បាស់ និងមានភាពស៊ីជម្រៅ នៃផែនការ យុទ្ធសាស្ត្រ គោលនយោបាយក្នុងការអភិវឌ្ឍទីក្រុងរណប និងនីតិវិធីលម្អិតនៃប្លង់គោលប្រើប្រាស់ដី។ លើសពីនេះទៅទៀតអត្ថបទសារណាមួយនេះ ក៏បានរំលេចឡើងឱ្យឃើញផងដែរ អំពីបញ្ហាប្រឈម និងដំណោះស្រាយរបស់អ្នកឧកញ៉ា **ពុង ឃាវសែ** និងអន្តរក្រសួងដែលពាក់ព័ន្ធ ព្រមទាំងរាល់វិធានការអនុវត្តផ្សេងៗឱ្យមានប្រសិទ្ធភាពក្នុងការរស់នៅ ប្រកបអាជីវកម្មរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នោះ ជាពិសេសចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបង្ហាញនូវការជម្រុញឱ្យមានភាពអភិវឌ្ឍន៍ឱ្យមានប្រសិទ្ធភាព និងចីរភាព។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

យោងតាមប្រធានបទខាងលើនេះជាប្រធានបទមួយដែលមានសារសំខាន់ ដែលជាមូលហេតុដែលឱ្យខ្ញុំបាទទាំងពីររូបខិតខំស្វែងរកឯកសារដែលពាក់ព័ន្ធទៅ និងប្រធានបទសារណាតាមរយៈបណ្ណាល័យនីតិសាស្ត្រនៃ សាកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងតាមរយៈព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច សេចក្ដីប្រកាស សារាចរណែនាំរបស់រាជរដ្ឋាភិបាល ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងការស្វែងរកឯកសារតាមរយៈប្រព័ន្ធអ៊ីនធឺណែត។ បន្ថែមពីលើនេះ ខ្ញុំបាទទាំងពីររូបបានខិតខំចុះទៅស្វែងរកឯកសារទៅតាមក្រសួង និងមន្ទីរដែលពាក់ព័ន្ធ ដើម្បីប្រមូលឯកសារផ្សេងៗយកមកវិភាគឱ្យកាន់តែស៊ីជម្រៅ និងកាន់តែលម្អិត ក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់ខ្ញុំបាទទាំងពីរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សារបស់ ខ្ញុំបាទទាំងពីររូប បានបែងចែកចេញជា ៣ជំពូកធំៗរួមមាន៖

- **ជំពូកទី១ សញ្ញាណទូទៅនៃការបង្កើតទីក្រុងរណបកោះនរា** ជារួមនៅក្នុងជំពូកទី១ នេះផងដែរ ខ្ញុំបាទទាំងពីរផ្តោតសំខាន់ទៅលើ ៣ចំណុចធំៗ ដែលទាក់ទងអំពីទីតាំងភូមិសាស្ត្រ កត្តាជម្រុញនាំឱ្យមានការរៀបចំទីក្រុងរណបកោះនរា ព្រមទាំងរចនាសម្ព័ន្ធគ្រប់គ្រងទីក្រុងរណប កោះនរា។
- **ជំពូកទី២ ការរៀបចំផែនការអភិវឌ្ឍ និងការអនុវត្តទីក្រុងរណបកោះនរា** ចំពោះជំពូកទី២ ខ្ញុំបាទទាំងពីរបានបែងចែកជា ៣ចំណុច ដែលចង់បង្ហាញអំពី នីតិវិធីលម្អិតនៃការ រៀបចំប្លង់គោលប្រើប្រាស់ដី ការតម្រង់ទិសក្នុងការអនុវត្តទីក្រុងរណបកោះនរា និងការអនុវត្ត សកម្មភាពតាមវិស័យ។
- **ជំពូកទី៣ គោលនយោបាយ និងសកម្មភាពអាទិភាពក្នុងការអភិវឌ្ឍទីក្រុងរណបកោះនរា** ចំណែកឯជំពូកទី៣ ខ្ញុំបាទទាំងពីរក៏បានបែងចែកជា ៣ចំណុចផងដែរ ដើម្បី យល់ដឹងអំពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ជាពិសេសចំណុច ចុងក្រោយ គឺចង់បង្ហាញអំពីបញ្ហាប្រឈម និងដំណោះស្រាយ។

# ជំពូកទី១
# សញ្ញាណទូទៅនៃការបង្កើត
# ទីក្រុងរណបកោះនរា

# ជំពូកទី១

# សញ្ញាណទូទៅនៃការបង្កើតទីក្រុងរណបកោះនរា

## ១.១. ស្ថានភាពទូទៅ

ទីក្រុងរណបត្រូវបានគេហៅឈ្មោះនេះពីមាត់មួយទៅមាត់មួយ នៅក្នុងគម្រោងអភិវឌ្ឍន៍អចលនទ្រព្យនានា ជាពិសេសគឺនៅក្នុងគម្រោងពុះដីឡូតិ៍លក់តែម្តងសម្រាប់ចង្អុលបង្ហាញថា តំបន់មួយនោះ គឺជាតំបន់ដែលមានសក្តានុពលខ្ពស់នឹងមានការអភិវឌ្ឍន៍ច្រើននៅថ្ងៃខាងមុខ។ ជាការពិតការបង្កើតទីក្រុងរណប គឺជាតំបន់ដែលមានការអភិវឌ្ឍខ្លាំងបំផុតបន្ទាប់ពីក្រុងគោល ហើយក៏នៅមិនឆ្ងាយពីទីក្រុងគោលប៉ុន្មានដែរនឹងជាតំបន់អភិវឌ្ឍន៍ទៅលើគម្រោងធំៗបន្ទាប់ពីទីក្រុង បើនិយាយឱ្យខ្លីទៅទីក្រុងរណប គឺជាតំបន់មួយអភិវឌ្ឍន៍ក្លាយទៅជាទីក្រុងមួយថ្មីទៀត ដែលអាចរស់នៅ ធ្វើការ និងកម្សាន្តបានយ៉ាងសម្បូរបែប ដោយមិនពឹងផ្អែកលើទីក្រុងគោលក៏បានដែរ។ ទីក្រុងរណប ប្រសិនបើយើងហៅតាមភាសាអង់គ្លេស គឺSatellite City ឬ Satellite Towns គឺជាតំបន់អភិវឌ្ឍន៍ស្នូលរបស់ទីក្រុងមួយ។ **ឧទាហរណ៍**ជាក់ស្តែង ការបង្កើតទីក្រុងរណបកោះនរា ដែលកំពុងធ្វើការអភិវឌ្ឍយ៉ាងខ្លាំងនឹងទទួលបានការវិនិយោគជាច្រើន ហើយស្ថិតនៅក្នុងទីក្រុងភ្នំពេញដែលជាទីក្រុងគោលចំណែកឯកោះនរា គឺជាទីក្រុងរណប។

នៅក្នុងទីក្រុងភ្នំពេញ យើងឃើញថាមានទីក្រុងរណបជាច្រើនកន្លែង ដែលកំពុងធ្វើការពង្រីកខ្លួន និងឈានទៅរកការអភិវឌ្ឍស្របតាមគោលនយោបាយ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ដែលជួយពង្រឹងក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធទីក្រុងរណប ឱ្យមានភាពលេចធ្លោ ទាក់ទាញដល់បណ្តាវិនិយោគិន ទូទាំងសកលលោកនាំគ្នាមកបណ្តាក់ទុននៅព្រះរាជាណាចក្រកម្ពុជា។ ជាក់ស្តែងទីក្រុងរណប ក៏ជាទីក្រុងមួយ បន្ទាប់បន្សំទីក្រុងគោល ដែលជួយសម្រួលដល់ទីក្រុងគោលបានមួយចំណែកផងដែរ ពាក់ព័ន្ធទៅនឹងការរស់នៅប្រកបដោយផាសុភាព សុខុដុមរមនាប្រកបសោយសេចក្តីថ្លៃថ្នូរ និងសុខសុវត្ថិភាពជាដើម។

ដែលយើងអាចមើលឃើញថា ការបង្កើតតំបន់ទីក្រុងរណបកោះនរានេះ គឺកំពុងតែមានការរីកចម្រើនផ្នែកឧស្សាហកម្ម និងពាណិជ្ជកម្មជាច្រើនទៀត ដែលអាចរស់នៅផ្តាច់ពីទីក្រុងគោលបានពីព្រោះ មានចរន្តសេដ្ឋកិច្ចផ្ទាល់ខ្លួន ដោយប្រជាជនមិនត្រូវការមកធ្វើការនៅទីក្រុងគោលឡើយ។ យើងអាចសម្គាល់គម្រោងអភិវឌ្ឍន៍ទីក្រុងរណបបានដោយ ជំហានដំបូងមើលទៅលើគម្រោងអភិវឌ្ឍន៍ផ្លូវ ជាពិសេស គឺផ្លូវក្រវាត់ក្រុង

តំបន់ផ្លូវកាត់ពីផ្លូវមួយទៅផ្លូវមួយ និងការអភិវឌ្ឍទៅលើគម្រោងធំៗដូចជា ឧស្សាហកម្ម ពាណិជ្ជកម្ម គម្រោងលំនៅដ្ឋាន ធនាគារ ផ្សារទំនើប សាលារៀន មណ្ឌលសុខភាព។ល។ [1]

### ១.១.១. គោលបំណង

ការបង្កើតទីក្រុងរណប គឺជួយជម្រុញដល់ការរីចម្រើននៅក្នុងប្រទេសជាតិជាខ្លាំងជាពិសេសនៅក្នុងទីក្រុងភ្នំពេញ ដោយគម្រោងទាំងនេះមានចំណុចល្អច្រើនស្ទើរតែទាំងអស់ ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធដែលបានចូលរួមអភិវឌ្ឍន៍ជាមួយរាជរដ្ឋាភិបាលបានមួយផ្នែកធំ ការចូលរួមលើកកម្ពស់នៅក្នុងវិស័យនគរូបនីយកម្ម និងសំណង់ និងអចលនទ្រព្យ ក៏ដូចជាការរួមចំណែកទៅលើផ្នែកបច្ចេកវិទ្យានៃសំណង់សម័យថ្មីផងដែរ។

គម្រោងទីក្រុងរណបត្រូវបានគាំទ្រដោយរាជរដ្ឋាភិបាល ដើម្បីកាត់បន្ថយនៅភាពកកកុញ នៃចំនួនមនុស្សដែលរស់នៅផ្តុំគ្នា ដោយគម្រោងអភិវឌ្ឍន៍ទីក្រុងរណបនីមួយៗបានធ្វើឡើងដើម្បីបង្កើនភាពទាក់ទាញ និងចាប់អារម្មណ៍ឱ្យមានមនុស្សចូលទៅរស់នៅកាន់តែច្រើន ក្រៅពីមានលក្ខណៈប្រសើរនៃហេដ្ឋរចនាសម្ព័ន្ធ ក៏មានផាសុខភាពខ្ពស់ក្នុងការរស់នៅជាមួយធម្មជាតិ។ អ្នកជំនាញបានលើកឡើងថា ការដែលរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចចិត្តបង្កើតឱ្យមានការអភិវឌ្ឍទីក្រុងរណប នៅជុំវិញរាជធានីភ្នំពេញនេះឡើង គឺជាជំនួយដ៏ល្អប្រសើរបំផុត ដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍នៅកណ្តាលរាជធានីភ្នំពេញ។

នៅពេលដែលមានការបែងចែក តំបន់ក្រុងផ្សេងគ្នាកាន់តែច្រើនវានឹងចូលរួមសម្រួលដល់សង្គមកាន់តែច្រើន ដោយសារតែនៅក្នុងទីក្រុងរណប ភាគច្រើនសុទ្ធតែបានបង្កើតជាតំបន់ពាណិជ្ជកម្មទាំងអស់ ដែលអ្នករស់នៅអាចធ្វើការបង្វែរគោលដៅទីតាំងអាជីវកម្ម ក៏ដូចជាកន្លែងធ្វើការជាដើម។ ព្រោះគ្រប់គម្រោងទីក្រុងរណបក្តាប់មូលហេតុធំៗដើម្បីបញ្ចៀសបញ្ហាប្រឈមនៅថ្ងៃអនាគត ក្រុមហ៊ុនអភិវឌ្ឍន៍ ត្រូវតែមានផែនការមេឱ្យបានច្បាស់លាស់ ទាំងការអភិវឌ្ឍនៅពេលបច្ចុប្បន្ន ក៏ដូចជាបន្តទៅថ្ងៃអនាគតក្នុងរយៈពេលវែង ដែលក្រៅពីគិតទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធ ត្រូវគិតទៅលើការបង្កើតនឹងថែរក្សាតំបន់បៃតងឱ្យបានច្រើនដែលជាចំណែកមួយដ៏សំខាន់ក្នុងការរស់នៅ។ [2]

### ១.១.២. ទីតាំងភូមិសាស្ត្រ

ទីក្រុងរណបកោះនរា មានទីតាំងស្ថិតនៅខាងកើតទីក្រុងកោះពេជ្រ សង្កាត់និរោធ ខណ្ឌច្បារអំពៅ នៅលើផ្លូវជាតិលេខ១ រាជធានីភ្នំពេញ កំពុងក្លាយជាទីកន្លែងលំហែកាយដ៏ពេញនិយមសម្រាប់ប្រជាពលរដ្ឋកម្ពុជា

[1] ដកស្រង់ចេញពី គេហទំព័រ https://propertyarea.asia ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣។

[2] ដកស្រង់ចេញពី គេហទំព័រ https://Cambodiapropertyreport.com ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣។

ជាពិសេសផ្លូវប្រវែង ៤គីឡូម៉ែត្រជាប់ទៅនឹងដងទន្លេមេគង្គពោរពេញទៅដោយទេសភាពដ៏ស្រស់បំព្រងនឹងល្អឯកនៃទីក្រុងភ្នំពេញ ដែលស្ថិតនៅលើផ្ទៃដីអភិវឌ្ឍន៍ទំហំ ១២៥ហិកតា និងផ្ទុកមនុស្សបាន ៥ម៉ឺននាក់។ ទីតាំងភូមិសាស្ត្រនេះទៀតសោត ជាអតីតកោះចារដែលបានបាក់ចូលទន្លេកន្លងទសវត្សមកនេះ។[3]

### ១.១.៣. ប្លង់គោល

ជាការពិតណាស់មុននឹងបង្កើតបានជាទីក្រុងរណបកោះនរា ឬទីក្រុងរណបផ្សេងទៀតបានគប្បីយល់ដឹងអំពីប្លង់គោលប្រើប្រាស់ដី។ ប្លង់គោលប្រើប្រាស់ដី គឺជាប្លង់ ឬផែនទីដែលកើតចេញពីការគិតគូរ និងរៀបចំផែនការទុកជាមុន សម្រាប់បំពេញតម្រូវការនៃការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីទៅតាមដំណាក់កាលនីមួយៗនៃការអភិវឌ្ឍរបស់សង្គមណាមួយ។ គ្រប់ផ្នែក គ្រប់វិស័យនៃរាល់សម័យកាលសង្គមសុទ្ធតែត្រូវការដីធ្លីដើម្បីទ្រទ្រង់ជីវិត និងធ្វើការអភិវឌ្ឍជាបន្តបន្ទាប់។ រហូតមកដល់ពេលនេះស្ទើរតែគ្រប់ប្រទេសទាំងអស់នៅលើពិភពលោកបាននិងកំពុងរៀបចំ និងអភិវឌ្ឍន៍ប្លង់គោលប្រើប្រាស់ដីរបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួន ដោយចាត់ទុកជាត្រីវិស័យគ្រឹះសម្រាប់តម្រង់ទិស នៃការអភិវឌ្ឍឱ្យបានសមស្រប និងប្រកបដោយចីរភាព។[4]

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានការរៀបចំប្លង់គោលប្រើប្រាស់ដីធ្លីនឹងពង្រាងផែនការហេដ្ឋារចនាសម្ព័ន្ធសាធារណៈនៅតាមរាជធានីក្រុងសំខាន់ៗរួចទៅហើយ ដែលនេះដើម្បីអាចធានាដល់ការអភិវឌ្ឍមូលដ្ឋានប្រកបដោយចីរភាព។ ប្លង់គោល ឬប្លង់គោលប្រើប្រាស់ដី Master Plan គឺជាផែនកំណត់អំពីចក្ខុវិស័យ និងយុទ្ធសាស្ត្ររួមសម្រាប់ការអភិវឌ្ឍរូបវន្ត និងកំណត់អំពីប្រភេទប្រើប្រាស់ដី ព្រមទាំងបង្ហាញអំពីទម្រង់ទីក្រុងបណ្តាញហេដ្ឋារចនាសម្ព័ន្ធទីក្រុង គមនាគមន៍សំខាន់ៗនៃទីក្រុង និងការធ្វើសមាហរណកម្ម។ ប្លង់គោលត្រូវភ្ជាប់មកជាមួយនូវគម្រោងអភិវឌ្ឍន៍ទីក្រុង តាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី មធ្យម និងរយៈពេលវែង។ ប្លង់ប្រើប្រាស់ដីធ្លី Land Use Plan ជាផែនការលម្អិតចេញពីប្លង់គោល កំណត់អំពីប្រភេទដី និងតំបន់នៃការប្រើប្រាស់ដីនីមួយៗកំណត់អំពីបទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍ ការអភិរក្ស និងបទប្បញ្ញត្តិក្នុងការសាងសង់តំបន់នីមួយៗព្រមទាំងកំណត់អំពីបណ្តាញគមនាគមន៍ និងការធ្វើសមាហរណកម្ម។[5]

ជាក់ស្តែង រាជរដ្ឋាភិបាលបានរៀបចំប្លង់គោលប្រើប្រាស់ដីនៅរាជធានីភ្នំពេញ ក្នុងខណ្ឌច្បារអំពៅ តាមចក្ខុវិស័យឆ្នាំ២០៣៥ ដោយរដ្ឋាភិបាលកម្ពុជា គឺជាអ្នកគាំពារ និងធានាខុសត្រូវលើការគ្រប់គ្រងការអភិវឌ្ឍ និងការអនុវត្តច្បាប់ដោយតម្លាភាពនៅក្នុងសង្គមជាតិ ដោយគិតដល់តម្រូវការកំណើនសេដ្ឋកិច្ច និងអភិវឌ្ឍន៍ចីរភាព

[3] ដកស្រង់ចេញពី គេហទំព័រ https://Cambodiapropertyreport.com ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣។

[4] ដកស្រង់ចេញពី ស្លាយមេរៀន នីតិរៀបចំដែនដី និងនគរូបនីយកម្មរបស់ បណ្ឌិត ជា សៀវម៉ី ឆ្នាំ២០២៣។

[5] សេចក្តីព្រាងអនុក្រឹតស្តីពី នគរូបនីយកម្ម រាជធានីក្រុង និងទីប្រជុំជន។

ចាំបាច់ត្រូវតែមានការរៀបចំផែនការទុកមុនឱ្យបានល្អ ដើម្បីធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព។ ការរៀបចំផែនការដីធ្លីសមស្របនូវគ្រប់កម្រិត ចាំបាច់ត្រូវតែមានការគិតគូរនឹងសិក្សាកសាងឱ្យមានលក្ខណៈស៊ីចង្វាក់ជាមួយប្រទេសនៅក្នុងតំបន់ និងនៅលើពិភពលោកផងដែរ។ ទោះជាយ៉ាងណា នៅក្នុងកិច្ចការបច្ចេកទេស គេអាចកសាងផែនការដីធ្លីទ្វេទិសបាន គឺរៀបចំពីកម្រិតថ្នាក់ក្រោមឡើងទៅលើ ឬពីលើចុះក្រោមជាមូលដ្ឋានលម្អិតច្បាស់លាស់ សម្រាប់កែតម្រូវផែនការថ្នាក់លើឱ្យបានសមស្របតាម ស្ថានភាពជាក់ស្តែងនឹងតម្រូវការរបស់សង្គម។ [6]

### ១.១.៤. តំបន់ទេសចរណ៍

ក្នុងរយៈពេលចុងក្រោយនេះ បន្ទាប់ពីបានដាក់ឱ្យដំណើរការនូវស្ពានកោះពេជ្រទៅទីក្រុងរណបកោះនរា និងការរៀបចំហេដ្ឋារចនាសម្ព័ន្ធមួយចំនួន នៅក្នុងតំបន់ទីក្រុងរណបកោះនរានោះរួចរាល់មក គេសង្កេតឃើញថា ទីក្រុងរណបកោះនរា គឺជាកន្លែងទេសចរណ៍មួយដែលមានភាពទាក់ទាញដល់ប្រជាពលរដ្ឋ ជាពិសេសយុវជនយុវនារីជាច្រើនបានចាប់អារម្មណ៍នាំគ្នាទៅដើរលេងកំសាន្តនឹងលំហែអារម្មណ៍ នៅឧទ្យាននរាដែលយើងហៅកាត់ថា Norea Parkway។ ដោយឧទ្យាននរានេះ គឺជាទិសដៅទេសចរណ៍មួយដ៏សំខាន់នៅក្នុងទីក្រុងរណបកោះនរាក៏ដូចជានៅរាជធានីភ្នំពេញ បន្ទាប់ពីទីក្រុងកោះពេជ្រ។[7]

ទីក្រុងរណបកោះនរាជាតំបន់ទេសចរណ៍មួយដែលកំពុងមានសក្តានុពលទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិជាខ្លាំងក្នុងការមកលេងកម្សាន្ត ពីព្រោះទីក្រុងរណបកោះនរាមិនត្រឹមតែមានឧទ្យាននរាប៉ុណ្ណោះទេ ក៏ប៉ុន្តែទីក្រុងរណបមួយនេះក៏បានបន្ថែមកន្លែងទេសចរណ៍មួយទៀត ដែលកំពុងតែទាក់ទាញខ្លាំងបន្ទាប់ពីឧទ្យាននរានោះ គឺកាហ្វេប្រោន (Coffee Brown) ដែលជាហាងកាហ្វេទំនើបមួយកន្លែងនេះកំពុងមានវត្តមានលើតំបន់ទីក្រុងរណបកោះនរា និងកំពុងតែមានការទាក់ចិត្តទាក់ភ្នែក ទាក់អារម្មណ៍អ្នកដែលបានឃើញឱ្យជ្រួលច្របល់ក្នុងការមកគយគន់ទេសភាពមាត់ទន្លេ ស្រូបយកខ្យល់អាកាសបរិសុទ្ធពីតំបន់នោះផងដែរ។[8]

លើសពីនេះទៅទៀតតំបន់ទីក្រុងរណបមួយនេះ ក៏បានបង្កើតនៅផ្សាររាត្រីមួយដែលមានឈ្មោះថា Khmer Streat ដែលនៅទល់មុខកាហ្វេប្រោន ហើយវាក៏ជាកន្លែងសម្រាប់ញ៉ាំអាហារឆ្ងាញ់ៗនឹងការដើរទិញ

[6] ដកស្រង់ចេញពី យុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលនីតិកាលទី៦។

[7] ដកស្រង់ចេញពី គេហទំព័រ https://Kampucheathmey.com ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣។

[8] ដកស្រង់ចេញពី គេហទំព័រ https://Infotainment.ams.com.kh ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣។

ទំនិញ បានទាំងទេសភាពបរិយាកាស ទាំងខ្យល់ធ្វើឱ្យបាត់ភាពតានតឹងដល់អ្នកដែលកំពុងសិក្សានឹងអ្នកកំពុងប្រកបការងារ។[9]

### ១.១.៥. តំបន់សេដ្ឋកិច្ចឧស្សាហកម្ម

ទីក្រុងរណបកោះនរា ស្ថិតនៅតាមដងទន្លេមេគង្គដែលជាកោះមួយស្ថិតនៅចំណុចកណ្តាលនៃទីក្រុងរណបកោះពេជ្រ និងខណ្ឌច្បារអំពៅនៃរាជធានីភ្នំពេញ។ គម្រោងអភិវឌ្ឍតំបន់សេដ្ឋកិច្ចឧស្សាហកម្មទីក្រុងរណបកោះនរាមួយនេះ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់សិទ្ធិឱ្យទៅក្រុមហ៊ុន Overseas Cambodia investment Corp Ltd (OCIC) របស់អ្នកឧកញ៉ា **ពង់ ឃាវសែ** ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចយ៉ាងច្រើនតាមរយៈការវិនិយោគ។

កោះនរា និងក្លាយជាទីក្រុងរណបមួយ ដែលជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ទេសចរណ៍ ដ៏ទាក់ទាញបំផុតនៅក្នុងរាជធានីភ្នំពេញ។ ហើយវានឹងប្រមូលផ្តុំដោយអគារពាណិជ្ជកម្មធំៗដូចជា ខុនដូ ផ្សារទំនើប សណ្ឋាគារ និងអគារស្នាក់នៅជាដើម។ [10]

តំបន់សេដ្ឋកិច្ចឧស្សាហកម្មកោះនរាមានដូចជា ៖

- ❖ ការធ្វើដំណើរ និងការដឹកជញ្ជូន
    - ➢ ក្រុមហ៊ុន OCIC បច្ចុប្បន្នកំពុងធ្វើកិច្ចការងារជាមួយក្រុមហ៊ុនចិនមួយដែលមានឈ្មោះថា «Cana Sino Construction» ដើម្បីសាងសង់ស្ពានចំនួនពីរទីតាំង។ ស្ពានទី១ជាប្រភេទស្ពានបេតុងយោងកាប ដែលមានដៃករាងឥន្ទធនូពីរសងខាង តភ្ជាប់ពីផ្លូវជាតិលេខ១ ទៅកាន់តំបន់អភិវឌ្ឍន៍សេដ្ឋកិច្ចកោះនរា។ ស្ពាននេះមានបណ្តោយប្រវែង ៦០ម៉ែត្រ ទទឹង២០ម៉ែត្រ និងមានគន្លងចំនួនបីសម្រាប់យានយន្ត និងមួយគន្លងសងខាងសម្រាប់ថ្មើរជើង។ ចំពោះគម្រោងថវិកាចំណាយមានចំនួន ១.៦លានដុល្លារអាមេរិក និងចំណាយពេលសាងសង់ប្រមាណជា១៧ខែ។
    - ➢ ស្ពានទី២ ជាប្រភេទស្ពានបេតុងខ្សែកាប តភ្ជាប់ពីតំបន់សេដ្ឋកិច្ចកោះនរាទៅកាន់ទីក្រុងរណបកោះពេជ្រ មានប្រវែងបណ្តោយ៨២៤ម៉ែត្រ និងទទឹង២៤.៥ម៉ែត្រ និងមានបីគន្លងសម្រាប់យានយន្ត និងមួយគន្លងសងខាងសម្រាប់ថ្មើរជើង បន្ថែមពីនេះសរសរខ្សែកាបមានកម្ពស់

[9] ដកស្រង់ចេញពី គេហទំព័រ https://foodbuzz.site ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣។

[10] ដកស្រង់ចេញពី ប្រសាសន៍របស់អ្នកឧកញ៉ា ពង់ ឃាវសែ អគ្គនាយកក្រុមហ៊ុនOCIC។

៦០ម៉ែត្រចំនួន២ដើម ដែលមានចម្លាក់ក្បាច់ខ្មែរយ៉ាងពិសេស ធ្វើឱ្យស្ពានមានកម្ពស់ពីផ្ទៃទឹកដល់ទៅ៨ម៉ែត្រ ជាអតិបរិមានៅរដូវវស្សាសម្រាប់នាវាទេសចរណ៍អាចឆ្លងកាត់បាន ដែលគ្រោងចំណាយថវិកា៣៨លានដុល្លារអាមេរិក និងប្រើប្រាស់រយៈពេលសាងសង់ប្រមាណជា៣៥ខែ។ តំបន់ទីក្រុងរណបកោះនរានឹងក្លាយជាតំបន់មួយដែលមានហេដ្ឋារចនាសម្ព័ន្ធល្អ និងតំបន់សេដ្ឋកិច្ចឧស្សាហកម្មដ៏ល្អប្រសើរ បន្ថែមពីនេះកោះនរាក៏ជា ទីតាំងល្អ លើគ្រប់ទិដ្ឋភាព ទាំងការរស់នៅ ការវិនិយោគ ជាពិសេសទីផ្សារធ្វើឱ្យអចលនទ្រព្យទីនោះនឹងមានកំណើនខ្ពស់នៅពេលអនាគត។

❖ គម្រោងវិនិយោគ

- ដោយឡែកផែនការអភិវឌ្ឍ តំបន់សេដ្ឋកិច្ចឧស្សាហកម្មទីក្រុងរណបកោះនរា តាមរយៈប្លង់គោលមានសភាពស្រដៀងគ្នានឹងទីក្រុងកោះពេជ្រនាពេលបច្ចុប្បន្ននេះដោយវានឹងក្លាយជាមជ្ឈមណ្ឌលពាណិជ្ជកម្មលំដាប់ពិភពលោកអន្តរជាតិនាពេលអនាគត។
- គម្រោង Vue Aston ត្រូវបានអភិវឌ្ឍន៍ដោយក្រុមហ៊ុន Peninsula Capital គម្រោងនេះមានទីតាំងស្ថិតនៅសង្កាត់និរោធ ខណ្ឌច្បារអំពៅ ដែលធ្វើការសាងសង់ខុនដូនៅតំបន់អភិវឌ្ឍន៍ដ៏សំខាន់មួយនៅរាជធានីភ្នំពេញ។ ហើយទន្ទឹមគ្នានេះដែរ អ្នករស់នៅគម្រោង វូ អាស្តុន និងកាន់តែមានភាពងាយស្រួលក្នុងការធ្វើដំណើរទៅតំបន់ទីប្រជុំជនកណ្តាលក្រុង ដោយចំណាយពេលត្រឹមតែប៉ុន្មាននាទីប៉ុណ្ណោះ ក្រោយមានស្ពានភ្ជាប់ពីកោះពេជ្រទៅកោះនរា។
- ក្រុមហ៊ុនអភិវឌ្ឍសិង្ហបុរី AKRAM Development Co Ltd បានទិញយកដីធ្លីជាង៣.៥ហិកតានៅតំបន់ទីក្រុងរណបកោះនរាពីក្រុមហ៊ុនវិនិយោគទុនអាណិកជនកម្ពុជា OCIC សម្រាប់គម្រោងវិនិយោគបែបប្រណិតលំដាប់កំពូលរបស់ខ្លួន ដែលគ្រោងនឹងវិនិយោគជាង១៥០លានដុល្លារ។ លោក Kelvin Chua អគ្គនាយកនៃ AKRAM Development Co Ltd បានថ្លែងថា គោលបំណងនៃការទិញនេះ គឺដើម្បីអភិវឌ្ឍន៍នូវគម្រោងបែបប្រណិតកំពូល ដោយសារតែលោកបានមើលឃើញថា ទីក្រុងកោះនរា គឺជាទីតាំងយុទ្ធសាស្ត្រដ៏មុតមាំមួយដែលមិនត្រឹមតែនៅជាប់ដងទន្លេមេគង្គប៉ុណ្ណោះទេ តែក៏ស្ថិតនៅកៀកជាមួយ និងទីតាំងដ៏ពិសេសពីរផ្សេងទៀតគឺទីក្រុងកោះពេជ្រ និងNaga Worldផងដែរ។
- បុរីប៉េងហួតបឹងស្នោ ជាគម្រោងបុរីធំជាងគេនៅផ្លូវជាតិលេខ១ ដែលប្រមូលផ្តុំដោយផ្ទះម៉ូដប្លែកៗដូចជា ហ្សបហោស៍ វីឡាទោល វីឡាភ្លោះ និងភូមិគ្រឹះតម្លៃរាប់លានដុល្លារ ហើយនៅក្នុងបុរី

មានគ្រប់សេវាកម្មប្រៀបដូចជាកូនទីក្រុងតូចមួយទៅហើយនៅតំបន់កោះនរា ដោយសារតែមានហាងលក់អាហារតូចធំ និងសាលារៀនជាដើម។

- បុរីហាយធិចលុច្យសារី ក៏ជាគម្រោងបុរីមួយដ៏ធំនៅលើផ្លូវជាតិលេខ១។ បុរីហាយធិចលុច្យសារីផ្តោតសំខាន់លើការអភិវឌ្ឍលំនៅឋានបែបប្រណិតៗ សម្រាប់អ្នកមានជីវភាពលំដាប់។ បុរីនេះមានចម្ងាយត្រឹមតែជាង៨០០ម៉ែត្រខាងកើតស្ពានព្រះមុនីវង្ស។
- គម្រោងអភិវឌ្ឍន៍លំនៅឋាន The Palms ដែលជាការវិនិយោគរួមរវាងក្រុមហ៊ុន Worldbridge Land (Cambodia) Co Ltd ជាក្រុមហ៊ុនអចលនទ្រព្យមានមូលដ្ឋាននៅប្រទេសកម្ពុជា និងក្រុមហ៊ុន Oxley Holdings Limited ជាក្រុមហ៊ុនអចលនទ្រព្យមានមូលដ្ឋាននៅប្រទេសសិង្ហបុរី។ គម្រោងអភិវឌ្ឍន៍លំនៅឋាន The Palms គឺជាគម្រោងលំនៅឋានបែបរមណីយដ្ឋានប្រណិតដំបូងគេក្នុងរាជធានីភ្នំពេញ។ គម្រោងនេះមានផ្តល់ជូននូវប្រភេទលំនៅឋានបែបផ្ទះ វីឡាជាប់មាត់ទន្លេ។

❖ កន្លែងកម្សាន្តនៅកោះនរា

- សួនច្បារកោះនរា គឺជាសួនច្បារមួយដែលមានទីតាំងស្ថិតនៅភូមិកោះនរា សង្កាត់និរោធ ខណ្ឌច្បារអំពៅ ក្រុងភ្នំពេញនឹងមានចម្ងាយប្រហែល៩គីឡូម៉ែត្រពីវត្តភ្នំ។ សួនច្បារនរានេះស្ថិតនៅក្នុងប្រភេទ ទេសចរណ៍កែច្នៃ ឬរមណីដ្ឋានកែច្នៃ រីឯចំណុចសំខាន់ៗនៅសួនច្បារនេះមានដូចជាសួនកុមារ ឬកន្លែងលេងទោង ពិចនិច កាហ្វេ គយគន់ថ្ងៃរះ គយគន់ថ្ងៃលិច ទស្សនាសួនដំណាំទស្សនាសួនផ្កា និងចំណុចផ្សេងៗទៀត។ មិនតែប៉ុណ្ណោះនៅទីនោះ លាតសន្ធឹងទៅដោយវាលស្មៅបៃតង ប្រឡមាត់ស្រះ ជាពិសេសមានផ្ការាប់រយប្រភេទរីកស្គុះស្គាយដេដាស បម្រើអារម្មណ៍ប្រិយមិត្តឱ្យរលាយអស់នូវទុក្ខកង្វល់ នឹងថតរូបលេងជាមួយនឹងប្លង់ថតរូបស្អាតៗ ដោយសេរីពុំគិតថ្លៃចូលទស្សនានោះឡើយ។
- ទន្លេលាភ ស្ថិតនៅភូមិកោះនរា សង្កាត់និរោធ ខណ្ឌច្បារអំពៅ គឺជាអាហារដ្ឋាន និងលំហែលើមាត់ទឹកបែបរមនីយដ្ឋានធម្មជាតិ។ នៅទីនោះអាហារដែលគួរឱ្យចាប់អារម្មណ៍ដែលមិនគួររំលងមាន ខ្យងអាំង ត្រីបឹងកញ្ចែត និងជ្រូកកណ្តុរ។ វាជាកន្លែងលំហែដែលសក្តិសមបំផុតនៅក្នុងរាជធានីភ្នំពេញ ព្រោះបានផ្តល់នូវភាពសម្បូរបែប។ [11]

[11] ដកស្រង់ចេញពី គេហទំព័រ https://Harbor-property.com ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣។

## ១.២. កត្តាជម្រុញនាំឱ្យមានការរៀបចំទីក្រុងរណបគោះនរា

នៅក្នុងរាជធានីភ្នំពេញ មានទីក្រុងរណបប្រមាណជា១០ដែលបានកំពុងនឹងសាងសង់ និងមានទីក្រុងរណបមួយចំនួនហាក់បានជាប់គាំង ដោយសារវិបត្តសេដ្ឋកិច្ចនៃក្រុមហ៊ុនផ្ទាល់។ ប៉ុន្តែបើនិយាយពីគុណប្រយោជន៍វិញទីក្រុងរណបដើរតួនាទីសំខាន់ណាស់ក្នុងការជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងកាត់បន្ថយលំហូរមនុស្សចូលក្នុងទីក្រុងគោល។ ដោយរាជរដ្ឋាភិបាលកាលពីកន្លងមកនេះ បានដាក់ចេញផែនការអភិវឌ្ឍទីក្រុងរណប តាមរយៈការផ្តល់ឱកាសដល់ក្រុមហ៊ុនទាំងនៅក្នុងស្រុក និងក្រៅស្រុកចូលរួមអភិវឌ្ឍន៍នៅតាមជាយរាជធានីភ្នំពេញ ជាក់ស្តែងស្ទើរតែគ្រប់ទិស នៃរាជធានីភ្នំពេញមានការចូលរួមអភិវឌ្ឍន៍ទីក្រុងរណបពីក្រុមហ៊ុនផ្សេងៗជាច្រើន។

អ្នកជំនាញបានអះអាងថា ការអភិវឌ្ឍទីក្រុងរណបកាន់តែច្រើន និងជួយជម្រុញឱ្យមានកំណើនសេដ្ឋកិច្ច និងរីកចម្រើនលើវិស័យសំណង់នៅក្នុងប្រទេស ខណៈរដ្ឋាភិបាលបាន និងកំពុងអភិវឌ្ឍន៍ទីក្រុងរណបស្របតាមផែនការ និងប្លង់គោលអភិវឌ្ឍន៍ប្លង់គោលនាពេលបច្ចុប្បន្ននេះ។ ប្រធានក្រុមប្រឹក្សាអភិបាលនៃសមាគមន៍អចលនទ្រព្យកម្ពុជា លោក **យាង ពុទ្ធី** បានឱ្យដឹងកាលពីថ្មីៗនេះថា មិនថានៅក្នុងប្រទេសកម្ពុជា ឬនៅតាមបណ្តាប្រទេសនៅលើពិភពលោកនេះ គឺគេបង្កើតតំបន់អភិវឌ្ឍន៍ថ្មីៗដែលហៅថាទីក្រុងរណប ដើម្បីជម្រុញកំណើនសេដ្ឋកិច្ច និងសំណង់ឱ្យមានការរីកចម្រើន។ លោកបន្ថែមទៀតថានៅក្នុងទីក្រុងភ្នំពេញមានការរីកចម្រើន និងមានកំណើនប្រជាជន បានជាគេព្យាយាមអភិវឌ្ឍទីក្រុងរណបបន្ថែមទៀត ដើម្បីជម្រុញការអភិវឌ្ឍគម្រោងខុនដូ ផ្សារទំនើប និងអគារពាណិជ្ជកម្មផ្សេងៗទៀត។ លោកបន្តទៀតថា ការបង្កើតឱ្យមានទីក្រុងរណបនេះ គឺឆ្លើយតបទៅនឹងកំណើនតម្រូវការ សេដ្ឋកិច្ច និងការរស់នៅ នៅពេលដែលបង្កើតឱ្យមានតំបន់អភិវឌ្ឍន៍ថ្មីៗបែបនេះក៏នឹងជួយវិស័យអចលនទ្រព្យ ជាពិសេសសំណង់កើនឡើង ព្រោះថាតំបន់ថ្មីត្រូវការសាងសង់សំណង់ផ្សេងៗ ប៉ុន្តែបញ្ហាតែមួយប៉ុណ្ណោះ គឺរដ្ឋាភិបាលមិនទាន់បានកំណត់ឱ្យបានច្បាស់លាស់ចំពោះការបែងចែកតំបន់អភិវឌ្ឍន៍ ដោយពេលខ្លះរាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យសាងសង់រោងចក្រក្បែរនឹងសណ្ឋាគារជាដើម។

ចំណែកលោក **ឡុង គឹមសួគ៌** អគ្គនាយកក្រុមហ៊ុន Century21 Advance បានឱ្យដឹងដែរថាការអភិវឌ្ឍតំបន់ទីក្រុងរណបកាន់តែច្រើន និងជួយជម្រុញកំណើនសេដ្ឋកិច្ចតាមរយៈការផ្លាស់ប្តូរពាណិជ្ជកម្មនានា ឱ្យកាន់តែមានភាពងាយស្រួល និងធ្វើឱ្យវិស័យកាន់តែមានតម្លៃខ្ពស់ផងដែរ។ លោកបន្តថា ជាពិសេសនោះនៅពេលដែលមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជុំវិញក្រុង គឺបានធ្វើឱ្យវិស័យអចលនទ្រព្យ និងសំណង់ មានការរីកចម្រើនជាខ្លាំង។

អ្នកឧកញ៉ា **ពង់ ឃាវសែ** អគ្គនាយកក្រុមហ៊ុន OCIC ធ្លាប់បានលើកឡើងកាលពីថ្មីៗនេះដែរថា គ្រាន់តែការអភិវឌ្ឍទីក្រុងរណបថ្មីមួយ នៅកោះនរាលើផ្ទៃដី១០០ហិកតា និងចូលរួមបង្កើនចំណូលថវិកាជាតិប្រមាណ ២៥០លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។ លោកបានថ្លែងថា គម្រោងអភិវឌ្ឍន៍ទីក្រុងរណបកោះនរានេះ និងផ្តល់អត្ថប្រយោជន៍ដល់សង្គមជាតិ និងសេដ្ឋកិច្ចជាតិយ៉ាងខ្លាំងជាពិសេសនៅក្នុងកាលៈទេសៈដែលកំពុងជួបវិបត្តនៅពេលនេះ ដែលកម្ពុជាកំពុងត្រូវការគម្រោងវិនិយោគបន្ថែមទៀត ដើម្បីជួយទ្រទ្រង់សកម្មភាពសេដ្ឋកិច្ចជាតិឱ្យបានរឹងមាំ។ លោកក៏បានបន្តទៀតថាតាមរយៈគម្រោងមួយនេះនឹងអនុគ្រោះដល់មនុស្សរស់នៅប្រមាណ៥ម៉ឺននាក់ហើយអាច និងចូលរួមចំណែកដល់ផលិតផលក្នុងស្រុក GDP ប្រមាណ២២៥លានដុល្លារអាមេរិកក្នុងមួយឆ្នាំៗស្មើនឹងប្រមាណ0.៩ភាគរយនៃ GDP នាពេលបច្ចុប្បន្ននេះ។[12]

### ១.២.១. កំណើនប្រជាជន

កំណើនប្រជាជន សំដៅទៅលើការកើនឡើង នៃចំនួនបុគ្គលក្នុងចំនួនប្រជាជនដែលបានផ្តល់ឱ្យក្នុងរយៈពេលមួយ។ វា គឺជានិន្នាការប្រជាសាស្ត្រដ៏សំខាន់បំផុតមួយបានបង្កើតប្រវត្តិសាស្ត្ររបស់មនុស្សជាតិ ហើយវាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើទិដ្ឋភាពផ្សេងៗនៃជីវិតមនុស្សរួមទាំងកត្តាសង្គម សេដ្ឋកិច្ច និងបរិស្ថាន។ មានកត្តាជាច្រើនដែលរួមចំណែកដល់កំណើនប្រជាជន រួមទាំងការកើនឡើងនៃធម្មជាតិ ការធ្វើចំណាកស្រុក និងការរីកចម្រើនផ្នែកបច្ចេកទេសវិទ្យា។ ការកើនឡើងធម្មជាតិ សំដៅទៅលើភាពខុសគ្នារវាងចំនួនកំណើត និងការស្លាប់ក្នុងចំនួនប្រជាជនក្នុងរយៈពេលមួយនៅក្នុងតំបន់ភាគច្រើននៃពិភពលោក អត្រាកំណើត គឺខ្ពស់ជាងអត្រាមរណភាព ដែលនាំឱ្យមានការកើនឡើងចំនួនប្រជាជនសរុប។ បាតុភូតនេះ គឺជារឿងធម្មតាជាពិសេសនៅក្នុង បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដែលអត្រាកំណើតច្រើនតែខ្ពស់ដោយសារជំនឿវប្បធម៌ សាសនា និងកង្វះលទ្ធភាពមធ្យោបាយពន្យាកំណើត និងកម្រិតនៃការអប់រំ ការថែទាំសុខភាពទាប។

ការធ្វើចំណាកស្រុក គឺជាកត្តាសំខាន់មួយទៀតដែលរួមចំណែកដល់កំណើនប្រជាជន។ មនុស្សផ្លាស់ប្តូរពីទីកន្លែងមួយទៅកន្លែងមួយទៀត សម្រាប់ហេតុផលផ្សេងៗដូចជា ឱកាសសេដ្ឋកិច្ច អស្ថេរភាពនយោបាយ ឬគ្រោះមហន្តរាយបរិស្ថាន។ ការធ្វើចំណាកស្រុកអាចមានទាំងផលវិជ្ជមាន និងផលអវិជ្ជមានលើអត្រាកំណើនប្រជាជននៅតំបន់មួយ។ **ឧទាហរណ៍៖** ការធ្វើចំណាកស្រុកអាចនាំឱ្យមានការកើនឡើងចំនួនប្រជាជននៅតំបន់ជាក់លាក់មួយ ខណៈពេលដែលធ្វើចំណាកស្រុកអាចធ្វើឱ្យមានការថយចុះនៃចំនួនប្រជាជន។

[12] ដកស្រង់ចេញពី គេហទំព័រ https://Propertyarea.asia ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣។

ការរីកចម្រើនផ្នែកបច្ចេកវិទ្យាក៏ បានរួមចំណែកដល់កំណើនប្រជាជនផងដែរ។ មួយវិញទៀតចំពោះការច្នៃប្រឌិតក្នុងវិស័យកសិកម្ម ឱសថ និងអនាម័យបាននាំឱ្យមានការកើនឡើងនៃអាយុជីវិតមនុស្ស និងជីវភាពរស់នៅកាន់តែប្រសើរឡើង ដែលបានរួមចំណែកដល់ការកើនឡើងនៃចំនួនប្រជាជន។ **ឧទាហរណ៍៖** បដិវត្តបៃតងនៃទសវត្សន៍ឆ្នាំ១៩៦០ និងឆ្នាំ១៩៧០ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ពូជដំណាំដែលផ្តល់ទិន្នផលខ្ពស់ ជី និងថ្នាំសម្លាប់សត្វល្អិតបាននាំឱ្យមានការកើនឡើងយ៉ាងខ្លាំង នៃផលិតកម្មស្បៀងដែលអនុញ្ញាតឱ្យមានកំណើនប្រជាជនជានិរន្តភាព។ ទោះជាយ៉ាងណាក៏ដោយកំណើនប្រជាជនក៏អាចមានផលវិបាក ឬអវិជ្ជមានផងដែរ ព្រោះវាបាននាំឱ្យមានភាពចង្អៀតណែន ការរិចរឹលបរិស្ថាន ការបាត់បង់ធនធាន និងការបង្កើនការប្រកួតប្រជែងសម្រាប់ធនធាន។ បញ្ហាទាំងនេះបង្ហាញឱ្យឃើញជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលកំណើនប្រជាជនយ៉ាងឆាប់រហ័សបានធ្វើឱ្យមានការប៉ះពាល់ជាខ្លាំងដល់ធនធានធម្មជាតិ និងបរិស្ថាន ជាពិសេសវាធ្វើឱ្យកំណើនសេដ្ឋកិច្ច និងវិបុលភាពកើនឡើង វាក៏អាចបង្កឱ្យមានភាពតានតឹងដល់គោលនយោបាយដែលត្រូវគិតគូរពីផលវិបាករយៈពេលវែងនៃកំណើនប្រជាជន និងបង្កើតដំណោះស្រាយទៅលើបញ្ហាប្រឈមនានាដែលទាក់ទងទៅនឹងកំណើនប្រជាជន។ [13]

### ១.២.២. ស្តង់ដានៃការរស់នៅ

ការរៀបចំទីក្រុងរណប គឺមានសារៈសំខាន់ណាស់សម្រាប់ស្តង់ដានៃការរស់នៅ ដែលបានផ្តល់នូវផលប្រយោជន៍សេដ្ឋកិច្ច និងការគ្រប់គ្រងបរិស្ថាន និងសុខុមាលភាព មានន័យថាស្តង់ដានៃការរស់នៅភាគច្រើនបានស្មើទៅដូចជាគំនិតជាកម្រិតនៃសុខុមាលភាពរបស់ប្រជាពលរដ្ឋនេះ ។ វាត្រូវបានវាស់ជាក្បួន សូចនាករនៃផលិតផលក្នុងស្រុកសរុបក្នុងមួយ Capital។ នៅក្នុងការពិត ទោះបីជាយ៉ាងណាក្នុងការកំណត់ស្តង់ដានៃការរស់នៅត្រូវតែបានដឹកនាំនឹងតម្លៃដែលមិនមែនជាសម្ភារៈ។ **ឧទាហរណ៍៖** តម្លៃធំនៅក្នុងការគណនានេះ គឺជាសន្ទស្សន៍នៃការអភិវឌ្ឍមនុស្សឱ្យមានសក្តានុពល។ វារួមបញ្ចូលទាំងកម្រិតនៃអក្ខរកម្មក្នុងប្រទេសនេះនឹងការពេញចិត្តរបស់ប្រជាពលរដ្ឋជាមួយការងារ និងកន្លែងរបស់ពួកគេនៅក្នុងជីវិត។ ដូចនេះផងដែរពីសារៈសំខាន់នៃការអស្ចារ្យ តួយ៉ាងអាយុកាល និងស្ថានភាពសុខភាព។ ជាអ្នកមានប៉ុន្តែអ្នកជំងឺទំនងជាមិនមានការសប្បាយចិត្ត។ អ្នកអាចរស់នៅក្នុងការគាំទ្រសម្ភារៈពេញលេញ ប៉ុន្តែវាត្រូវបានប្រទះនឹងភាពខុសគ្នានៃកត្តាដែលបង្កគ្រោះថ្នាក់ដល់សុខភាព ការនេះគួរតែរួមបញ្ចូលទាំងភាពតានតឹង។

ប្រសិនបើវាត្រឹមត្រូវការរៀបចំទីក្រុង និងធ្វើឱ្យមានការចែករំលែកនូវសុខភាពសាធារណៈ និងសុវត្ថិភាព។ ការអំពាវនាវឱ្យមានការរៀបចំតាមដងផ្លូវឱ្យបានល្អ ដើម្បីឱ្យមានការទាក់ទាញឱ្យមានអ្នកដើរកាន់តែច្រើនទាំង

[13] ដកស្រង់ចេញពី គេហទំព័រ https://helloneakkru.com ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣។

ដែលពួកគេមិនដឹងខ្លួនក្នុងការតាមដានមើលមនុស្សម្នាក់ផ្សេងទៀត។ខណៈពេលដែលធ្វើឱ្យកាន់តែប្រសើរឡើងនូវទេសភាពតាមដងផ្លូវ និងចរាចរណ៍មានភាពស្ងប់ស្ងាត់ក្នុងគោលបំណងធ្វើឱ្យមានអ្នកដើរកាន់តែច្រើន អ្នកជិះកង់ និងចរាចរណ៍រថយន្ត។ ទាំងនេះ គឺជាការលើកទឹកចិត្តចំពោះអ្នកដើរ ឬជិះកង់ ជំនួសការបើកបរ។ ផ្សព្វផ្សាយពីការធ្វើលំហាត់ប្រាណ និងទំនាក់ទំនងសង្គមជាមួយអ្នកជិតខាង។ ចំនួននៃការសិក្សាដែលមានទំនាក់ទំនងជាមួយនឹងការរីកដុះដាលនៃចរិតលក្ខណៈសង្គមក្នុងការកសាងបរិស្ថាន រាប់បញ្ចូលទាំងការបង្កើតឱ្យមានសង្គមដែលមានអ្នកដើរដោយផ្ទាល់ដើម្បីសុខភាពសាធារណៈ។

ជាក់ស្តែងអ្នកដើរជាច្រើន គឺនៅលើផ្លូវការថយចុះនូវគ្រោះថ្នាក់នីយភាព គឺត្រូវមានការចូលរួមពីអ្នកបើកបរ។ បើតាមការសិក្សាផ្សេងៗគ្នាបានបង្ហាញថា អ្នកបើកបរបានស៊ាំនឹងការបើកបរជាងការដើរថ្មើរជើង សរុបមកពួកគេមិនបានដឹងខ្លួនទេ ក្នុងការក្លាយជាមនុស្សដែលមានការប្រុងប្រយ័ត្នកាន់តែខ្លាំងនិងការតាំងចិត្ត។ [14]

## ១.៣. រចនាសម្ព័ន្ធគ្រប់គ្រងទីក្រុងរណបកោះនរា

រចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ ៖ [15]




រចនាសម្ព័ន្ធក្នុងការគ្រប់គ្រងទីក្រុងរណប គឺជាគោលនយោបាយស្តីពីប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ បានផ្តល់ជាទស្សនទាន និងចង្អុលបង្ហាញដល់ការរៀបចំ និងកែសម្រួលសេចក្តីណែនាំបច្ចេកទេស

[14] ដកស្រង់ចេញពី សៀវភៅនគរូបនីយវិទ្យារបស់សាស្ត្រចារ្យ បណ្ឌិត អ៊ុន សក្កដា ២០២៣។

[15] ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុម័តនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៨។

ស្ដីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍឱ្យស្របតាមចរិតលក្ខណៈផ្សេងៗគ្នារបស់ រដ្ឋបាលនីមួយៗនៅថ្នាក់ក្រោមជាតិ។[16]

### ១.៣.១. អន្តរក្រសួងពាក់ព័ន្ធ

មុននឹងមានការរៀបចំចេញជាទីក្រុងណាមួយបាន គេចាំបាច់ណាស់ត្រូវតែមានការចូលរួមពីអន្តរក្រសួងពាក់ព័ន្ធដូចមាននៅខាងក្រោម៖

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសុខាភិបាល
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល
- ក្រសួងអភិវឌ្ឍជនបទ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងទេសចរណ៍។

### ១.៣.២. តួនាទី និងភារកិច្ចរបស់អន្តរក្រសួង និងមន្ទីរដែលពាក់ព័ន្ធ

ដើម្បីសាងសង់ ឬបង្កើតទីក្រុងណាមួយបាន គេចាំបាច់ត្រូវតែយល់ដឹងពីតួនាទី និងភារកិច្ចរបស់អន្តរក្រសួងដែលពាក់ព័ន្ធទៅនិងការបង្កើតទីក្រុងណេប ក៏ដូចជាការបង្កើតនូវទីក្រុងផ្សេងៗទៀត។

តួនាទី និងភារកិច្ចរបស់អន្តរក្រសួងពាក់ព័ន្ធមានដូចជា៖

- តួនាទី និងភារកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសុរិយោដីខេត្ត ក្រុង៖
  - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសុរិយោដីខេត្ត ក្រុង ត្រូវតែអនុវត្តគោលនយោបាយ និងទិសដៅការងាររបស់ក្រសួងរួមមាន ការងាររៀបចំដែនដី ការងារនគរូបនីយកម្ម ការងារសំណង់ ការងារសុរិយោដី ការងារភូមិសាស្ត្រ ដើម្បីធានានូវតុល្យភាព និងស្ថេរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច និង

[16] ដកស្រង់ចេញពី គេហទំព័រ https://ncdd.gov.kh ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣។

សង្គមសំដៅការពារផលប្រយោជន៍នៃសណ្តាប់ធ្នាប់ជាសាធារណៈ លើកកម្ពស់សោភ័ណភាពសង្គម ការពារសម្បត្តិធម្មជាតិ និងវប្បធម៌ជាតិ

- ចងក្រងឯកសារទិន្នន័យទាក់ទង និងការងាររៀបចំដែនដីនគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រដោយសហការជាមួយអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ
- អនុវត្តបទប្បញ្ញត្តិ លិខិតបទដ្ឋានបច្ចេកទេសនានា របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផ្តល់មតិយោបល់ និងពិនិត្យលើការស្នើសុំទីតាំងសាងសង់ ដោយផ្អែកលើលិខិតអនុញ្ញាតរបស់ក្រសួង
- សហការជាមួយអាជ្ញាធរដែនដី អង្គការជាតិ និងអន្តរជាតិ
- ចូលរួមផ្តល់យោបល់អំពីគុណភាពសំណង់ បរិក្ខារ និងគ្រឿងចក្រព្រមទាំងដាក់ឱ្យពិសោធន៍សម្ភារៈគ្រឿងផ្គុំសំណង់ និងភូគព្ភសាស្ត្រ
- គ្រប់គ្រងតាមដាន ត្រួតពិនិត្យការស្រាវជ្រាវគម្រោងប្លង់ និងសំណង់ បណ្តាខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ-សង្កាត់ ក្នុងសមត្ថកិច្ចរបស់ខ្លួន និងតាមការប្រគល់ភារកិច្ចពីក្រសួង
- ចេញលិខិតអនុញ្ញាត បើក ផ្អាក និងបិទអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់ដល់រូបវន្តបុគ្គល និងក្រុមជាងសំណង់ និងពិនិត្យតាមដានសមត្ថភាពបច្ចេកទេសអាជីវកម្ម
- លើកផែនការបណ្តុះបណ្តាលមន្ត្រីជំនាញ
- ណែនាំការងាររៀបចំការដ្ឋានសំណង់ បើក និងបិទការដ្ឋាន
- ចេញលិខិតអនុញ្ញាតសាងសង់
- តាមដានអនុវត្តបទប្បញ្ញត្តិ សេចក្តីណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការជួសជុល ថែទាំ ប្រើប្រាស់សំណង់អគារ សំណង់ការ្យ និងបេតិកភណ្ឌក្នុងខេត្ត ក្រុង
- គ្រប់គ្រងដីធ្លីគ្រប់ប្រភេទ
- វាស់វែង និងគណនាឋានលេខា ស្ថានភាពដី និងក្បាលដី ក្នុងក្របខណ្ឌសមត្ថកិច្ច និងភូមិសាស្ត្ររដ្ឋបាលដែលទទួលខុសត្រូវ
- កសាងប្លង់ដីគ្រប់ប្រភេទ ប្លង់ស្ថានភាពដីទូទៅ ប្លង់សុរិយោដី ប្លង់ក្បាលដី ប្លង់ដីក្នុងទីប្រជុំជន

- ចូលរួមសិក្សា និងកសាងឯកសារពន្ធអាករដី និងលើកគម្រោងចំណូលពន្ធអាការដីប្រចាំឆ្នាំក្នុងទូទាំងខេត្ត ក្រុង ក្នុងសមត្ថកិច្ចរបស់ខ្លួន។ [17]

❖ តួនាទី និងភារកិច្ចរបស់ក្រសួងអប់រំយុវជន និងកីឡាៈ

- កំណត់នយោបាយអប់រំ យុវជន និងកីឡា សំដៅធានាការអភិវឌ្ឍធនធានមនុស្សប្រកបដោយចីរភាព
- កសាងនីតិក្រមសម្រាប់អភិវឌ្ឍន៍វិស័យអប់រំ យុវជន និងកីឡា
- កសាងផែនការអនុវត្ត ពិនិត្យតាមដាន និងវាយតម្លៃនយោបាយអប់រំ យុវជន និងកីឡា ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស ព្រមទាំងលើកទិសដៅ និងវិធានការកែលម្អជាបន្តបន្ទាប់តាមគ្រប់មុខជំនាញ
- លើកកម្ពស់គុណភាពវិស័យអប់រំ យុវជន និងកីឡាឱ្យឆ្លើយតបទៅនឹងដំណាក់កាលនីមួយៗនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិ និងអន្តរជាតិ ដើម្បីកសាងសមត្ថភាពខាងចំណេះដឹង ចំណេះធ្វើ សីលធម៌ និងចេះរួមរស់ជាមួយគ្នា
- តម្រង់ទិសវិជ្ជាជីវៈ បំណិនជីវិត និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅគ្រប់ភូមិសិក្សា
- ពិនិត្យសំណើ បង្កើត ការបិទ ការរំលាយបញ្ចូលគ្នា ការបង្កើតជំនាញថ្មី ការបំបែក ការប្រែក្លាយ និងទទួលស្គាល់គ្រឹះស្ថានសិក្សា និងថ្នាក់រៀនសាធារណៈ និងឯកជនគ្រប់ប្រភេទ និងគ្រប់កម្រិត
- លើកកម្ពស់ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍វិស័យអប់រំ យុវជន និងកីឡា
- គ្រប់គ្រង ត្រួតពិនិត្យ វាយតម្លៃដំណើរការសិក្សា ការនិពន្ធ ការផ្សាយ ការនាំចូលសៀវភៅសិក្សា និងឯកសារពាក់ព័ន្ធការបង្រៀន និងរៀន គ្រប់កម្រិតសិក្សា គ្រប់ភូមិសិក្សា និងដាក់ពិន័យ
- ពិនិត្យលើការផ្តល់ បដិសេធ ដកហូតវិញ្ញាបនបត្រ ឬ សញ្ញាបត្រ និងវាយតម្លៃកម្រិតវិញ្ញាបនបត្រ ឬ សញ្ញាបត្រចេញដោយគ្រឹះស្ថានសិក្សានានា ទាំងក្នុង និងក្រៅប្រទេស
- ផលិត និងត្រួតពិនិត្យការផ្សព្វផ្សាយព័ត៌មានអប់រំ ការផ្សាយពាណិជ្ជកម្មសិក្សាតាមគ្រប់រូបភាពពាក់ព័ន្ធនឹងវិស័យអប់រំ យុវជន និងកីឡា

[17] ប្រកាសស្តីពី តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង និងតួនាទីភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ លេខ៧៦, ប្រការ១។

- អភិវឌ្ឍន៍ការងារយុវជន និងការងារអប់រំកាយ និងកីឡាដោយកំណត់វិធានគ្រប់គ្រងអប់រំបណ្តុះបណ្តាល និងបំប៉នបច្ចេកទេស
- បង្កើនការយល់ដឹងអំពីវប្បធម៌ជាតិ និងវប្បធម៌អន្តរជាតិ
- គ្រប់គ្រងបុគ្គលិកហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ពិនិត្យ និងផ្តល់យោបល់គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងវិស័យអប់រំ យុវជន និងកីឡា
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនរដ្ឋាភិបាល។ [18]

❖ តួនាទី និងភារកិច្ចរបស់ក្រសួងសុខាភិបាល៖

- កំណត់គោលនយោបាយសុខាភិបាលដោយផ្អែកលើមូលដ្ឋានកម្មវិធីរបស់រាជរដ្ឋាភិបាលសំដៅលើកកម្ពស់សុខភាព និងសុខុមាលភាពរបស់ប្រជារាស្ត្រ
- ធ្វើផែនការ និងរៀបចំយុទ្ធសាស្ត្រសម្រាប់វិស័យសុខាភិបាល
- រៀបចំលិខិតបទដ្ឋាន សំដៅធានាជាអតិបរមាគុណភាពសុខាភិបាលសាធារណៈ និងឯកជន
- តាមដានរំលឹកត្រួតពិនិត្យ និងវាយតម្លៃការងាររដ្ឋបាល និងបច្ចេសទេសនៃអង្គភាពសុខាភិបាលស្របតាមច្បាប់ និងលិខិតបទដ្ឋានដែលបានដាក់ចេញឱ្យអនុវត្តជាផ្លូវការ
- សិក្សារកមធ្យោបាយនានា សម្រាប់អភិវឌ្ឍន៍ផ្នែកសុខាភិបាល និងគ្រប់គ្រងបណ្តាធនធានមនុស្សសម្ភារៈ ហិរញ្ញវត្ថុ និងព័ត៌មានឱ្យសមស្របទៅនឹងប្រព័ន្ធសុខាភិបាលសាធារណៈនៅថ្នាក់កណ្តាលខេត្តក្រុង រាជធានី ស្រុក ខណ្ឌឃុំ និងសង្កាត់
- រៀបចំកម្មវិធីបង្ការ និងថែទាំវេជ្ជសាស្ត្រ សំដៅបំបាត់ ឬកាត់បន្ថយស្ថានិករោគ ដែលមាននៅក្នុងប្រទេស
- សម្របសម្រួលធនធាននានា ឱ្យបានស្របទៅតាមតម្រូវការ និងឱ្យទទួលបានទិន្នផលល្អប្រសើរ

[18] អនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ១៥៦, អនក្រ.បក, ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០១៦, មាត្រា៥។

- គ្រប់គ្រងប្រព័ន្ធផលិតកម្មអាជីវកម្ម និងបែងចែកឱសថ បរិក្ខាអមវេជ្ជសាស្ត្រ និងសម្ភារៈវេជ្ជសាស្ត្រជូនដល់គ្រប់អង្គភាពសាធារណៈ និងឯកជន
- ពិនិត្យតាមដានសុវត្ថិភាពចំណីអាហារ។ [19]

❖ តួនាទី និងភារកិច្ចរបស់ក្រសួងបរិស្ថាន៖

- រៀបចំទស្សនៈវិស័យ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ព្រមទាំងកំណត់អាទិភាពប្រកបដោយចីរភាព ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ
- តាក់តែង និងអនុវត្តលិខិតបទដ្ឋាន និងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តភាព និងការរស់នៅប្រកបដោយចីរភាព
- សម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ក្នុងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីនានាពាក់ព័ន្ធនិងវិស័យបរិស្ថាន
- ផ្តល់យោបល់ដល់ក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីធានាការអភិរក្ស អភិវឌ្ឍន៍ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តភាព
- គ្រប់គ្រងទិន្នន័យបរិស្ថាន និងដឹកនាំសម្របសម្រួលការងារអប់រំ និងការផ្សព្វផ្សាយបរិស្ថានព្រមទាំងចាត់ចែងព្រឹត្តិការណ៍សំខាន់ៗទាក់ទងនិងវិស័យបរិស្ថាន
- លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តភាព និងការរស់នៅប្រកបដោយចីរភាព តាមរយៈការផ្សព្វផ្សាយព័ត៌មាន និងសកម្មភាពបង្កើតការយល់ដឹងនានា
- លើកទឹកចិត្តឱ្យមានការចូលរួមជាសាធារណៈក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តភាព និងការរស់នៅប្រកបដោយចីរភាព តាមរយៈការពិគ្រោះយោបល់ជាសាធារណៈនៅក្នុងដំណើរការសេចក្តីសម្រេចនានា
- ផលិត និងផ្សព្វផ្សាយព័ត៌មានស្តីពីសកម្មភាពទាក់ទង និងកិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិជូនសាធារណៈជន

[19] អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល លេខ៦៧, អនក្រ.បក, ថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧, មាត្រា៣។

- គ្រប់គ្រង និងសម្របសម្រួលកិច្ចគាំពារបរិស្ថាន រួមមានការគ្រប់គ្រងគុណភាពទឹក ខ្យល់ និងដី ការគ្រប់គ្រងសម្លេងរំខាន និងការគ្រប់គ្រងការបំភាយកាំរស្មីវិទ្យុសកម្ម និងអេឡិចត្រូម៉ាញ៉េទិច
- រៀបចំ និងអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីនានាសម្រាប់វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងការពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់គម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន
- គ្រប់គ្រង និងសម្របសម្រួលការងារការពារ និងអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព
- ប្រមូលវិភាគ និងគ្រប់គ្រងទិន្នន័យបរិស្ថាន និងធនធានធម្មជាតិ
- ជម្រុញ និងលើកទឹកចិត្តឱ្យមានការវិនិយោគក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព
- កៀងគរ និងគ្រប់គ្រងធនធានសម្រាប់កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព
- សហការជាមួយបណ្ដាប្រទេសនៅក្នុងតំបន់ និងពិភពលោក អង្គការជាតិ អង្គការអន្តរជាតិ និងសហគមន៍មូលដ្ឋាន ដើម្បីធានាឱ្យមាននូវកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព
- លើកសំណើរជូនរាជរដ្ឋាភិបាល អំពីការចូលរួមក្នុងកិច្ចព្រមព្រៀងអនុសញ្ញា និងពិធីសារអន្តរជាតិនានាដែលទាក់ទងនិងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងអនុវត្តកិច្ចការជំនាញពាក់ព័ន្ធសម្រាប់ជាមូលដ្ឋានជូនរាជរដ្ឋាភិបាលក្នុងការបំពេញកាតព្វកិច្ច និងការទទួលខុសត្រូវក្រោមកិច្ចព្រមព្រៀងអនុសញ្ញា និងពិធីសារទាំងនេះ
- រៀបចំរបាយការណ៍ស្តីពីបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជាឱ្យបានទៀងទាត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ។ [20]

[20] អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន លេខ២៣៤, អនក្រ.បក, ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១, មាត្រា៣។

❖ តួនាទី និងភារកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល៖

➢ រៀបចំ និងអនុវត្តនយោបាយឧស្សាហកម្មរបស់រាជរដ្ឋាភិបាល

➢ គ្រប់គ្រង និងផ្សព្វផ្សាយបច្ចេកវិទ្យា និងស្តង់ដារដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

➢ រៀបចំ និងអនុវត្តនយោបាយជាតិលើវិស័យធនធានរ៉ែ ក្នុងការសិក្សាស្រាវជ្រាវរុករកអភិវឌ្ឍន៍ការជីកយកប្រព្រឹត្តកម្ម ការបន្សុទ្ធ និងអាជីវកម្ម

➢ គ្រប់គ្រងអនុវត្តការងារសិក្សាស្រាវជ្រាវ ផ្សព្វផ្សាយទិន្នន័យ ភូតព្ភសាស្ត្រលើកលែងតែអ្វីដែលទាក់ទងនិងប្រេងកាត និងឧស្ម័ន

➢ រៀបចំ និងអនុវត្តនយោបាយជាតិលើវិស័យថាមពល រៀបចំផែនការគោលការណ៍ច្បាប់ និងសហប្រតិបត្តិការជាមួយស្ថាប័ននានា និងជាមួយបរទេស សំដៅអភិវឌ្ឍន៍លើវិស័យថាមពល

➢ សិក្សាស្រាវជ្រាវ ប្រព័ន្ធផ្គត់ផ្គង់ចែកចាយ ស្ថានីយ៍អគ្គិសនី និងវាយតម្លៃសក្តានុពលវារីអគ្គិសនី ដើម្បីរៀបចំអនុវត្តគម្រោងប្រព័ន្ធអគ្គិសនីណា ដែលការផលិតថាមពលអគ្គិសនីជាគោលបំណងចំបង

➢ រៀបចំ និងអនុវត្តនយោបាយផ្គត់ផ្គង់ទឹកស្អាតដល់ទីក្រុង និងទីប្រជុំជន

➢ គ្រប់គ្រង ផ្សព្វផ្សាយ ការងារមាត្រាសាស្ត្រ

➢ ចូលរួមអនុវត្តការងារពាក់ព័ន្ធនិងអាងទន្លេមេគង្គ ស្របតាមភារកិច្ចរបស់ក្រសួង។[21]

❖ តួនាទី និងភារកិច្ចរបស់ក្រសួងអភិវឌ្ឍន៍ជនបទ៖

➢ កំណត់នយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល

➢ លើកទិសដៅ ផែនការរយៈពេលខ្លី មធ្យម វែង លើការងារអភិវឌ្ឍន៍ជនបទដើម្បីកែលម្អស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រជារាស្ត្រជនបទឱ្យកាន់តែល្អប្រសើរឡើង កាត់បន្ថយជាបណ្តើរៗនូវភាពក្រីក្រ និងភាពខុសគ្នារវាងអ្នកជនបទ និងអ្នកទីក្រុង

[21] អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល លេខ៣៥, អនក្រ.បក, ចុះនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩, មាត្រា៣។

- ចូលរួមក្នុងការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិក្នុងវិស័យអភិវឌ្ឍន៍ជនបទ ដោយកម្រិតសកម្មភាពការងារត្រឹមថ្នាក់គ្រួសារ ភូមិ និងឃុំ ក្នុងព្រះរាជាណាចក្រកម្ពុជា
- សិក្សាស្រាវជ្រាវ ប្រមូលផ្ដុំ និងគ្រប់គ្រងទិន្នន័យ ព័ត៌មាន ស្ថិតិ អំពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ
- អភិវឌ្ឍន៍ធនធានមនុស្ស តាមរយៈការបណ្ដុះបណ្ដាលបច្ចេកទេសជំនាញ និងចំណេះដឹងដល់មន្ត្រីបុគ្គលិករាជការរបស់ក្រសួង
- រៀបចំបើកមជ្ឈមណ្ឌលបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈថ្នាក់ភូមិភាគដល់ប្រជារាស្ត្រជនបទតាមការចាំបាច់ និងតាមលទ្ធភាពជាក់ស្តែង
- អប់រំ ផ្សព្វផ្សាយដើម្បីលើកកម្ពស់ផលិតភាព និងប្រាក់ចំណូលប្រចាំគ្រួសាររបស់ប្រជាពលរដ្ឋ ដោយផ្អែកលើការស្រាវជ្រាវបច្ចេកទេសជំនាញអភិវឌ្ឍន៍ជនបទ
- ធ្វើទំនាក់ទំនង សម្របសម្រួល និងសហប្រតិបត្តិការជាមួយបរទេស អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នរដ្ឋ អាជ្ញាធរគ្រប់ជាន់ថ្នាក់ និងផ្នែកឯកជនដែលមានការពាក់ព័ន្ធ ព្រមទាំងប្រជារាស្ត្រមូលដ្ឋាន ដើម្បីធ្វើការអភិវឌ្ឍជនបទប្រកបដោយភាពស្ថិតស្ថេរយូរអង្វែង
- គ្រប់គ្រង ដឹកនាំ និងទទួលខុសត្រូវ ក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍន៍ជនបទចម្រុះ ថ្នាក់គ្រួសារ ភូមិ ឃុំ ដែលរួមមានផ្លូវលំជនបទ ផ្គត់ផ្គង់ទឹកតាមជនបទ ថែទាំសុខភាពបឋម អភិវឌ្ឍន៍សហគមន៍ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ
- ជម្រុញការរៀបចំ និងពង្រីករចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទគ្រប់ជាន់ថ្នាក់ ជាពិសេសគណៈកម្មការអភិវឌ្ឍន៍ជនបទនៅមូលដ្ឋាន។ [22]

❖ តួនាទី និងភារកិច្ចរបស់ក្រសួងអតីតយុទ្ធជន និងយុវនីតិសម្បទា៖

### ក. វិស័យសង្គមកិច្ច

- រៀបចំគោលនយោបាយ និងដឹកនាំ គ្រប់គ្រងរាល់សេវាសង្គមកិច្ចរបស់រដ្ឋ ដើម្បីជួយដល់ប្រភេទជនងាយរងគ្រោះ និងជនក្រីក្រជាអាទិ៍ ជនចាស់ជរាគ្មានទីពឹង ជនពិការ ជនរស់នៅតាមចញ្ចើមផ្លូវថ្នល់

[22] អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍជនបទ លេខ៧៨,អនក្រ.បក, ចុះនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧, មាត្រា៣។

កុមារកំព្រា កុមារតាមចិត្តចញ្ចឹមថ្នល់ ស្ត្រីពេស្យា ជនដែលផ្ទុកមេរោគហ៊ីវ/អេដស៍ មិនមេរោគឆ្លងកាច សាហាវ ជនក្រីក្រ ជួបការលំបាក ជាងគេក្នុងសង្គម

- រៀបចំអនុវត្តគោលនយោបាយ ស្តីពីគ្រួសារ ជនចាស់ជរា
- រៀបចំលិខិតបទដ្ឋាន និងគ្រប់គ្រងការងារ សុំកូនទៅចិញ្ចឹមនៅក្នុង និងក្រៅប្រទេស
- រៀបចំសេវាសង្គមកិច្ច ដើម្បីថែរក្សា ការពារ និងអប់រំ កុមារកំព្រា កុមាររងាយរងគ្រោះដោយអំពើជួញដូរ ដោយជម្ងឺអេដស៍ កុមារពិការ និងចិញ្ចឹមបីបាច់ថែរក្សាទារក ដែលត្រូវគេបោះបង់ចោល
- រៀបចំគោលការណ៍គាំទ្រជនពិការ អនុវត្តការងារស្តារលទ្ធភាពពលកម្ម បង្កលក្ខណៈខាងជីវភាព រស់នៅដល់ជនពិការគ្រប់ប្រភេទ
- សហការជាមួយស្ថាប័នពាក់ព័ន្ធចាត់វិធានការផ្លូវច្បាប់ក្នុងការទប់ស្កាត់អំពើពេស្យាចារ ការជួញដូរមនុស្ស ការរំលោភផ្លូវភេទលើកុមារ ការប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ជួយដល់ជនរងគ្រោះដោយភយន្តរាយផ្សេងៗ មានគ្រោះថ្នាក់ធម្មជាតិ និងគ្រោះថ្នាក់ផ្សេងៗទៀត
- សហការជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្នុងការអនុវត្តសិទ្ធិកុមារ
- គ្រប់គ្រងរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈសម្រាប់មន្ត្រីរាជការតាមការកំណត់ របស់ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់គ្រងរបបធានារ៉ាប់រងសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលដែលកំពុងបំពេញភារកិច្ច
- គ្រប់គ្រងរបបធានារ៉ាប់រងសង្គមដល់កូនកំព្រាពីសពមន្ត្រីរាជការ
- ដឹកនាំ គ្រប់គ្រង និងសហការជាមួយអង្គការក្រៅរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិដែលធ្វើសកម្មភាព លើវិស័យសង្គមកិច្ច ជាអាទិ៍ ការផ្តល់ព័ត៌មាន ការប្រាប់បង្ហាញ ការណែនាំ និងការផ្តល់សេវាសង្គមកិច្ច នានា
- បំផុសការចូលរួមសកម្មភាពសាមគ្គីធម៌សង្គម លើកទឹកចិត្ត និងធ្វើជាដៃគូជាមួយអង្គការមនុស្សធម៌ សហគមន៍មូលដ្ឋានក្នុងការបង្កើតមូលនិធិទ្រទ្រង់ដល់សេវាសង្គមកិច្ចនានាដើម្បីជួយដល់ជនងាយ រងគ្រោះគ្រប់ប្រភេទ ។

### ខ. វិស័យអតីតយុទ្ធជន

- ➢ រៀបចំដាក់ឱ្យដំណើរការ សម្របសម្រួលគោលនយោបាយជាតិ ស្តីពីអតីតយុទ្ធជន
- ➢ រៀបចំបញ្ចូលអតីតយុទ្ធជន និងគ្រួសារទៅក្នុងសហគមន៍ ដោយលើកកម្ពស់ស្ថានភាពរស់នៅឱ្យបានល្អប្រសើរ និងគ្មានការរើសអើង តាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ ការដោះស្រាយការងារធ្វើ និងបង្កើតមុខរបរ
- ➢ លើកគោលការណ៍អប់រំណែនាំ អតីតយុទ្ធជន ឱ្យយល់ពីតម្លៃកាតព្វកិច្ច តួនាទីក្នុងគ្រួសារ សហគមន៍ និងសង្គមដើម្បីទទួលបានការអភិវឌ្ឍ
- ➢ គ្រប់គ្រងរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ សម្រាប់យោធិននៃកងយោពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល កងសេនាជន កងជីវពល ដែលបានបូជាជីវិតដើម្បីប្រទេសជាតិ។

### គ. វិស័យយុវនីតិសម្បទា

- ➢ គ្រប់គ្រងក្មេងពីអាយុ ៧ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ដែលបានប្រព្រឹត្តបទល្មើស ពាលអនាថា អបាយមុខក្នុងទូទាំងប្រទេស និងមានតួនាទីកែប្រែអប់រំ ដើម្បីឱ្យក្លាយទៅជាពលរដ្ឋល្អ
- ➢ បង្កើតមជ្ឈមណ្ឌលទទួលអប់រំកុមារ យុវកុមារតាមការចាំបាច់ ដើម្បីទទួលយកកុមារ យុវកុមារ ដែលបានប្រព្រឹត្តអំពើខុសឆ្គងមកគ្រប់គ្រង អប់រំ និងបណ្តុះបណ្តាល
- ➢ សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ បង្កើតកម្មវិធីក្នុងការអប់រំបណ្តុះបណ្តាលអនីតិជន
- ➢ សហការជាមួយស្ថាប័នពាក់ព័ន្ធ រៀបចំកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់ទណ្ឌិតតាមពន្ធនាគារ
- ➢ កសាងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធទៅនឹងការគ្រប់គ្រងវិស័យយុវនីតិសម្បទា
- ➢ បង្កើត គ្រប់គ្រងមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងសមាហរណកម្មជនរងគ្រោះទាំងនោះទៅក្នុងសហគមន៍។

❖ តួនាទី និងភារកិច្ចរបស់ក្រសួងពាណិជ្ជកម្ម៖[23]

---

[23]អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម លេខ៩១,អនក្រ.បក, ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧,

- រួមចំណែកកសាងគោលនយោបាយពាណិជ្ជកម្ម ដោយឈរលើមូលដ្ឋានច្បាប់ និងបទប្បញ្ញត្តិអន្តរជាតិពិសេសអង្គការពាណិជ្ជពិភពលោក
- កំណត់អំពីសន្និធិទំនិញយុទ្ធសាស្ត្រ
- តាមដានថ្លៃទំនិញ និងដំណើរការទីផ្សារ
- ចលនា និងផ្សព្វផ្សាយការប្រើប្រាស់ដល់អតិថិជន និងចាត់វិធានការការពារផលប្រយោជន៍អ្នកប្រើប្រាស់
- ជួយរកទីផ្សារជូនកសិករ និងពាណិជ្ជករ
- រៀបចំដឹកនាំ និងត្រួតពិនិត្យពាណិជ្ជកម្មក្រៅប្រទេស និងផ្តល់អាជ្ញាប័ណ្ណសម្រាប់ការនាំចេញ នាំចូលទំនិញ តាមការកំណត់របស់រាជរដ្ឋាភិបាល
- អនុវត្តនយោបាយ ដើម្បីអភិវឌ្ឍវិសយឯកជន ធានាសេរីភាព និងការធ្វើពាណិជ្ជកម្មប្រកបដោយសមធម៌
- ចាត់ចែងតាក់តែងច្បាប់ពាណិជ្ជកម្ម បទប្បញ្ញត្តិពាណិជ្ជកម្ម និងគ្រប់គ្រងមជ្ឈមណ្ឌលតម្កល់ឯកសារ និងព័ត៌មានពាណិជ្ជកម្ម
- គាំទ្រ និងឧបត្ថម្ភដល់មជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ជម្រុញវិស័យពាណិជ្ជកម្ម និងវិស័យពាក់ព័ន្ធនឹងពាណិជ្ជកម្ម តាមការរៀបចំអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្មទាំងមូល
- គាំទ្រ និងឧបត្ថម្ភដល់មជ្ឈមណ្ឌលជាតិ នៃមជ្ឈមណ្ឌលតម្កល់ប្រកបដោយសមធម៌
- ចាត់ចែងតាក់តែងច្បាប់ពាណិជ្ជកម្ម បទប្បញ្ញត្តិពាណិជ្ជកម្ម និងគ្រប់គ្រងមជ្ឈមណ្ឌលតម្កល់ឯកសារ និងព័ត៌មានពាណិជ្ជកម្មទាំងមូល
- គ្រប់គ្រង និងរៀបចំដឹកនាំ ការតម្កល់លិខិតជូនដំណឹង នៃប្រតិបត្តិការដែលមានកិច្ចធានា
- រៀបចំ និងគ្រប់គ្រងមជ្ឈមណ្ឌលពិព័រណ៍ពាណិជ្ជកម្មជាតិ ខេត្ត ក្រុង និងតំបន់
- ជម្រុញឱ្យមានតុល្យភាពទំនិញនាំចូល នាំចេញ

---

មាត្រា៣។

- ផ្សព្វផ្សាយ និងធ្វើទំនាក់ទំនងជាមួយទីផ្សារអន្តរជាតិ តាមរយៈការដាក់តំណាងពាណិជ្ជកម្មដើម្បីលើកទិសដៅអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មក្រៅប្រទេស ឈរលើមូលដ្ឋានសេដ្ឋកិច្ចទីផ្សារ
- សិក្សាស្រាវជ្រាវស្ថានភាពសេដ្ឋកិច្ចជាតិ និងអន្តរជាតិ ព្រមទាំងព្យាករណ៍និន្នាការទីផ្សារសម្រាប់ផ្សព្វផ្សាយដល់ផលិតករ និងពាណិជ្ជករ ដើម្បីងាយស្រួលធ្វើជំនួញនៅក្នុង និងក្រៅប្រទេស
- សម្របសម្រួលការងារកម្មសិទ្ធិបញ្ញា គ្រប់គ្រងដោយផ្ទាល់ម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ ការសម្គាល់ភូមិសាស្ត្រទំនិញ និងការការពារព័ត៌មានសម្ងាត់ពាណិជ្ជកម្ម
- ត្រួតពិនិត្យគុណភាព បរិមាណ ទម្ងន់ យថាប្រភេទទំនិញ នាំចេញ នាំចូល
- បង្ក្រាបការក្លែងបន្លំ គុណភាពទំនិញនៅលើទីផ្សារ លើកលែងតែផលិតផលឱសថ បរិក្ខារពេទ្យ និងគ្រឿងសម្អាង
- គ្រប់គ្រង និងអនុវត្តបទប្បញ្ញត្តិនៃប្រព័ន្ធអនុគ្រោះទូទៅ និងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនានា ព្រមទាំងចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ
- ធ្វើអាណាព្យាបាលពាណិជ្ជកម្ម សហគ្រាសជំនួញរបស់រដ្ឋ សហគ្រាសសេដ្ឋកិច្ចចម្រុះរដ្ឋ និងឯកជនដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងពាណិជ្ជកម្ម
- ធ្វើសហប្រតិបត្តិការ និងធ្វើសមាហរណកម្មសេដ្ឋកិច្ចពាណិជ្ជកម្ម ជាមួយសហគ្រាសប្រជាជាតិអាស៊ីអាគ្នេយ៍ដែលហៅកាត់ថា អាស៊ាន និងជាមួយបណ្តាប្រទេសនានា ព្រមទាំងអង្គការអន្តរជាតិនានា
- កាន់កាប់បញ្ជីពាណិជ្ជកម្ម និងគ្រប់គ្រងសមត្ថភាពពាណិជ្ជកម្ម ដូចមានចែងក្នុងច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។[24]

❖ តួនាទី និងភារកិច្ចរបស់ក្រសួងទេសចរណ៍៖

- ដឹកនាំ គ្រប់គ្រង សម្របសម្រួល និងអភិវឌ្ឍន៍លើវិស័យទេសចរណ៍
- កំណត់និងរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ សំដៅគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យទេសចរណ៍ប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រនិងឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ

[24] អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុទ្ធជន និងនីតិសម្បទា លេខ៥៥, អនក្រ.បក, ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥, មាត្រា៣។

- រួមចំណែកការពារ និងថែរក្សាធនធានធម្មជាតិ វប្បធម៌ និងទំនៀមទម្លាប់ដែលជាមូលដ្ឋានបម្រើឱ្យវិស័យទេសចរណ៍
- ទាញយកផលប្រយោជន៍ក្នុងវិស័យទេសចរណ៍ឱ្យបានជាអតិបរមា ធានាការបែងចែកប្រកបដោយសមធម៌ និងប្រកបដោយបរិយាបន្ន និងទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាននៃវិស័យទេសចរណ៍
- ផ្សព្វផ្សាយវិស័យទេសចរណ៍ក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជា
- ចាត់តាំងស្ថានភាពតំណាងទេសចរណ៍នៅក្រៅប្រទេស ដោយសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- គ្រប់គ្រង និងជម្រុញចលនាទេសចរណ៍ក្នុងស្រុក
- លើកកម្ពស់កិច្ចសហប្រតិបត្តិការទូលំទូលាយ រកទីផ្សារ និងជម្រុញការផ្សព្វផ្សាយទេសចរណ៍កម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព ដោយមានការចូលរួមជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន
- អភិវឌ្ឍន៍ផលិតផលទេសចរណ៍ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន
- ពង្រឹង ការអភិវឌ្ឍអេកូទេសចរណ៍ និងសហគមន៍ទេសចរណ៍មូលដ្ឋាន ដោយសហការជាមួយក្រសួងស្ថានប័នពាក់ព័ន្ធ
- អភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ឱ្យសមស្របតាមស្តង់ដារជាតិ និងអន្តរជាតិ អាស៊ានតំបន់ និងពិភពលោក
- គ្រប់គ្រង និងត្រួតពិនិត្យសាលាជំនាញវិជ្ជាជីវៈទេសចរណ៍ និងគ្រឹះស្ថានទេសចរណ៍
- ធានា និងលើកកម្ពស់គុណភាពសេវាកម្មទេសចរណ៍ និងប្រព័ន្ធធានាគុណភាពដោយផ្តល់សន្តិសុខសុវត្ថិភាព ជាសុខភាព និងបង្កើនការពេញចិត្តដល់ទេសចរ
- គ្រប់គ្រងអាជីវកម្មទេសចរណ៍រម្មណីយដ្ឋានទេសចរណ៍ និងសេវាកម្មផ្សេងទៀត ដែលបម្រើឱ្យវិស័យទេសចរណ៍
- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពលើកកម្ពស់ និងជម្រុញចលនាប្រឡងប្រណាំង **«ទីក្រុងស្អាត រម្មណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ»** និងចលនាប្រឡងប្រណាំង ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍

- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិក្នុងវិស័យទេសចរណ៍
- សហការរួមចំណែកការពារបរិស្ថាន និងលើកកម្ពស់ «**កម្ពុជាស្អាត កម្ពុជាបៃតង**»
- សហការជម្រុញការវិនិយោគវិស័យទេសចរណ៍ ស្របតាមផែនការអភិវឌ្ឍជាតិ និងផែនការអភិវឌ្ឍទេសចរណ៍កម្ពុជា
- សហការជាមួយផ្នែកពាក់ព័ន្ធ ក្នុងការដោះស្រាយវិវាទទេសចរណ៍
- សហការគ្រប់គ្រង និងឯកជនភាវូបនីយកម្មនៃសហគ្រាសទេសចរណ៍របស់រដ្ឋ
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការគ្រប់គ្រងដីធ្លីរបស់រដ្ឋ ដែលបានជួលសម្រាប់គោលបំណងទេសចរណ៍
- សហការជាមួយនគរបាលទេសចរណ៍ និងសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធានាសន្តិសុខ សុវត្ថិភាពទេសចរណ៍
- ផ្តល់យោបល់លើផែនការប្រើប្រាស់ដីធ្លី តាមរយៈយន្តការគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយ-កម្មថ្នាក់ជាតិ ថ្នាក់រាជធានី ថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផ្តល់យោបល់លើហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈបម្រើឱ្យវិស័យទេសចរណ៍
- ផ្តល់យោបល់លើការផ្តល់សម្បទានសម្រាប់គោលបំណងទេសចរណ៍
- សហការផ្តល់យោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ លើការកសាងគោលនយោបាយពន្ធដារលើអាជីវកម្មទេសចរណ៍ ទិដ្ឋាការ និងគោលនយោបាយទេសចរណ៍
- រៀបចំនិងអនុវត្ត សម្របសម្រួល និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរនិងផ្នែកឯកជន ក្នុងការអនុវត្តបទប្បញ្ញត្តិ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីនានាពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ដូចមានចែងក្នុងច្បាប់ស្តីពីទេសចរណ៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីរាជរដ្ឋាភិបាល។[25]

[25] អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍ លេខ២៥៨, អនក្រ.បក, ចុះនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦, មាត្រា៥។

# ជំពូកទី២

# ការរៀបចំផែនការអភិវឌ្ឍ និងការអនុវត្តទីក្រុងឈាបកោះ នរា

# ជំពូកទី២

# ការរៀបចំផែនការអភិវឌ្ឍ និងការអនុវត្តទីក្រុងរលាយកោះនរា

## ២.១. នីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីធ្លី

នីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីធ្លីមានគោលបំណងធានាគុណភាព និងប្រសិទ្ធភាពនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌនៅព្រះរាជាណាចក្រកម្ពុជា។ មានគោលដៅកំណត់តាមគោលការណ៍ និងនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

- វាក្យស័ព្ទមួយចំនួនដែលប្រើក្នុងសេចក្ដីសម្រេចខាងលើមានន័យដូចតទៅ៖

- **ប្លង់គោលប្រើប្រាស់ដី** សំដៅដល់ផែនការដែលកំណត់អំពីចក្ខុវិស័យ និងយុទ្ធសាស្ត្រតម្រង់ទិសសម្រាប់ការអភិវឌ្ឍរូបវន្ត និងកំណត់អំពីប្រភេទនៃការប្រើប្រាស់ដី ប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់ ព្រមទាំងបង្ហាញអំពីទម្រង់ បណ្ដាញហេដ្ឋារចនាសម្ព័ន្ធ និងគមនាគមន៍សំខាន់ៗនៃក្រុង ស្រុក ខណ្ឌ និងការធ្វើសមាហរណកម្មក្រុង ស្រុក ខណ្ឌ និងតំបន់ជុំវិញ។ ប្លង់គោលប្រើប្រាស់ដី ត្រូវភ្ជាប់ជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍន៍ និងអភិរក្សក្រុង ស្រុក ខណ្ឌ ទៅតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី មធ្យម និងវែង។ ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ មានចក្ខុវិស័យសម្រាប់រយៈពេល១៥ឆ្នាំ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល៥ឆ្នាំម្ដង។

- **ផែនការប្រើប្រាស់ដី** សំដៅដល់ផែនការលម្អិតចេញពីប្លង់គោលប្រើប្រាស់ដី ដែលកំណត់អំពីប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី និងកំណត់អំពីបទបញ្ញានៃការប្រើប្រាស់ដីជាក់ស្ដែង ការសាងសង់ ការអភិវឌ្ឍ និងការអភិរក្សនៅក្នុងតំបន់នីមួយៗ។ ផែនការប្រើប្រាស់ដីបង្ហាញនូវបណ្ដាញគមនាគមន៍ និងការធ្វើសមាហរណកម្មក្រុង ស្រុក ខណ្ឌ និងតំបន់ជុំវិញ។ ផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌមានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច១៥ឆ្នាំ និងអាចធ្វើការកែសម្រួលរាល់រយៈពេល៥ឆ្នាំម្ដង។

- **ប្លង់លម្អិតនគរូបនីយកម្ម** សំដៅដល់ប្លង់រំលេចទីតាំងនៃតំបន់ណាមួយក្នុងទីក្រុង ឬជាគម្រោងអភិវឌ្ឍន៍ទីក្រុង ដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររូបវន្តលម្អិតនៃការរៀបចំផ្នែក ទីតាំង ឬតំបន់ប្រើប្រាស់ដីណាមួយ ឬច្រើននៃក្រុង ស្រុក ខណ្ឌ ដូចជាការបង្ហាញអំពីការរៀបចំ ការរចនា ទម្រង់ រូបរាង និងសោភណ្ឌភាពនៃរចនាសម្ព័ន្ធរូបវន្តសម្រាប់ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់តាមរយៈគំនូរ ឬរូបសំណាក។

❖ ការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- មានការចូលរួមពីនាក់ពាក់ព័ន្ធ
- ស្របតាមគោលការណ៍វិជ្ជការ និងវិសហជ្ឈការ
- គោរពតាមឋានានុក្រម និងលក្ខខណ្ឌទ្វេទិសនៃរាល់ការសម្រេចចិត្ត
- មានកិច្ចសហការជាមួយគ្រប់សមត្ថកិច្ចជំនាញ និងអាជ្ញាធរដែនដីពាក់ព័ន្ធ
- យកផែនការរូបវន្តក្រុង ស្រុក ខណ្ឌ ជាមូលដ្ឋានបង្អែកសម្រាប់ការអភិវឌ្ឍ ការអភិរក្ស ការអភិវឌ្ឍដី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការសាងសង់គ្រប់ប្រភេទក្នុងក្រុង ស្រុក ខណ្ឌ ព្រមទាំងការធ្វើសមាហរណកម្ម ដើម្បីធ្វើឱ្យការប្រើប្រាស់ដីបានត្រឹមត្រូវ ចំទិសដៅ មានប្រសិទ្ធភាព មានចីរភាព មានតុល្យភាពនិងមានសមធម៌
- រួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុសកល និងលើកកម្ពស់ការអភិវឌ្ឍបៃតង
- ត្រូវយកចិត្តទុកដាក់ដល់សុវត្ថិភាព សុខុមាលភាព និងភាពងាយស្រួលសម្រាប់មនុស្សទាំងអស់គ្នា រួមទាំងជនពិការ ជនចាស់ជរា និងជនងាយរងគ្រោះ។

❖ ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវមានទំហំការងារអប្បបរិមាដូចខាងក្រោម៖

**ក. ការប្រមូលផ្តុំ និងវិភាគទិន្នន័យ៖** ត្រូវប្រមូល និងវិភាគទិន្នន័យរូបវន្ត សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន វប្បធម៌ ប្រជារាស្ត្រ និងការស្រង់មតិ។ល។

**ខ. ការកំណត់ចក្ខុវិស័យ៖** ត្រូវសិក្សា និងកំណត់ចក្ខុវិស័យអភិវឌ្ឍន៍ និងអភិរក្សសម្រាប់រយៈពេលយ៉ាងតិច១៥ឆ្នាំ។

**គ. ការកំណត់យុទ្ធសាស្ត្រ៖** ត្រូវសិក្សា និងកំណត់យុទ្ធសាស្ត្រអភិវឌ្ឍន៍ និងអភិរក្សដើម្បីសម្រេចបាននូវចក្ខុវិស័យមានជាអាទិ៍

- យុទ្ធសាស្ត្រអភិវឌ្ឍន៍ និងអភិរក្ស
- យុទ្ធសាស្ត្រប្រើប្រាស់ដី
- យុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ

- យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច
- យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច
- យុទ្ធសាស្ត្រការពារបរិស្ថាន អភិវឌ្ឍន៍បៃតង និងគ្រប់គ្រងកាកសំណល់
- យុទ្ធសាស្ត្របង្កាទប់ស្កាត់គ្រោះមហន្តរាយ។

**ឃ. គំនូសប្លង់សម្រាប់ប្លង់គោលប្រើប្រាស់ដីមានដូចជាៈ**

**ឃ.១. ប្លង់សម្រាប់ទិន្នន័យស្ថានភាពបច្ចុប្បន្ន**

- ប្លង់បង្ហាញប្លង់ទីតាំង
- ប្លង់បង្ហាញព្រំប្រទល់សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដី
- ប្លង់ដង់ស៊ីតេប្រជាជន
- ប្លង់កំណត់ប្រភេទប្រើប្រាស់ដី
- ប្លង់បង្ហាញផ្លូវថ្នល់ និងគមនាគមន៍ចម្បងៗ
- ប្លង់លំហសាធារណៈ និងផ្ទៃបៃតង
- ប្លង់និន្នាការនៃការរីករបស់ក្រុង ស្រុក ខណ្ឌ
- ប្លង់គ្រប់គ្រងកាកសំណល់រឹង
- ប្លង់គ្រប់គ្រងកាកសំណល់រាវ
- ប្លង់សរុប។

**ឃ.២. ប្លង់អនាគតកាល ស្របតាមចក្ខុវិស័យមានដូចជា**

- ប្លង់បង្ហាញព្រំប្រទល់សម្រាប់ប្លង់គោលរៀបចំប្រើប្រាស់ដី
- ប្លង់ដង់ស៊ីតេប្រជាជន
- ប្លង់បែងចែកប្រភេទប្រើប្រាស់ដី
- ប្លង់បណ្តាញផ្លូវថ្នល់ និងគមនាគមន៍ចម្បងៗ
- ប្លង់លំហសាធារណៈ និងផ្ទៃបៃតង

- ប្លង់គម្រោងពង្រីងក្រុង ស្រុក ខណ្ឌ
- ប្លង់គ្រប់គ្រងកាកសំណល់រឹង
- ប្លង់គ្រប់គ្រងកាកសំណល់រាវ
- ប្លង់សរុប។

**ង. សេចក្តីណែនាំ និងអនុវត្តគ្រប់គ្រងការអភិវឌ្ឍ៖** ត្រូវរៀបចំបញ្ជីគម្រោង និងផែនការសកម្មភាពតាមលំដាប់អាទិភាពសម្រាប់អនុវត្តរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ព្រមទាំងមានសេចក្តីណែនាំសម្រាប់ការអនុវត្ត និងការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងសាងសង់។

**ច. ឯកសារឧបសម្ព័ន្ធ**

**ឆ. ឯកសារទាំងអស់ត្រូវចងក្រងជារបាយការណ៍បច្ចេកទេស**

ការរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវគោរពតាមគោលការណ៍ដូចមានចែងក្នុងសេចក្តីសម្រេចលេខ០៤១ ប្រការ៥។ ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវផ្តួចផ្តើមនិងរៀបចំដោយគណៈកម្មការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ និងសម្របសម្រួលដោយគណៈកម្មការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ។

នីតិវិធីនិងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖

**ជំហានទី១៖** ការផ្សព្វផ្សាយគម្រោង និងការចុះសិក្សាបឋមលើទីតាំង

**ជំហានទី២៖** ការចុះប្រមូលទិន្នន័យ និងព័ត៌មាន

**ជំហានទី៣៖** ការវិភាគទិន្នន័យ និងការរៀបចំសេចក្តីព្រាងចក្ខុវិស័យ និងយុទ្ធសាស្ត្រ

**ជំហានទី៤៖** ការរៀបចំសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី

**ជំហានទី៥៖** ការប្រមូលធាតុចូល និងការកែសម្រួលបឋម

**ជំហានទី៦៖** ការបិទផ្សាយជាសាធារណៈ

**ជំហានទី៧៖** ការកែសម្រួលចុងក្រោយ

**ជំហានទី៨៖** ការរៀបចំគម្រោងអាទិភាព

**ជំហានទី៩៖** ការសម្រេចលើប្លង់គោលប្រើប្រាស់ដី

ក្នុងដំណើរការរៀបចំប្លង់គោលប្រើប្រាស់ដី ត្រូវរៀបចំសិក្ខាសាលានៅ ទីតាំងគម្រោងដើម្បីទទួលធាតុចូលឱ្យបានយ៉ាងតិចបីលើក ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ០៤១។

ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើបច្ចុប្បន្នកម្មដោយត្រូវកត់ត្រាទុកជាប្រចាំនូវស្ថានភាពវិវត្តក្រុង ស្រុក ខណ្ឌ ដើម្បីងាយស្រួលក្នុងការរៀបចំជាសេចក្តីព្រាងសំណើរប្លង់គោលប្រើប្រាស់ដីសម្រាប់ស្នើសុំកែសម្រួលសរុបក្នុងរយៈពេល៥ឆ្នាំម្តង។ ការកែសម្រួលប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមនីតិវិធីដែលមានលក្ខណៈ ដូចដំណើរការប្លង់គោលប្រើប្រាស់ថ្មីដែរ។ ការកែសម្រួលប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ មុនពេលកំណត់នៃរយៈពេល៥ឆ្នាំ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ ឬតម្រូវការចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ប្លង់គោលប្រើប្រាស់ដីដែលត្រូវបានកែសម្រួលរួច ត្រូវស្នើសុំការសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការតាមនីតិវិធីដូចការសម្រេចប្លង់គោលប្រើប្រាស់ដីថ្មីដែរ។ [26]

### ២.១.១. នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី

នៅក្នុងការបង្កើតទីក្រុងណាបមួយ អ្នកដែលមានគម្រោងក្នុងការបង្កើតនោះត្រូវយល់ដឹងពីនីតិវិធីការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លីជាមុនសិន។ ដើម្បីយល់ដឹងអំពីអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ នៃក្រសួងរៀបចំដែន នគរូបនីយកម្ម និងសំណង់ ត្រូវយល់ដឹងអំពីការកំណត់ និងណែនាំបច្ចេកទេសជំនាញ និងទម្រង់បែបបទនៃការសាងសង់ប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ដល់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង។ ដោយអភិបាលខេត្ត ក្រុងត្រូវចេញសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងក្នុងការវិនិច្ឆ័យតាមរបៀបបង្ហាញលើផែនទី ឬតាមរបៀបពិព័រណ៌នា ឬតាមរបៀបទាំងពីរ។

នៅពេលដែលតំបន់បានធ្វើការវិនិច្ឆ័យបានប្រកាសហើយ អភិបាលខេត្ត ក្រុងនៃតំបន់ធ្វើការវិនិច្ឆ័យ ត្រូវតែងតាំងគណៈកម្មការរដ្ឋបាលសម្រាប់តំបន់ដែលត្រូវធ្វើការវិនិច្ឆ័យនោះ។

- ដោយសមាសភាពនៃគណៈកម្មការរដ្ឋបាលមាន៖
  - តំណាងអភិបាលខេត្ត ក្រុង ជាប្រធាន

[26] សេចក្តីសម្រេចស្តីពី នីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ លេខ០៤១, សសរ, ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤, ប្រការ៤, ៥, ៨, ៩, ១០។

- មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ជាមន្ត្រីសុរិយោដី ជាសមាជិក
- មន្ត្រីទទួលខុសត្រូវការងាររដ្ឋបាលសុរិយោដី នៃមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ជាសមាជិក
- អភិបាលស្រុក ខណ្ឌ ឬតំណាង ជាសមាជិក
- មេឃុំ ចៅសង្កាត់ ឬតំណាង ជាសមាជិក
- មេភូមិ ឬតំណាង ជាសមាជិក
- ចាស់ព្រឹទ្ធាចារ្យក្នុងទីតាំងធ្វើការវិនិច្ឆ័យ ២រូប ជាសមាជិក

❖ ភារកិច្ចរបស់គណៈកម្មការរដ្ឋបាលមាន៖

- បិទផ្សាយជាសាធារណៈនូវប្លង់បញ្ជីសុរិយោដី ជាអាទិ៍ ប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដី
- ទទួលរាល់បណ្ដឹងតវ៉ា ធ្វើការស្រាវជ្រាវ និងដោះស្រាយតាមការព្រមព្រៀង
- ធ្វើសេចក្ដីសន្និដ្ឋានផ្ដល់យោបល់លើឯកសារនៃការវិនិច្ឆ័យ
- លើកសំណើផ្ដល់សិទ្ធិលើដីជូនអ្នកកាន់កាប់ ជូនកម្មសិទ្ធិករ ឬរក្សាទុកជាទ្រព្យសម្បត្តិរដ្ឋ។

នៅពេលដែលតំបន់ធ្វើការវិនិច្ឆ័យត្រូវបានកំណត់ហើយ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ព្រមទាំងមន្ត្រីចាំបាច់មួយចំនួនទៀតរួមមាន៖ មន្ត្រីកំណត់ព្រំដី មន្ត្រីវិនិច្ឆ័យ និងមន្ត្រីវាស់វែង ដែលត្រូវបំពេញភារកិច្ចក្នុងតំបន់ធ្វើការវិនិច្ឆ័យ។

មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ដែលបានទទួលសេចក្ដីណែនាំអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រត្រូវទទួលខុសត្រូវចំពោះការវិនិច្ឆ័យដែលបានកំណត់នៅក្នុងអនុក្រឹត្យ។ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យមានសិទ្ធិដឹកនាំចេញសេចក្ដីណែនាំចាំបាច់ដល់មន្ត្រីជំនាញ ដែលបានតែងតាំងក្នុងអនុក្រឹត្យលេខ៤៦ វាក្យខណ្ឌទី១ មាត្រា៤។

មន្ត្រីកំណត់ព្រំដី និងមន្ត្រីវាស់វែងមានសិទ្ធិចូលក្នុងបរិវេណអចលនវត្ថុណាមួយ នៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ ដើម្បីកំណត់ព្រំដី និងវាស់វែង ហើយអាចអញ្ជើញជនដែលពាក់ព័ន្ធឱ្យផ្ដល់នូវចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗដែលទាក់ទងទៅនិងព្រំនៃក្បាលដីណាមួយ។

មន្ត្រីវិនិច្ឆ័យ មានសិទ្ធិសាកសួរយកព័ត៌មានចាំបាច់សម្រាប់អនុវត្តការងារវិនិច្ឆ័យ អាចអញ្ជើញជនដែលពាក់ព័ន្ធឱ្យផ្តល់នូវចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗទាក់ទងទៅនិងការវិនិច្ឆ័យ។ នៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ ជនដែលមានការពាក់ព័ន្ធ មានកាតព្វកិច្ចចូលរួម និងសហការក្នុងការកំណត់ព្រំដី និងការវិនិច្ឆ័យដោយផ្ទាល់នូវចម្លើយដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ឯកសារ ឬភស្តុតាងផ្សេងៗដល់មន្ត្រីជំនាញ ដើម្បីអនុវត្តការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ។ ជនគ្រប់រូបមានសិទ្ធិចូលរួមពិនិត្យ និងផ្តល់យោបល់ ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារ នៃការវិនិច្ឆ័យ និងមានសិទ្ធិសុំឱ្យមន្ត្រីជំនាញពន្យល់បំភ្លឺអំពីខ្លឹមសារ នៃទិន្នន័យដែលពាក់ព័ន្ធនិងតំបន់ធ្វើការវិនិច្ឆ័យ។

អភិបាលខេត្តក្រុង ត្រូវធ្វើលិខិតផ្លូវការដែលពិព័ណ៌នា និងអនុញ្ញាតឱ្យអនុវត្តនីតិវិធីវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ ទៅអាជ្ញាធរមូលដ្ឋាននៃតំបន់ធ្វើការវិនិច្ឆ័យយ៉ាងហោចណាស់១៥ថ្ងៃមុន កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យ។ អភិបាលខេត្តក្រុង ត្រូវជូនដំណឹងជាសាធារណៈ អំពីពេលវេលា និងទីកន្លែងនៃកិច្ចប្រជុំផ្សព្វផ្សាយ។ សេចក្តីជូនដំណឹងត្រូវបិទឱ្យសាធារណៈជនដឹងរយៈពេល៧ថ្ងៃ មុនបើកកិច្ចប្រជុំផ្សព្វផ្សាយ ក្នុងកន្លែងដែលងាយឃើញនៅក្នុងភូមិ ឬនៅទីតាំងធ្វើការវិនិច្ឆ័យផ្ទាល់។ សេចក្តីប្រកាសត្រូវតែផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងមានប្រសិទ្ធិភាពនៅក្នុងទីតាំងធ្វើការវិនិច្ឆ័យ ដោយសហការជាមួយ អាជ្ញាធរមូលដ្ឋាន។ កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ ត្រូវរៀបចំធ្វើនៅទីតាំងធ្វើការវិនិច្ឆ័យ។ ក្នុងកិច្ចប្រជុំនោះមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬតំណាងគណៈកម្មការរដ្ឋបាល ត្រូវពន្យល់ពីដំណើរការនៃការវិនិច្ឆ័យ បំភ្លឺពីបញ្ហាច្បាប់ និងឆ្លើយរាល់សំណួរទាក់ទងនិងការវិនិច្ឆ័យដែលបានលើកឡើង។ កិច្ចប្រជុំបន្ថែមសម្រាប់ថ្នាក់ឃុំត្រូវបានរៀបចំ ប្រសិនបើមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬអាជ្ញាធរមូលដ្ឋានចាត់ទុកថាជាការចាំបាច់។

មន្ត្រីកំណត់ព្រំដីត្រូវជូនដំណឹងដល់ថ្នាក់ដឹកនាំមូលដ្ឋានអំពីការកំណត់ព្រំដីក្នុងតំបន់ ដោយកំណត់ការធ្វើវិនិច្ឆ័យ ពេលវេលា និងទីកន្លែងដែលបានចាប់ផ្តើមធ្វើការវិនិច្ឆ័យឱ្យបានមុន៧ថ្ងៃយ៉ាងតិច។ សេចក្តីជូនដំណឹងតម្រូវឱ្យជនដែលពាក់ព័ន្ធមកចង្អុលបង្ហាញព្រំប្រទល់នៃអចលនវត្ថុរបស់ខ្លួន តាមរបៀបដែលបានបញ្ជាក់ក្នុងសេចក្តីប្រកាសជូនដំណឹង។ បន្ទាប់មក មន្ត្រីកំណត់ព្រំដីដែលបានទទួលការណែនាំពីអ្នកគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវកំណត់ព្រំប្រទល់អចលនវត្ថុទាំងអស់ដែលបង្កើតបានជាក្បាលដីក្នុងប្លង់សុរិយោដី។ ក្នុងរយៈពេលធ្វើការកំណត់ព្រំប្រទល់ក្បាលដី មន្ត្រីកំណត់ព្រំដីត្រូវគោរពគោលការណ៍ដូចខាងក្រោម៖

ក- បើកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលជាប់ព្រំ មានវត្តមានហើយព្រមព្រៀងលើព្រំប្រទល់ នោះព្រំប្រទល់ និងត្រូវបានកំណត់យោងតាមការព្រមព្រៀង។

ខ- បើការព្រមព្រៀងដែលរៀបរាប់ក្នុងចំណុច ក មិនអាចធ្វើទៅបាន ឬមានកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលនៅជាប់ព្រំណាមួយអវត្តមាន នោះព្រំប្រទល់ត្រូវកំណត់នៅលើដី តាមឯកសារដែលមាន និងភស្តុតាងជាលក្ខណៈរូប ជាលាយលក្ខណ៍អក្សរ ឬចម្លើយផ្ទាល់មាត់ទាក់ទង និងព្រំដី។

គ- ចំពោះក្បាលដីដែលមានព្រំប្រទល់ជាប់និងដីសាធារណៈ ឬក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ព្រំប្រទល់ក្បាលដីត្រូវកំណត់ដោយអនុឡោមទៅតាមចំណុច ក ឬ ខ នៃអនុក្រឹត្យលេខ៤៦ វាក្យខណ្ឌទី២ មាត្រា៧។

ឃ- វិវាទទាំងអស់ អំពីព្រំប្រទល់ដែលមិនអាចដោះស្រាយបានក្នុងពេលកំណត់ព្រំដី ត្រូវបញ្ជូនទៅធ្វើការសម្របសម្រួលនិងដោះស្រាយវិវាទតាមអនុក្រឹត្យលេខ៤៦ មាត្រា១២។

មន្ត្រីវាស់វែងដែលទទួលបានការណែនាំពីមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវអនុវត្តការងារវាស់វែងដែលជាតម្រូវការក្នុងការប្រតិបត្តិនីតិវិធីវិនិច្ឆ័យ និងរៀបចំប្លង់សុរិយោដី។ មន្ត្រីវិនិច្ឆ័យដែលបានទទួលការណែនាំពីមន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យ ត្រូវអង្កេតរាល់ឯកសារ ភស្តុតាង និងព័ត៌មានផ្សេងៗជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ទាក់ទងទៅនឹងសិទ្ធិលើក្បាលដីនីមួយៗក្នុងតំបន់ធ្វើការវិនិច្ឆ័យហើយកត់ត្រាសិទ្ធិទាំងនេះ ចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី។

ការរៀបចំឯកសារនៃការវិនិច្ឆ័យមានន័យដូចខាងក្រោម៖

១. ឯកសារនៃការវិនិច្ឆ័យត្រូវមាន៖

- ប្លង់សុរិយោដី
- បញ្ជីឈ្មោះម្ចាស់ដី
- ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី
- ទម្រង់បែបបទនៃការ ប្រមូលទិន្នន័យនីមួយៗត្រូវបានបង្ហាញ៖

**ក. អត្តសញ្ញាណក្បាលដី**

**ខ. អត្តសញ្ញាណម្ចាស់ដី**

**គ. កាលបរិច្ឆេទនៃការវិនិច្ឆ័យ។**

២. ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ត្រូវផ្តិតមេដៃយល់ព្រមពីម្ចាស់ដី ព្រមទាំងអ្នកជាប់ព្រំ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីវិនិច្ឆ័យ។

៣. នៅពេលឯកសារនៃការវិនិច្ឆ័យត្រូវបានបំពេញចប់សព្វគ្រប់ហើយ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យត្រូវចុះហត្ថលេខាលើឯកសារទាំងនេះ។

ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យដែលរួមមាន ប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីត្រូវមានរយៈពេល៣០ថ្ងៃ នៅកន្លែងដែលងាយមើលឃើញសម្រាប់ការអង្កេតជាសាធារណៈនៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ។ អាជ្ញាធរខេត្តក្រុង ត្រូវផ្សាយដំណឹងអំពីការបិទផ្សាយជាសាធារណៈនៅឯកសារនៃការវិនិច្ឆ័យ តាមសំណើរបស់គណៈកម្មការរដ្ឋបាល។ ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនៅឯកសារនៃការវិនិច្ឆ័យ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យអាចកែតម្រូវការខុសឆ្គង ឬការភ្លេចភ្លាំងណាដែលមិនជះឥទ្ធិពល ដល់ផលប្រយោជន៍ត្រឹមត្រូវស្របច្បាប់នៃជនណាមួយ។ ការកែតម្រូវផ្សេងៗក្នុងឯកសារនៃការវិនិច្ឆ័យ អាចធ្វើបានដរាបណាមានការយល់ព្រមពីជនពាក់ព័ន្ធ ដែលទទួលឥទ្ធិពលពីការកែតម្រូវនោះ។

ក្នុងអំឡុងពេលនៃការបិទផ្សាយជាសាធារណៈ ជនណាដែលមានឈ្មោះក្នុងបញ្ជី ឬអ្នកដែលមានផលប្រយោជន៍លើក្បាលដីណាមួយដែលអាចចាត់ទុកថា ឯកសារនៃការវិនិច្ឆ័យជាក់លាក់ ឬមិនពេញលេញ អាចផ្តល់ដំណឹងដល់គណៈកម្មការរដ្ឋបាលនូវការជំទាស់របស់ខ្លួន។ ក្រោយពីផ្តល់នូវការកត់សម្គាល់ដ៏សមហេតុផល ដល់ជនគ្រប់រូបដែលពាក់ព័ន្ធនិងការជំទាស់ និងបន្ទាប់ពីពិគ្រោះជាមួយអ្នកដែលធ្វើការជំទាស់គណៈកម្មការរដ្ឋបាលត្រូវព្យាយាមដោះស្រាយតាមការព្រមព្រៀង។ ការជំទាស់ ឬវិវាទណាមួយដែលមិនអាចដោះស្រាយបាន ត្រូវបញ្ជូនទៅគណៈកម្មសុរិយោដីថ្នាក់ជាតិ ស្របតាមនីតិវិធីដែល និងកំណត់ដោយអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។ ក្រោយពីផុតរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ និងបញ្ចប់ការដោះស្រាយទំនាស់តាមនីតិវិធីដូចមានចែងក្នុង អនុក្រឹត្យលេខ៤៦ មាត្រា១២។

គណៈកម្មការរដ្ឋបាលត្រូវផ្តល់ការយល់ព្រមលើឯកសារនៃការវិនិច្ឆ័យ ចំពោះក្បាលដីទាំងឡាយណាដែលមិនមានទំនាស់។ បន្ទាប់ពីការយល់ព្រម គណៈកម្មការរដ្ឋបាលត្រូវបញ្ជូនឯកសារនៃការវិនិច្ឆ័យទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសុរិយោដី ដើម្បីពិនិត្យលើលក្ខណៈបច្ចេកទេស និងចុះហត្ថលេខាហើយបញ្ជូនទៅអភិបាលខេត្តក្រុងចុះហត្ថលេខា។ ក្រោយពីអភិបាលខេត្តក្រុង និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ចុះហត្ថលេខាហើយឯកសារនៃការវិនិច្ឆ័យ ត្រូវបានបញ្ចប់ជាស្ថាពរចំពោះក្បាលដីដែលមិនមានទំនាស់។ ចំពោះឯកសារនៃការវិនិច្ឆ័យ ដែលនៅពាក់ព័ន្ធនិងវិវាទនិងត្រូវបញ្ចប់ជាស្ថាពរ នៅពេលមានការដោះស្រាយចប់សព្វគ្រប់ដោយគណៈកម្មការសុរិយោដី ឬតុលាការ។ នៅពេលដែលឯកសារនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរ យោងតាម អនុក្រឹត្យលេខ៤៦ វាក្យខណ្ឌទី១ មាត្រា១៤ ឯកសារនៃការវិនិច្ឆ័យ

ព្រមទាំងឯកសារទាំងអស់ ដែលទទួលបានក្នុងអំឡុងពេលនៃការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីដើម្បីចុះបញ្ជី។ ក្រោយពេលក្បាលដីដែលមានក្នុងឯកសារនៃការវិនិច្ឆ័យ ត្រូវបានចុះបញ្ជីហើយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ លើគ្រប់ក្បាលដីនៃតំបន់ធ្វើការវិនិច្ឆ័យនេះ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចប្រគល់សិទ្ធិឱ្យខេត្ត ក្រុងណាដែលមានគ្រប់លក្ខណៈសម្បត្តិ ដើម្បីចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាន់អចលនវត្ថុនេះ នៅក្នុងតំបន់ធ្វើការវិនិច្ឆ័យនៅក្នុងខេត្តក្រុងរបស់ខ្លួន។ ការណែនាំអំពីរបៀបរបបនៃការកាន់កាប់ឯកសារសុរិយោដី និងឯកសារណេបផ្សេងៗនិងកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ [27]

### ២.១.២. ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ

នៅពេលដែលមានការបង្កើតទីក្រុងរណបមួយឡើង ក៏ដូចជាការបង្កើតនូវទីក្រុងនៅតាមតំបន់ផ្សេងទៀត ហើយក្នុងករណីមានវិវាទណាមួយកើតឡើងពាក់ព័ន្ធទៅ និងដីធ្លីនោះគណៈកម្មាការសុរិយោដីមានបេសកកម្មដោះស្រាយវិវាទទាក់ទងនិងអចលនវត្ថុ ដែលមិនទាន់បានចុះបញ្ជី ដែលយើងអាចហៅថា វិវាទដែលកើតមាននៅក្រៅតំបន់វិនិច្ឆ័យ និងវិវាទដែលកើតនៅក្នុងតំបន់វិនិច្ឆ័យ ដែលមិនអាចសម្របសម្រួលបានដោយគណៈកម្មការរដ្ឋបាល។

បន្ទាប់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានកំណត់ទម្រង់បែបបទនៃពាក្យបណ្ដឹង ហើយ នោះគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវចុះបញ្ជី និងបើកសំណុំរឿងនៃរាល់វិវាទដែលបានទទួល។ ហើយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ គឺត្រូវពន្យល់អំពីនីតិវិធីដល់ភាគីវិវាទ និងសាកសួរថាតើគូរវិវាទយល់ព្រមធ្វើការដោះស្រាយសម្របសម្រួលគ្នាតាមនីតិវិធីឬទេ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវស៊ើបអង្កេតលើវិវាទ ដោយការស៊ើបអង្កេតរួមមាន ការបញ្ជាក់អំពីទីតាំងនៃក្បាលដីដែលមានវិវាទ និងភាគីពាក់ព័ន្ធ និងអំពីកម្មវត្ថុនៃវិវាទ និងការប្រមូលឯកសារដែលមានចម្លើយរបស់សាក្សី និងព័ត៌មានទាក់ទង និងក្បាលដីមានវិវាទ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវថតចម្លង និងបញ្ជាក់លើឯកសារចម្លងនោះសម្រាប់ទុកជាសំណុំរឿង និងប្រគល់ច្បាប់ដើមឱ្យភាគីវិវាទ បន្ទាប់មកគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវកសាង និងបញ្ជូនឯកសារស៊ើបអង្កេតទៅក្នុងសំណុំរឿងវិវាទ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវសម្របសម្រួលវិវាទក្រៅពីករណី ដែលមានចែងនៅក្នុងអនុក្រឹត្យលេខ៤៧ មាត្រា១០។

[27] អនុក្រឹត្យ ស្ដីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ៤៦, អនក្រ.បក, ចុះនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០០០, មាត្រា៣, ៤, ៥, ៦, ៧, ៨, ៩, ១០, ១១, ១២, ១៣។

ចំណែកឯកសារសម្របសម្រួលត្រូវតែអនុវត្តតាមការណែនាំរបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ បន្ទាប់ពីការស៊ើបអង្កេត ប្រសិនបើឃើញថាវិវាទមិនត្រូវបានដោះស្រាយដោយសមធម៌នូវថ្នាក់ស្រុក ខណ្ឌ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវបញ្ជូនសំណុំរឿងវិវាទទៅគណៈកម្មការថ្នាក់ខេត្ត ក្រុង តាមការយល់ឃើញផ្ទាល់របស់ប្រធាន ឬតាមសំណើរបស់ភាគីទាំងសងខាង ចំពោះករណីដូចតទៅៈ

- ជនម្នាក់ទាមទារដីច្រើនក្បាល ដែលជាកម្មវត្ថុនៃការប្ដឹងទាមទាររបស់ភាគីតូចតាចមួយចំនួនដែរ
- ភាគីម្ខាងនៃវិវាទ គឺជាអាជ្ញាធរមានឋានៈខ្ពស់
- ករណីមានវិវាទពាក់ព័ន្ធ និងផលប្រយោជន៍របស់ប្រធានគណៈកម្មការថ្នាក់ស្រុក ខណ្ឌ
- វិវាទដែលពាក់ព័ន្ធ និងដីសាធារណៈរបស់រដ្ឋ។[28]

## ២.២. គម្រោងការអាទិភាពក្នុងការអនុវត្ត និងការអភិវឌ្ឍ

ផែនការក្នុងការអនុវត្ត និងអភិវឌ្ឍន៍ ដើម្បីរៀបចំផែនការកសាងអភិវឌ្ឍដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនានា គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវកំណត់អំពីបញ្ហា និងតម្រូវការជាអាទិភាពយ៉ាងពិតប្រាកដរបស់មូលដ្ឋាន និងយុទ្ធសាស្ត្រនានាដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ សំដៅឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋយ៉ាងមានប្រសិទ្ធភាព។

គម្រោងការអាទិភាពក្នុងការអនុវត្ត និងអភិវឌ្ឍន៍ត្រូវផ្អែកតាមគោលការណ៍សំខាន់ៗដូចខាងក្រោមៈ

- ការចែករំលែកព័ត៌មាន
- តម្លាភាព
- សង្គតិភាព និងសុខុដុមនីយកម្ម
- ការចូលរួមពិគ្រោះយោបល់ជាទូទៅ
- ការឆ្លើយតប និងតម្រូវការ
- គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
- ប្រសិទ្ធភាព និងសុក្រឹត្រភាពសេដ្ឋកិច្ច និងសង្គម

[28] អនុក្រឹត្យ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី, លេខ៤៧, អនក្រ.បក, ចុះនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២, ជំពូកទី៣, មាត្រា៥។

- ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន
- ការធានាសមធម៌។

ការសាងសង់ផែនការគម្រោងអាទិភាពក្នុងការអនុវត្ត និងអភិវឌ្ឍន៍ត្រូវបានចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ នូវក្នុងការប្រជុំវិភាគអំពី ការពិនិត្យ និងវិភាគស្ថានភាពសេដ្ឋកិច្ច ដោយផ្តោតលើអាជីវកម្ម កសិកម្ម ឧស្សាហកម្ម គមនាគមន៍ សេវាកម្ម ការវិនិយោគជាដើម។ មិនតែប៉ុណ្ណោះក៏មានការពិនិត្យ និងវិភាគស្ថានភាពសង្គមកិច្ច ដោយផ្តោតលើការងារអប់រំ សុខុមាលភាពយេនឌ័រ ភាពក្រីក្រ សាសនា អន្តោប្រវេសន៍ និងចំណាកស្រុកជាដើម។ ក្នុងនោះគេក៏ពិនិត្យលើ ការវិភាគស្ថានភាពគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំការប្រែប្រួលអាកាសធាតុ ដោយផ្តោតលើការប្រើប្រាស់ដីធ្លី ធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយចម្បងៗ ការប្រែប្រួលអាកាសធាតុជាដើម។ លើសពីនេះគេក៏ពិនិត្យទៅលើ ការវិភាគស្ថានភាពការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ដោយផ្តោតលើអភិបាលកិច្ច ការគ្រប់គ្រងដែនដី ការគ្រប់គ្រងស្ថិតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ការងារព្រំដែន។ល។ [29]

## ២.២.១. ការអនុវត្តប្រព័ន្ធដឹកជញ្ជូន និងអភិវឌ្ឍន៍វិស័យទីក្រុងរណបកោះនរា

ការអនុវត្តប្រព័ន្ធដឹកជញ្ជូន និងអភិវឌ្ឍន៍វិស័យទីក្រុងរណបកោះនរា គឺចង់គ្រប់គ្រងនិងត្រួតពិនិត្យលើរាល់អាជីវកម្ម និងសេវាកម្មទាក់ទងនិងទីភ្នាក់ងារទេសចរណ៍ ដឹកជញ្ជូនទេសចរណ៍និងមគ្គុទ្ទេសក៍ទេសចរណ៍ ដោយរៀបចំបង្កើត និងធ្វើបច្ចុប្បន្នកម្មបទដ្ឋានគតិយុត្ត ប្រព័ន្ធចំណាត់ថ្នាក់ ស្តង់ដាអប្បបរមា និងការអនុវត្តនានាដើម្បីត្រួតពិនិត្យតាមដាន កែលម្អ និងរក្សាគុណភាពសេវាកម្មទីភ្នាក់ងារដឹកជញ្ជូន និងមគ្គុទ្ទេសទេសចរណ៍ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យសមស្របតាមកម្រិតស្តង់ដាជាតិ និងអន្តរជាតិ និងលក្ខខណ្ឌអនុវត្តដ៏ល្អប្រសើរបំផុតនៅក្នុងប្រទេសកម្ពុជា ដោយការគ្រប់គ្រងនេះ ត្រូវតែមានការអនុវត្តជានយោបាយជាតិលើវិស័យសំណង់សាធារណៈទូទៅ ដោយរៀបចំគោលការណ៍ច្បាប់ និងសហការជាមួយស្ថាប័ននានា ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិ។ ដោយមានសមិទ្ធផលថែទាំ គ្រប់គ្រងលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន កំពង់ផែ ផ្លូវដែក ផ្លូវទឹក និងអគាររដ្ឋដែលជាការសហការធានាសន្តិសុខ សុវត្ថិភាព និងសេវាកម្មប្រកបដោយគុណភាព និងភាពពេញចិត្តរបស់ទេសចរណ៍ ដែលបានសហការសិក្សាផលប៉ះពាល់សង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថានដែល បណ្តាលមកពីការធ្វើអាជីវកម្ម ទីភ្នាក់ងារទេសចរណ៍ សេវាកម្មដឹកជញ្ជូន ទេសចរណ៍ និង

[29] ប្រកាសអន្តរក្រសួង ស្តីពីសេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ក្រុង ចុះខែមីនា ឆ្នាំ២០១៧។

មគ្គុទ្ទេសក៍ទេសចរណ៍ ដោយទទួលបានការអនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់អគ្គនាយក គ្រប់គ្រងវិស័យដឹកជញ្ជូន ឧស្សាហកម្ម និងទេសចរណ៍។

រាល់វិស័យដឹកជញ្ជូន គឺបានតាក់តែងបទបញ្ញា និងត្រួតពិនិត្យលើការដឹកជញ្ជូនតាមផ្លូវថ្នល់ ផ្លូវដែក ផ្លូវទឹក និងបានចូលរួមសហការតាក់តែងច្បាប់ បទប្បញ្ញត្តិ បទដ្ឋាននានាដែលពាក់ព័ន្ធនិងសំណង់ ដែលសមិទ្ធផលសំខាន់ៗផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានប្រគល់ឱ្យដែលទទួលបានការសហការជាមួយរដ្ឋលេខាធិការអាកាសចរស៊ីវិល រាល់ការងារសំណង់ផ្លូវអាកាស។[30]

## ២.២.២. ការតម្រង់ទិសក្នុងការអនុវត្តទីក្រុងរណបកោះនរា

ការតម្រង់ទិសក្នុងការអនុវត្តទីក្រុងរណបកោះនរា ពីព្រោះពុំមានប្រទេសណាបានសម្រេចកំណើនសេដ្ឋកិច្ចក្នុងកម្រិតខ្ពស់ ដោយពុំមានការអនុវត្តក្នុងការអភិវឌ្ឍ និងការពង្រីកទីក្រុងឡើយ។ ដោយប្រទេសកម្ពុជាបច្ចុប្បន្នកំពុងស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការអនុវត្ត និងការអភិវឌ្ឍក្នុងការពង្រីកទីក្រុង ដោយមានប្រជាជន២១% ក្នុងចំណោមប្រជាជនទាំងអស់កំពុងរស់នៅក្នុងទីក្រុង។

ត្រឹមឆ្នាំ ២០៥០គេរំពឹងថា ៣០%នៃប្រជាជនទាំងអស់នឹងរស់នៅតាមបណ្តាទីក្រុងរណប។ ពីព្រោះយល់ថាប្រទេសកម្ពុជាគឺមានល្បឿន និងវិសាលភាពនៃការអនុវត្ត និងការអភិវឌ្ឍក្នុងការពង្រីកទីក្រុងរណបទំនងជានិងបន្តមានការកើតឡើងបន្ថែមទៀត។ បន្ថែមពីលើនេះការអនុវត្តវិស័យទីក្រុងរណប គឺពិតជាជួយសម្រួលដល់ទីក្រុងគោលជាខ្លាំងក្នុងការសម្រួលការកកស្ទះនូវចរាចរណ៍ និងកំណើនប្រជាជន ការផ្តល់សេវាជាមូលដ្ឋាន ការផ្តល់ភាពងាយស្រួលពាក់ព័ន្ធ និងវិស័យដឹកជញ្ជូនតាមគ្រប់មធ្យោបាយ បញ្ហាសន្តិសុខសណ្តាប់ធ្នាប់សង្គម បរិស្ថាន និងបង្កលក្ខណៈឱ្យមានការរៀបចំផែនការ ក្នុងការគ្រប់គ្រងកំណើនទីក្រុងគោលឱ្យទាន់ពេលវេលា កុំឱ្យទីក្រុងគោលត្រូវជាប់គាំងក្នុងគន្លងនៃកំណើនដែលពុំមាននិរន្តរភាព។ល។

លើសពីនេះក្នុងការតម្រង់ទិសអនុវត្តទីក្រុងរណប ក៏មានការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទីក្រុងប្រកបដោយចីរភាព ដើម្បីឆ្លើយតបចំពោះតម្រូវការរបស់ទីក្រុងគោលផងដែរ ពីព្រោះទីក្រុងរណបបានបង្កើតនូវបរិយាកាសដែលអាចបង្កើនភាពអាចរស់នៅបាន និងមានភាពប្រកួតប្រជែង ការវិនិយោគតាមវិស័យលើហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានក្នុងទីក្រុងរណប ក៏អាចធ្វើឱ្យបានកាន់តែប្រសើរ ប្រសិនបើមានការតម្រង់ទិសដោយប្លង់គោលដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ មួយវិញទៀត ក៏បានធានាឱ្យមានការអនុវត្ត និងការអភិវឌ្ឍក្នុងការពង្រីកទីក្រុងរណបប្រកបដោយបរិយាបន្ន ដោយពុំមានវិសមភាពក្នុងទីក្រុងរណបបង្កការគំរាមកំហែងដល់

[30] ដកស្រង់ចេញពី គេហទំព័រ https://coj.gov.kh ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២៣។

និរន្តរភាពទេ និងមិនអាចធ្វើឱ្យមានការបែកបាក់ និងជម្លោះក្នុងសង្គមឡើយ។ ចំណែកឯចក្ខុវិស័យបរិយាបន្ន រួមមានទាំងទំហំវិសាលភាព ផ្នែកសេដ្ឋកិច្ច ភូមិសាស្ត្រ និងសង្គមដែលអាចជួយការពារទប់ទល់ទៅ និងហានិភ័យទាំងឡាយ។ [31]

### ២.២.៣. ចក្ខុវិស័យសម្រាប់ការអភិវឌ្ឍ

ចក្ខុវិស័យក្នុងការរៀបចំទីក្រុងរណប គឺមានគោលបំណងក្នុងការគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍន៍តាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាន និងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខុដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។ ក្នុងន័យនេះអ្នកដែលទទួលបន្ទុករៀបចំការអភិវឌ្ឍទីក្រុងរណប ត្រូវគោរពទៅតាមគោលនយោបាយជាតិរៀបចំដែនដីគប្បីបញ្ចៀសឱ្យបាននូវការខ្វែងគំនិតយោបល់គ្នា ដោយត្រូវគោរពទៅតាមឋានានុក្រមនៃផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយត្រូវមានបញ្ញត្តិកំណត់ជាក់លាក់នូវមុខងារនៃដីក្នុងទីតាំងនីមួយៗ និងការប្រើប្រាស់ដី។

ចក្ខុវិស័យនេះមានគោលបំណង និងគោលដៅដូចជា៖

#### ក. គោលបំណង

- ធានាការប្រើប្រាស់ដី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព ចីរភាព និងសមធម៌ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ការធានាសន្តិសុខស្បៀង កិច្ចការការពារជាតិ និងលំនឹងធម្មជាតិ។
- តម្រង់ទិសដល់ការអភិវឌ្ឍជាតិឱ្យមានតុល្យភាព នូវទូទាំងប្រទេសលើផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សង្គម សេដ្ឋកិច្ច និងបរិស្ថាន និងមានភាពងាយស្រួលដល់ការទាក់ទងពីតំបន់មួយទៅតំបន់មួយទៀតនៅក្នុងប្រទេស ក្នុងតំបន់ និងអន្តរជាតិ។
- សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងគោលនយោបាយតាមវិស័យដើម្បី សម្រេចគោលដៅអភិវឌ្ឍន៍ជាតិ។

#### ខ. គោលដៅ

- អភិវឌ្ឍន៍ប្រកបដោយចីរភាព ដោយធានាបាននូវការផ្គត់ផ្គង់សេចក្តីត្រូវការ និងការទទួលខុសត្រូវចំពោះផលប្រយោជន៍របស់មនុស្សបច្ចុប្បន្ន និងមនុស្សជំនាន់ក្រោយ។

---

[31] ដកស្រង់ចេញពី គេហទំព័រ https://propertyarea.asia ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣។

- គ្រប់គ្រង ការពារ ប្រើប្រាស់ និងអភិវឌ្ឍន៍ធនធានធម្មជាតិដោយកំណត់ឱ្យបានច្បាស់លាស់ជាមុន នៅទីតាំង ឬតំបន់ដែលប្រើប្រាស់សម្រាប់ការអភិវឌ្ឍ។
- រក្សានូវការប្រើប្រាស់ដីធ្លី សម្រាប់រយៈពេលវែង ដើម្បីឱ្យមានតុល្យភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថាន។
- ប្រើប្រាស់នូវសក្តានុពលជាអំណោយផលធម្មជាតិនៃដី និងជាសេចក្តីត្រូវការនៃការអភិវឌ្ឍ និងធ្វើឱ្យប្រសើរនូវលក្ខណៈភូមិសាស្ត្រពិសេសដោយឡែកៗ តាមបរិបទនៃតំបន់នីមួយៗនៅក្នុងប្រទេស
- លើកកម្ពស់កម្រិតជីវភាពប្រជាជនឱ្យកាន់តែប្រសើរឡើង និងកាត់បន្ថយអតិបរិមានូវគម្លាតរវាងតំបន់ផ្សេងៗទូទាំងប្រទេស។
- ធានាការប្រើប្រាស់ ការអភិវឌ្ឍ និងការគ្រប់គ្រងដីតាមផែនការរៀបចំដែនដី និងផែនការប្រើប្រាស់ដីប្រកបដោយសមធម៌ សមភាពយេនឌ័រ ព្រមទាំងការពារនិងគាំទ្រដល់ជីវភាពរស់នៅ របស់សហគមន៍ជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះ។
- រៀបចំបន្ទាការគ្រប់គ្រងការអភិវឌ្ឍ និងការការពារតំបន់នីមួយៗ ឱ្យស្របទៅនិងលក្ខខណ្ឌ និងកត្តាតម្រូវនៃការរៀបចំដែនដីទូទាំងប្រទេស ដោយពិចារណាអំពីលក្ខខណ្ឌ និងកត្តាតម្រូវនៃតំបន់ជាក់លាក់នីមួយៗ ដើម្បីឱ្យផែនការរៀបចំដែនដីនោះអាចអនុវត្តទៅបានដោយរលូន។
- ទប់ស្កាត់ និងកាត់បន្ថយនូវហានិភ័យនៃគ្រោះធម្មជាតិ ដែលបណ្តាលមកពីគម្រោងផែនការ អភិវឌ្ឍ។

ដើម្បីសម្រេចបាននូវគោលបំណង និងគោលដៅខាងលើក្នុងការរៀបចំដែនដី ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ការចូលរួមស្របតាមលទ្ធិប្រជាធិបតេយ្យ និងតម្លាភាព
- ភាពស្របច្បាប់ ដើម្បីធានាបាននូវយុត្តិធម៌ និងការគោរពសិទ្ធិមនុស្ស
- គោលការណ៍វិជ្ជការ និងវិសហមជ្ឈការ
- ការលើកកម្ពស់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិដែលធនធាន ឬសមត្ថភាពនូវមានកម្រិត
- អភិបាលកិច្ចល្អក្នុងដំណើរការក្នុងការធ្វើផែនការ និងលើកកម្ពស់ការស្រុះស្រួលគ្នា

- ភាពឯកភាពគ្នាលើឋានានុក្រមនៃផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងវិធីសាស្ត្រនៃការធ្វើផែនការ
- ការគោរពលក្ខណៈទ្វេទិស ពីក្រោមទៅលើ ពីលើមកក្រោមនៃរាល់ការសម្រេចចិត្ត
- ការធ្វើសមាហរណកម្មគ្រប់ថ្នាក់ គ្រប់វិស័យ និងតំបន់ភូមិសាស្ត្រដែលមានទំនាក់ទំនង និងគ្នា
- រក្សាតុល្យភាពនៃការអភិវឌ្ឍ នៃការបែងចែកផលដែលទទួលបានដល់គ្រប់តំបន់
- ការផ្តល់អាទិភាពលើផែនការអភិវឌ្ឍតំបន់ងាយរងគ្រោះ ជាពិសេសតំបន់ដែលនឹងអាចរងគ្រោះ និងនៅក្បែរនោះឱ្យទាន់ពេលវេលា និងដោយប្រុងប្រយ័ត្ន
- ការរក្សាតុល្យភាពនៃការប្តេជ្ញាចិត្ត និងភាពបត់បែននៃគោលនយោបាយ និង
- ការប្រើប្រាស់ផែនទីដែលមានទិន្នន័យយោងជាមួយឯកភាពគ្នា។[32]

[32] អនុក្រឹត្យ ស្តីពីការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ, លេខ១៨១, អនក្រ.បក។

# ជំពូកទី៣

# គោលនយោបាយ និងសកម្មភាព
# អាទិភាពក្នុងការអភិវឌ្ឍទីក្រុង
# ឈរលើកោះនរា

# ជំពូកទី៣

# គោលនយោបាយ និងសកម្មភាពអាទិភាពក្នុងការអភិវឌ្ឍទីក្រុងរណបកោះនរា

## ៣.១. លិខិតអនុញ្ញាតសាងសង់

ក្នុងការសាងសង់អចលនវត្ថុនៅលើដីណាមួយបាន លុះត្រាតែកម្មសិទ្ធិករនៃដី ជាកម្មសិទ្ធិករនៃការកាន់កាប់ដីស្របច្បាប់ ទើបអាចអនុញ្ញាតឱ្យសាងសង់សំណង់នៅលើដីនោះបាន ដោយការសាងសង់ គឺមិនអាចអនុញ្ញាតនៅលើដីដែលកំពុងមានវិវាទអំពីសិទ្ធិកាន់កាប់ដីបានឡើយ។ ប្រសិនបើការងារសាងសង់ក្នុងស្ថានភាពអាសន្ន ឬគ្រោះមហន្តរាយដើម្បីជួយសង្គ្រោះ ឬការពារអាយុជីវិត ឬបង្ការមិនឱ្យមានការប៉ះពាល់ ឬខូចខាតធ្ងន់ធ្ងរដល់សុខភាព ឬទ្រព្យសម្បត្តិក្នុងភាពអាសន្ន គឺមិនតម្រូវឱ្យមានលិខិតអនុញ្ញាតជាមុនឡើយ ទោះបីការងារសាងសង់នោះអនុវត្តនៅលើដីដែលកំពុងមានវិវាទអំពីសិទ្ធិកាន់កាប់ក៏ដោយ ក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្ន ឬគ្រោះមហន្តរាយត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលត្រូវបានសាងសង់ក្នុងស្ថានភាពអាសន្ន ឬគ្រោះមហន្តរាយ ត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់តាមលក្ខខណ្ឌតាមនីតិវិធីជាធរមាន។

សំណង់ដែលការងារសាងសង់មិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ មានដូចខាងក្រោមៈ

- សំណង់អាគារផ្ទាល់ដីដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ ១២ ម៉ែត្រក្រឡា និងមានកម្ពស់ទាបជាងឬស្មើ ៥ម៉ែត្រ
- លំនៅឋានធ្វើពីឈើ ផ្ទះថ្មក្រោមឈើលើដោយមានកម្រាលខណ្ឌធ្វើពីឈើ ផ្ទះត្រៀមធ្វើពីឈើឬថ្មនៅទីជនបទ ឬស្រែចម្ការដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាង ឬស្មើ ១០០ម៉ែត្រក្រឡា មានកម្ពស់ទាបជាង ឬស្មើ ៩ម៉ែត្រ និងមិននៅក្នុងតំបន់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌ តំបន់អភិរក្ស ឬតំបន់ការពារ
- សំណង់មិនមែនបេតុង ដែលសាងសង់ផ្ទាល់ដី សម្រាប់ប្រើប្រាស់ជាបណ្តោះអាសន្នមានជាអាទិ៍ បង្គោល ដងទង់ វេទិកា រោង តូប ឬគ្រឿងផ្គុំដទៃទៀតសម្រាប់ប្រារព្ធពិធីផ្សេងៗ
- សំណង់នៅក្នុងបរិវេណវត្តអារាមនៃព្រះពុទ្ធសាសនាដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាង ឬស្មើ ២០ម៉ែត្រក្រឡា និងមានកម្ពស់ទាបជាងឬស្មើ ១២ម៉ែត្រ
- របងដែលមិនធ្វើអំពីថ្មបេតុង។

ចំពោះការងារកែប្រែដែលមិនប៉ះពាល់ដល់រចនាសម្ព័ន្ធទ្របន្ទុកគ្រឿងផ្គុំសំណង់ និងសោភណភាពខាងក្រៅ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ មិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ឡើយជាអាទិ៍៖

- ការប្តូរពណ៌ផ្នែកខាងក្នុង
- ការប្តូរទ្រង់ទ្រាយផ្នែកខាងក្នុងនៃសំណង់ ដូចជាបង្កាន់ដៃសុវត្ថិភាព ពិតានដែលមិនធ្វើពីបេតុងដែក ជញ្ជាំងខណ្ឌបន្ទប់ដែលមិនទ្របន្ទុក
- ការប្តូរមុខងារសមាសភាពសំណង់ដែលមិនបង្កើនបន្ទុកលើគ្រឿងផ្គុំសំណង់និងក្នុងគោលដៅមិនមែនអាជីវកម្ម។

មុននឹងធ្វើការសាងសង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ ម្ចាស់សំណង់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនទៅមេឃុំ ឬចៅសង្កាត់នៃទីតាំងដែលសំណង់នោះស្ថិតនៅ។ ចំពោះបែបបទ និងនីតិវិធីនៃការជូនដំណឹងជាមុនអំពីការងារសាងសង់ដែល មិនតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ រីឯសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវធ្វើជាភាសាខ្មែរ និងត្រូវមានភ្ជាប់ឯកសារបញ្ជាក់អំពីកម្មសិទ្ធិកាន់កាប់ស្របច្បាប់នៃដីដែលសំណង់តាំងនៅ សាលាកបត្រក្បាលដី គម្រោងប្លង់ស្ថាបត្យកម្មនិងឯកសារបច្ចេកទេសផ្សេងទៀតសម្រាប់បម្រើឱ្យការសាងសង់ ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលយ៉ាងយូរ៤៥ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញបង្កាន់ដៃទទួលពាក្យស្នើសុំនោះ។ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលយ៉ាងយូរ២៥ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានីខេត្ត ចេញបង្កាន់ដៃទទួលពាក្យស្នើសុំនោះ។ ចំពោះអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលយ៉ាងយូរ១៥ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលការិយាល័យច្រកចេញចូលតែមួយ នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចេញបង្កាន់ដៃទទួលពាក្យស្នើសុំនោះ។

លិខិតអនុញ្ញាតសាងសង់ អស់សុពលភាពក្នុងករណីដែលការដ្ឋានសំណង់ មិនបានចាប់ផ្តើមដំណើរការក្នុងរយៈពេល១ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតសាងសង់នោះ។ ក្នុងករណីម្ចាស់សំណង់បានទទួលលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ រយៈពេលនៃសុពលភាពលិខិតអនុញ្ញាតសាងសង់ ត្រូវចាប់ផ្តើមរាប់ឡើង

វិញគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតបើកការដ្ឋានសំណង់នោះ ដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីអាចបាន បន្តនូវសុពលភាពលិខិតអនុញ្ញាតសាងសង់បានតែមួយដងគត់។

លក្ខខណ្ឌនៃការបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់មានដូចខាងក្រោម៖

- ការស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ត្រូវបានផ្ញើមកអាជ្ញាធរមានសមត្ថកិច្ចតាមរយៈយន្តការច្រកចេញចូលតែមួយ ក្នុងរយៈពេល៣០ថ្ងៃមុនថ្ងៃផុតសុពលភាពលិខិតអនុញ្ញាតសាងសង់
- គ្មានការកែប្រែគម្រោងប្លង់ស្ថាបត្យកម្មដើមនៃលិខិតអនុញ្ញាតសាងសង់
- មិនទាន់មានការចាប់ផ្តើមមានការសាងសង់នូវការបើកការដ្ឋានសំណង់។

រយៈពេលសម្រាប់សម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់។ បែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។ បែបបទនិងបរិបថនៃការផ្តល់លិខិតសាងសង់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រោយការពិគ្រោះយោបល់របស់ក្រសួងមហាផ្ទៃ។[33]

### ៣.១.១. យុទ្ធសាស្ត្រអភិវឌ្ឍន៍

យុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងរណប គឺចង់រក្សាតុល្យភាពរវាងការពង្រីកទីក្រុងគោលទៅលើតំបន់ជនបទនិន្នាការនៃការពង្រីកទីក្រុងដែលពុំមានផែនការច្បាស់លាស់ត្រូវតែបញ្ឈប់។ ការពង្រីកទីក្រុងរណបត្រូវតែមានទស្សនាទាននៃការធ្វើសមាហរណកម្មទីក្រុងគោល និងជនបទដើម្បីកាត់បន្ថយអតុល្យភាពនៃសក្តានុពលដែលមានរួចហើយ។ សម្រាប់តំបន់ទីក្រុងគោលដែលបានរៀបចំជាមជ្ឈមណ្ឌលរដ្ឋបាល ការស្នាក់នៅ ការផលិត និងសេវាកម្មត្រូវគិតគូរដោះស្រាយទំនោរនៃភាពកកស្ទះ និងពង្រីកលទ្ធភាពនៃការអភិវឌ្ឍ តាមរយៈការបង្កើតទីក្រុងរណបដែលមានបណ្តាញគមនាគមន៍ផ្សារភ្ជាប់គ្នា។ ចំពោះតំបន់ជនបទគួរតែត្រូវបានរក្សាលំនឹង និងអភិវឌ្ឍន៍សក្តានុពលរបស់ខ្លួន ដើម្បីពង្រឹងឱ្យមានភាពឯករាជ្យភាព ជាតំបន់ស្នាក់នៅ តំបន់សម្បទានដីសង្គមកិច្ច និងសម្បទានដីសេដ្ឋកិច្ច។ ការធ្វើវិមជ្ឈការផែនការរៀបចំដីរួមទាំងសេវាកម្មត្រូវបានពង្រីក និងពង្រឹងដើម្បីកសាងសមត្ថភាពស្ថាប័នគ្រប់គ្រងក្នុងមូលដ្ឋាន និងប្រើប្រាស់ឱ្យមានប្រសិទ្ធភាពនូវតំបន់ដែលបានអភិវឌ្ឍន៍នានា។

[33] អនុក្រឹត្យស្តីពី លិខិតអនុញ្ញាតសាងសង់, លេខ២២៤, អនក្រ.បក, ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០, មាត្រា១៣, ១៤, ១៥, ១៦, ១៧, ១៨, ១៩, ២០, ២១។

យុទ្ធសាស្ត្រនៃការអភិវឌ្ឍទីក្រុងរណបនៅប្រទេសកម្ពុជាធ្វើឡើង ដើម្បីធានាបាននូវចីរភាព សមធម៌ តុល្យភាព និងការធ្វើសមាហរណកម្មទាំងក្នុងប្រទេស ក្នុងតំបន់ ដោយធានានូវការផ្គត់ផ្គង់ ការរៀបចំដែនដីត្រូវធ្វើទៅតាមលំដាប់នៃអាទិភាពចំពោះតំបន់ដែលមានកំណើនប្រជាជន និងសេដ្ឋកិច្ចខ្ពស់មានជាអាទិ៍។ ដោយថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ-សង្កាត់ដែលមានយុទ្ធសាស្ត្រក្នុងការរៀបចំ និងផែនការប្រើប្រាស់ដីជាអ្នកទទួលខុសត្រូវដោយផ្ទាល់ទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ មុខងារ និងភារកិច្ចជាមូលដ្ឋានមួយចំនួនដែលឃុំមិនអាចធ្វើបាន ត្រូវផ្តល់ការទទួលខុសត្រូវនូវកម្រិតរដ្ឋបាលនៅថ្នាក់ខ្ពស់ជាង ដែលជាតំបន់ស្នូលដោយត្រូវបន្សុីរវាងតំបន់ស្នូល និងតំបន់ទ្រនាបដែលនៅជុំវិញ និងត្រូវភ្ជាប់គ្នាដោយបណ្តាញគមនាគមន៍ដែលជាអាទិ៍នៃការអភិវឌ្ឍ។ ក្នុងការអភិវឌ្ឍទីក្រុងរណប ក៏ត្រូវពិចារណាលើទិដ្ឋភាពសមធម៌សង្គម ដូចជាតម្រូវការខាងលំនៅដ្ឋានសមស្រប និងមានតុល្យភាពរវាងលទ្ធភាពដែលគ្រួសារក្រីក្រ និងអ្នកមានប្រាក់ចំណូលទាប អាចរកបានលំនៅដ្ឋានសមរម្យ និងតម្រូវការសេដ្ឋកិច្ចរបស់រដ្ឋ និងផ្នែកឯកជន។ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងរណបក្រៅពីផ្តល់ការងារធ្វើ ត្រូវគិតគូរជាអាទិភាពដល់ការរៀបចំកន្លែងសម្រាកលំហែសាធារណៈ ធានាបាននូវការរស់នៅប្រកបដោយគុណភាព សុវត្ថិភាព បរិស្ថានល្អ និងសោភណ្ឌភាព ព្រមទាំងការកំណត់តំបន់គ្រប់គ្រងពិសេសសម្រាប់រៀបចំខ្សែក្រវ៉ាត់បៃតងនៃទីក្រុង។

យុទ្ធសាស្ត្រនេះក៏ត្រូវរៀបចំឱ្យមានរចនាសម្ព័ន្ធសេដ្ឋកិច្ចមួយប្រកបដោយតុល្យភាព ដែលអាចធានាបាននូវការអភិវឌ្ឍរយៈពេលវែង ក្នុងបរិបថនៃសកលភាវូបនីយកម្ម និងដើម្បីផ្តល់នូវកាលានុវត្តភាពសម្រាប់ការបណ្តុះបណ្តាល និងការងារធ្វើដល់ប្រជាពលរដ្ឋ។ គោលបំណងសំខាន់ដើម្បីជៀងវាងចលនាបំលាស់ទីរបស់ប្រជាពលរដ្ឋ ក្នុងការស្វែងរកការងារដែលនៅឆ្ងាយពីលំនៅដ្ឋាន។ ដូច្នេះការកសាងផែនការអភិវឌ្ឍ សេដ្ឋកិច្ច ត្រូវផ្សារភ្ជាប់និងការអភិវឌ្ឍលំនៅឋាន ដើម្បីកាត់បន្ថយការចំណាយលើការធ្វើដំណើរ និងរួមចំណែកកាត់បន្ថយគម្លាតពីតំបន់មួយទៅតំបន់មួយទៀត។ វិធានការសំខាន់ៗផ្នែកសេដ្ឋកិច្ច គឺការប្រើប្រាស់សក្តានុពលនៃប្រភេទធនធានធម្មជាតិផ្សេងៗ ដើម្បីបម្រើដល់ការអភិវឌ្ឍវិស័យរ៉ែ ឧស្សាហកម្ម ថាមពល ពាណិជ្ជកម្ម ធុរកិច្ច សេដ្ឋកិច្ចជាតិ និងទេសចរណ៍។ លក្ខខណ្ឌសមស្របក្នុងការធ្វើអាជីវកម្មលើធនធានប្រេង ឧស្ម័នធម្មជាតិ និងធនធានរ៉ែផ្សេងៗទៀតត្រូវគ្រប់គ្រងឱ្យមាននិរន្តភាព។ ម៉្យាងវិញទៀតដើម្បីឆ្លើយតបទៅនិងតម្រូវការជាមូលដ្ឋានរបស់មនុស្ស ចាំបាច់ត្រូវពិចារណាលើទិដ្ឋភាពទាំងឡាយមានជាអាទិ៍ កន្លែងលំហែកាយ ឬកម្សាន្ត កន្លែងសម្រាប់លេងកីឡា ទីកន្លែងសាធារណៈ លំហបៃតង ជាសួននិងឧទ្យាន មជ្ឈមណ្ឌលវប្បធម៌និងសាសនា ការផ្តល់សុខុមាលភាពដល់មនុស្សគ្រប់វ័យ (កុមារ យុវជន ស្ត្រី បុរស មនុស្សចាស់ ជនពិការ) ឱ្យមានលទ្ធភាពទទួលបាននូវសេវាសុខភាព សេវាអប់រំ។ល។ ទាំងអស់នេះជាប្រការចាំបាច់ដើម្បីផ្តល់នូវការកសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយនិរន្តភាព។

បន្ថែមពីនោះទៀត គេក៏ផ្តោតសំខាន់ទៅលើបរិស្ថានអំណោយផលល្អ គឺជាការរួមចំណែកធានាដល់ជីវិតរស់នៅរបស់មនុស្សជាតិ។ ដូច្នេះចាំបាច់ត្រូវតែការពារធម្មជាតិនៃប្រព័ន្ធជីវៈចម្រុះ និងទេសភាពធម្មជាតិ ជាពិសេសតំបន់ធម្មជាតិសំខាន់ៗ។ បច្ចុប្បន្នធនធានធម្មជាតិកំពុងប្រឈមនិងហានិភ័យ និងការបាត់បង់ដែលបង្កឡើងដោយកត្តាជាច្រើនមានជាអាទិ៍ ភាពក្រីក្រ និងចំណាកស្រុករបស់ប្រជាពលរដ្ឋដែលចាំបាច់ត្រូវជៀសវាង ឬមានវិធានការទប់ស្កាត់។ ដូចនេះធនធានធម្មជាតិដូចជាទឹក ដី ពពួកសត្វ និងរុក្ខជាតិ ព្រមទាំងធនធានព្រៃឈើត្រូវគ្រប់គ្រងឱ្យបានត្រឹមត្រូវ និងសមស្របតាមគោលការណ៍នៃកិច្ចការពារបរិស្ថាន។ ចំពោះដីកសិកម្ម និងដី ព្រៃឈើជាប្រភពចម្បងសម្រាប់ផលិតកម្មដំណាំស្បៀង ដំណាំកសិ-ឧស្សាហកម្ម និងសម្រាប់រក្សានូវបរិស្ថាន ធម្មជាតិ ដែលតម្រូវឱ្យមានការកំណត់និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព តាមរយៈការរៀបចំឱ្យមានបែបបទគតិយុត្តលើការប្រើប្រាស់ អភិរក្ស ការពារ អភិវឌ្ឍន៍ប្រកបដោយចីរភាព។ ដូច្នេះត្រូវធ្វើការពិនិត្យកែលម្អលើការប្រើប្រាស់ដីកសិកម្ម ដីព្រៃឈើ និងជលផលឱ្យបានសមស្របក្នុងគោលដៅបង្កើនការវិនិយោគលើវិស័យកសិកម្ម សមស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះក៏ត្រូវរៀបចំឱ្យមានឧស្សាហកម្មរ៉ែ និងថាមពលដែលមិនប៉ះពាល់ ឬអាចមានផលប៉ះពាល់បរិស្ថានតិចបំផុត។

លើសពីនេះប្រសិទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស គឺជាលក្ខខណ្ឌតម្រូវចាំបាច់មួយសម្រាប់ជីវិតសេដ្ឋកិច្ច និងសង្គម និងការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាព និងមុខងារនៃការរៀបចំដែនដី។ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនប្រព័ន្ធព័ត៌មាន និងទំនាក់ទំនងព្រមទាំងការផ្គត់ផ្គង់ថាមពលអគ្គិសនី ទឹកស្អាត និងទូរគមនាគមន៍ត្រូវតែពង្រឹង និងកែលម្អតាមរយៈការស្តារនីតិសម្បទា និងការសាងសង់ឡើងវិញ ជាពិសេសត្រូវធានាថាប្រជាពលរដ្ឋនៅតាមតំបន់ជនបទ អាចទទួលបាននូវសេវាផ្គត់ផ្គង់ចរន្តអគ្គិសនី ទូរគមនាគមន៍ សេវាសុខភាពសាធារណៈ និងគុណភាពទឹកស្អាត ព្រមទាំងប្រព័ន្ធអនាម័យត្រឹមត្រូវ។ ដូច្នេះវិធានការនៃការរៀបចំត្រូវតែគិតគូរជាពិសេសដល់ការអភិវឌ្ឍវិស័យថាមពល និងវិស័យគមនាគមន៍ តាមរយៈការស្តារ និងការសាងសង់រោងចក្រអគ្គិសនី និងបណ្តាញផ្លូវគមនាគមន៍ទូទាំងប្រទេស។[34]

## ៣.១.២. ការអភិវឌ្ឍលើវិស័យដីធ្លី

ការអភិវឌ្ឍវិស័យដីធ្លី សំដៅដល់ការរៀបចំដីតាមរយៈការប្តូរប្រភេទនៃការប្រើប្រាស់ដី ការប្តូរមុខងារតំបន់ប្រើប្រាស់ដី ការធ្វើសមាហរណកម្មក្បាលដី ការពង្រួមក្បាលដី ការបំបែកក្បាលដី ក្នុងគោលបំណងកែប្រែរចនាសម្ព័ន្ធនៃដី ឬការបង្កើនដង់ស៊ីតេនៃការប្រើប្រាស់ដីសម្រាប់គោលដៅ នៃការសាងសង់លំនៅឋាន អគារ

[34] គោលនយោបាយជាតិស្តីពី ការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា, បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១១។

ពាណិជ្ជកម្ម សេវាកម្ម ឬឧស្សាហកម្មដោយធានានូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី។

ការអភិវឌ្ឍដីធ្លីត្រូវមានលិខិតអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីធានាបាននូវភាពត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសរៀបចំដែនដី និងនគរូបនីយកម្ម និងជាគ្រឹះនៃភាពស្របច្បាប់នៅក្នុងការអនុវត្តគម្រោងអភិវឌ្ឍដីធ្លី។ ម្យ៉ាងវិញទៀត ការអភិវឌ្ឍដីធ្លីគឺមានគោលបំណងពាណិជ្ជកម្ម សេវាកម្ម និងឧស្សាហកម្ម ត្រូវមានលិខិតអនុញ្ញាតអភិវឌ្ឍន៍ដី ទោះបីគម្រោងនេះស្ថិតនៅក្នុងតំបន់ជនបទដាច់ស្រយាល ឬតំបន់ឆ្ងាយពីផ្លូវជាតិ ផ្លូវដែក តំបន់រម្មណីយដ្ឋានទេសចរណ៍ ឬតំបន់បេតិកភណ្ឌជាតិក៏ដោយ។ ក៏ប៉ុន្តែការអភិវឌ្ឍដីធ្លីក្នុងតំបន់កសិកម្មសម្រាប់សាងសង់លំនៅឋានលក្ខណៈគ្រួសារ សាងសង់រោងចក្រ ក្នុងទីតាំងដីសម្បទានសេដ្ឋកិច្ច និងសាងសង់រោងសិប្បកម្ម ឬរោងចក្រសម្រាប់គោលដៅកសិកម្ម មិនតម្រូវឱ្យមានលិខិតអនុញ្ញាតអភិវឌ្ឍន៍ដីធ្លីទេ លើកលែងតែតំបន់ណាដែលមានបទដ្ឋានគតិយុត្តដោយឡែក។

ការរៀបចំផែនការប្រើប្រាស់ដី និងការអភិវឌ្ឍរួមមាន៖

- គោលបំណង និងគោលដៅនៃការអភិវឌ្ឍ និងការប្រើប្រាស់ដីធ្លី
- ទិសដៅក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងគម្រោង និងការធ្វើសមាហរណកម្មទៅក្នុងតំបន់
- គំនូសប្លង់ប្រើប្រាស់ដីដោយកំណត់អំពី ទំហំដីឡូត៍ បណ្តាញផ្លូវ បណ្តាញទឹកស្អាត បណ្តាញអគ្គិសនី អាងប្រព្រឹត្តកម្មទឹកកខ្វក់ ក្បាលបំពង់ទឹក និងប្រព័ន្ធពន្លត់អគ្គីភ័យ ប្រព័ន្ធលូ សួនច្បារ លំហសាធារណៈ ផ្ទៃ បៃតង និងការដាំដើមឈើ
- តារាងសង្ខេបពិពណ៌នាអំពីគំនូសប្លង់ប្រើប្រាស់ដី។

ត្រូវរៀបចំគម្រោងពេលវេលា អនុវត្តសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែងត្រូវរៀបចំផែនការថវិកាសម្រាប់អនុវត្តគម្រោងស្របតាមផែនការសកម្មភាព និងពេលវេលា។ [35]

### ៣.១.៣. ការអភិវឌ្ឍលំនៅឋាន

ការអភិវឌ្ឍទៅលើលំនៅឋាន គឺជាការរៀបចំហេដ្ឋារចនាសម្ព័ន្ធឱ្យកាន់តែល្អប្រសើរ ប្រកបដោយភាពទទួលខុសត្រូវរបស់ម្ចាស់គម្រោងទទួលសាងសង់ ដោយគេសង្កេតឃើញថាម្ចាស់គម្រោងសាងសង់តែងតែបានរៀបចំនូវទឹក ភ្លើង ជាពិសេសផ្លូវតភ្ជាប់ពីផ្លូវធំ ទៅកាន់ទីតាំងនៃគម្រោងលំនៅឋាននោះតែម្តង ដែលធ្វើឱ្យប្រជា

[35] ប្រកាសស្តីពី ការអភិវឌ្ឍដី, លេខ០៨៧, ចុះនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨។

ពលរដ្ឋរស់នៅជាមួយបរិយាកាសមួយដ៏ថ្មី ដែលទទួលបានការគិតគូរយ៉ាងល្អិតល្អន់។ ពីព្រោះការអភិវឌ្ឍលំនៅឋាននៅក្នុងក៏មានទីក្រុងរណបកោះនា ដែលមិនមែនគ្រាន់តែអភិវឌ្ឍន៍លំនៅឋានហើយលក់ជូនអតិថិជននោះទេ តែក៏បានគិតគូរទៅដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ទីក្រុងរណបកោះនរា និងប្រជាពលរដ្ឋដែលរស់នៅក្រៅតំបន់ទីក្រុងរណបកោះនរាផងដែរ។ ការអភិវឌ្ឍលំនៅឋាន វាក៏ទទួលបានការទាក់ទាញដល់ការវិនិយោគ ពីសំណាក់វិនិយោគិនលើលំនៅឋាននេះដែរ។[36]

### ៣.១.៤. ការអភិវឌ្ឍលើវិស័យទឹកស្អាត

ការអភិវឌ្ឍវិស័យទឹកស្អាត គឺជាការកំណត់នៃការប្រើប្រាស់ដីដើម្បីតម្លើង ឬសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ត្រូវគោរពតាមបទបញ្ញត្តិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។ ដើម្បីជាផលប្រយោជន៍សាធារណៈ ប្រតិបត្តិករអាចទទួលបានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិស្របច្បាប់លើទីតាំងដែលត្រូវធ្វើការរៀបចំតម្លើង សាងសង់ ឬជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។ ប្រតិបត្តិករត្រូវខិតខំដោះស្រាយតាមរយៈការចរចា សម្របសម្រួលជាមួយម្ចាស់កម្មសិទ្ធិ ដោយទូទាត់សំណងសមរម្យ និងយុត្តិធម៌ ដើម្បីមានសិទ្ធិចូល សិទ្ធិឆ្លងកាត់ និងប្រើប្រាស់ដីសម្រាប់តម្លើង សាងសង់ ឬជួសជុលទឹកស្អាត។ ក្នុងករណីដែលមិនអាចទទួលបានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ប្រតិបត្តិករ ត្រូវស្នើសុំអាជ្ញាធរមានសមត្ថកិច្ចដើម្បីដោះស្រាយបញ្ហានេះ ដើម្បីជាប្រយោជន៍សាធារណៈ។ [37]

### ៣.១.៥. ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ភ្ញៀវទេសចរណ៍ និងប្រជាជន

ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ភ្ញៀវទេសចរណ៍ និងប្រជាជន គឺជាការបង្កើតប្រសិទ្ធភាពនៃការគ្រប់គ្រងវិស័យទីក្រុងរណប ក៏ដូចជាកិត្តិនាមកម្ពុជាដើម្បីធ្វើឱ្យទេសចរណ៍ទីផ្សារគោលដៅ អាទិភាពកាន់ តែស្គាល់ កាន់តែឃើញជាវិជ្ជមាន កាន់តែទទួលស្គាល់កម្ពុជាជាគោលដៅទេសចរណ៍សកលឈានមុខ។ បន្ថែមពីនោះវាក៏ជួយបង្កើតប្រសិទ្ធភាពម នៃការផ្សព្វផ្សាយទាក់ទាញទេសចរណ៍កម្ពុជា ទៅកាន់ទីផ្សារទេសចរណ៍សំខាន់ៗដើម្បីធ្វើឱ្យទេសចរណ៍នៃទីផ្សារគោលដៅអាទិភាព និងពិភពលោកចាប់អារម្មណ៍មកទស្សនា។ ប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងនៃការធ្វើដំណើរការរបស់ភ្ញៀវ និងហេដ្ឋារចនាសម្ព័ន្ធផ្ទៃក្នុងដើម្បីសម្រួលការធ្វើដំណើរស្របតាមស្តង់ដារអន្តរជាតិ។

---

[36] ដកស្រង់ចេញពី គេហទំព័រ https://propertyarea.asia ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣។

[37] ច្បាប់ស្តីពី ការគ្រប់គ្រងទឹកស្អាត, ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០២៣។

លើសពីនេះទៅទៀតវាក៏ជួយបង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍផលិតផលទេសចរណ៍ប្រកបដោយ នវានុវត្តន៍ ភាពច្នៃប្រឌិត និងភាពជាខ្មែរដោយផ្អែកលើបេតិកភណ្ឌវប្បធម៌ បេតិកភណ្ឌធម្មជាតិ ប្រជាជនខ្មែរ ភាពជាខ្មែរ និងពង្រឹងសេវាទេសចរណ៍ សេវាស្តង់ដាមួយតាមរយៈការដាក់ចេញ និងការអនុវត្តស្តង់ដារបៃតងសម្រាប់ផលិតផល និងសេវាទេសចរណ៍ទាំងលើកម្រិតថ្នាក់ជាតិ និងតំបន់អាស៊ានដើម្បីបង្កើតច្រករបៀងទេសចរណ៍។ ដោយបង្កើតការអភិវឌ្ឍធនធានគោលដៅទេសចរណ៍ អភិវឌ្ឍតំបន់ទេសចរណ៍ ជម្រុញការវិនិយោគនៅតាមតំបន់ទេសចរណ៍។

បន្ថែមពីនេះក៏បានចូលរួមអភិវឌ្ឍន៍រចនាសម្ព័ន្ធស្ថាប័ន និងពង្រឹងអភិបាលកិច្ចទេសចរណ៍ ដែលរាប់ទាំងការគិតគូរដល់ការបង្កើតក្រុមប្រឹក្សាជាតិទេសចរណ៍ និងការពង្រឹងអង្គភាពអាទិភាព គ្រប់គ្រងគោលដៅទេសចរណ៍តាមរាជធានី ខេត្ត និងគោលដៅទេសចរណ៍សំខាន់ៗដោយបង្កើនកិច្ចសហការភាពជាដៃគូររវាងរដ្ឋនិងឯកជន និងកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធនានា។ ការអភិវឌ្ឍបរិវត្តកម្មឌីជីថលក្នុងវិស័យទេសចរណ៍ ដោយត្រូវមានផែនការនឹងធនធានច្បាស់លាស់ស្របទៅតាមដំណាក់កាលឌីជីថលនីយកម្ម(DIGITIZATION) និងឌីជីថលលូបនីយកម្ម(DIGITALIZATION) និងបរិវត្តកម្មឌីជីថល (DIGITAL TRANSFORMATION)។ ក៏ដូចជាជួយអភិវឌ្ឍន៍ធនធានមនុស្ស ដោយផ្តោតសំខាន់លើការអប់រំបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ ឆន្ទៈមនសិការ គុណធម៌ និងសីលធម៌សម្រាប់បុគ្គលិកនិយោជិត និយោជក និងមន្ត្រីរាជការ ព្រមទាំងភាគីពាក់ព័ន្ធនិងវិស័យទេសចរណ៍ឱ្យស្របតាមតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ធ្វើយ៉ាងណាធានាបានថាបុគ្គលិកម្នាក់មានជំនាញមួយ ជាពិសេសបណ្តុះបណ្តាលអ្នកជំនាញវិជ្ជាជីវៈទេសចរណ៍ស្របតាមស្តង់ដារអាស៊ាន ព្រមទាំងលើកកម្ពស់សុខុមាលភាពមន្ត្រីទេសចរណ៍ប្រកបដោយសមធម៌ និងបរិយាបន្ន។ [38]

### ៣.១.៦. ការធ្វើឱ្យទីក្រុងរណបកាន់តែមាននិរន្តរភាពខាងបរិស្ថាន

ការធ្វើឱ្យទីក្រុងរណបកាន់តែមាននិរន្តរភាពខាងបរិស្ថាន គឺជាកិច្ចការពារបរិស្ថានមួយ ក៏ដូចជាយុទ្ធសាស្ត្រថ្មីសម្រាប់ការរីកចម្រើននៃឧស្សាហកម្ម ដើម្បីការពារនិងកែលម្អប្រព័ន្ធអេកូបរិស្ថាន ជម្រុញដល់ការអភិវឌ្ឍបៃតង ផ្តល់ការគាំទ្រដ៏សំខាន់ និងពាក់ព័ន្ធយ៉ាងជិតស្និតលើសុខុមាលភាពសាធារណៈ។ ចាប់តាំងពីវិស័យទីក្រុងរណបចូលមកប្រទេសកម្ពុជាធ្វើការអភិវឌ្ឍគ្រប់វិស័យមក គេបានដាក់ការការពារបរិស្ថានជាបទបញ្ហាមួយក្នុងការអភិវឌ្ឍគម្រោងនានា ស្របតាមលក្ខខណ្ឌក្នុងស្រុក ជាគោលការណ៍នៃការកម្រិតធំបំផុតលើតំបន់អេកូឡូស៊ីដែលត្រូវរក្សាទុក ដោយវិស័យទីក្រុងរណបបានយកចិត្តទុកដាក់លើការស្ថាបនាហេដ្ឋារចនា

[38] ដកស្រង់ចេញពី គេហទំព័រ https://tourism.gov.kh ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣។

សម្ព័ន្ធបរិស្ថានជាខ្លាំង ដោយបានសាងសង់ហេដ្ឋារចនាសម្ព័ន្ធចម្រុះទឹកកខ្វក់ ទីតាំងចាត់ចែងសម្រាម និងការគ្រប់គ្រងសម្លេងរំខាន។ មិនតែប៉ុណ្ណោះ ទីក្រុងរណបបានធ្វើការផ្អែកតាមសណ្ឋានដី និងធនធានធម្មជាតិ បានធ្វើការរចនាផែនការមេ ថែរក្សាធម្មជាតិក្នុងតំបន់ផងដែរ។ វិស័យទីក្រុងរណបក៏បានធ្វើការអភិវឌ្ឍសាងសង់ ដោយធ្វើការរក្សាទុកសណ្ឋានដីអេកូឡូស៊ីឱ្យបានច្រើនបំផុត កែលំអផែនការគម្រោងដោយរក្សាព្រៃឈើ និងខិតខំដាំព្រៃឈើ និងប្រព័ន្ធអេកូឡូស៊ីធម្មជាតិ។ ដោយមានការកំណត់ពេលរៀបចំថែរក្សាបរិស្ថានធម្មជាតិ និងបង្កើតទិសដៅអេកូទេសចរណ៍ផ្សេងៗ។

វិស័យទីក្រុងរណបបានបណ្តាក់ទុនលើគ្រប់ផ្នែកនៃការសាងសង់ ក្នុងកិច្ចព្រមព្រៀងសុទ្ធតែមានបញ្ជាក់ច្បាស់ពីលក្ខខណ្ឌថៃទាំបរិស្ថាន ហើយភាគីសហប្រតិបត្តិការចាំបាច់ត្រូវតែគោរពតាមបទប្បញ្ញត្តិនីតិវិធីថែរក្សាបរិស្ថានទាំងអស់របស់ព្រះរាជាណាចក្រកម្ពុជា ដោយធ្វើការសាងសង់ក្រោមការបំពេញតម្រូវការបទដ្ឋាននិងនីតិវិធីការពារបរិស្ថាន និងបរិស្ថានលើបន្ទុកសេដ្ឋកិច្ច បន្ទុកច្បាប់បញ្ញត្តិ បន្ទុកគោលការណ៍ បន្ទុកសប្បុរសធម៌ និងការបង្កើតការងារជម្រុញដល់ការអភិវឌ្ឍសង្គម ក៏បានជម្រុញដល់ការការពារបរិស្ថានក្នុងពេលបច្ចុប្បន្ន ការសន្សំ-សំចៃថាមពល ការកាត់បន្ថយការបញ្ចេញកាកសំណល់ ការធ្វើប្រព័ន្ធបៃតង និងការអភិវឌ្ឍប្រសិទ្ធភាពកាបូនទាបផងដែរ។

ក្នុងអំឡុងពេលសាងសង់គម្រោងអភិវឌ្ឍទីក្រុងរណបកោះនរា គឺទាមទារនូវគម្រោងរចនាបែបអេកូឡូស៊ី ការស្តាបនាបៃតង ការប្រើប្រាស់ឡើងវិញ បច្ចេកទេសសន្សំថាមពល រក្សាបរិស្ថានឥតឈប់ឈរដែរ។ ហើយក្នុងការកាត់បន្ថយការផលិតនិងការប្រើប្រាស់ធនធានថាមពល ផ្គត់ផ្គង់ធនធានប្រើប្រាស់ដែលមានប្រសិទ្ធភាព បង្កើនការច្នៃប្រឌិតលើបច្ចេកទេសរក្សាបរិស្ថានបៃតង បន្តកែលម្អនិងផ្សព្វផ្សាយវប្បធម៌ផលិតតាមបទដ្ឋាន និងអនុវត្តទំនួលខុសត្រូវ នូវភារកិច្ចរបស់ក្រុមហ៊ុនផ្ទាល់។ [39]

## ៣.២. ការងារសន្តិសុខ និង សណ្តាប់ធ្នាប់សង្គម

ការងារសន្តិសុខ ត្រូវមានការអនុវត្តគ្រប់វិធានការ ពុះពាររាល់ការលំបាកស្មុគស្មាញ ដោយធានាបានថាតំបន់ទីក្រុងរណបគឺមានសុខសុវត្ថិភាព សភាពការណ៍សន្តិសុខ គឺគ្មានអំពើប្លន់ប្រដាប់អាវុធ ក្មេងទំនើង និងគ្រឿងញៀន ដោយម្ចាស់គម្រោងអភិវឌ្ឍន៍ត្រូវតែទទួលយកចិត្តទុកដាក់ក្នុងការដាក់បង្ក្រាបបានជាបន្តបន្ទាប់ ផ្តល់នូវភាពកកក្តៅដល់ប្រជាជន វិនិយោគិន និងភ្ញៀវទេសចរណ៍។ ដោយសន្តិសុខសណ្តាប់ធ្នាប់ និងសភាពការណ៍ល្អ បានផ្តល់នូវភាពអនុគ្រោះដល់ការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងការយុទ្ធ

[39] ដកស្រង់ចេញពី គេហទំព័រ https://openjicareport.jica.go.jp ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣។

សាស្ត្របញ្ចុកោណរបស់រាជរដ្ឋាភិបាលឱ្យទទួលបានជោគជ័យពិសេស ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ថ្នល់ លូ ស្ពាន សួនច្បារ សំណង់អគារខ្ពស់ៗ ដោយទីក្រុងរណបបានចូលរួមយ៉ាងសកម្មក្នុងការជម្រុញកំណើន សេដ្ឋកិច្ចជាតិ កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន។

ចំណែកឯសណ្តាប់ធ្នាប់សង្គម ម្ចាស់គម្រោងអភិវឌ្ឍន៍ទីក្រុងរណប បានរឹតបន្តឹងយ៉ាងតឹងរឹងទៅលើ សណ្តាប់ធ្នាប់តាមដងផ្លូវ មធ្យោបាយយានជំនិះ និងប្រជាជន និងបញ្ហាលំនៅឋានបរិស្ថានផ្សេងៗទៀតដែលគេ បានខិតខំរៀបចំឱ្យមានសណ្តាប់ធ្នាប់កាន់តែល្អប្រសើរ។ [40]

## ៣.៣. បញ្ហាប្រឈម និងដំណោះស្រាយ

ជាទូទៅ មានកំណើនយ៉ាងលឿននៃប្រជាជនក្នុងការមកលេង មករស់នៅ និងប្រកបអាជីវកម្មនៅក្នុង ទីក្រុងរណប ធ្វើឱ្យការបង្កើតទីក្រុងរណបមាន**បញ្ហាប្រឈម**មួយចំនួនដូចជា៖

- ការកកស្ទះចរាចរណ៍នៅក្នុងទីក្រុងរណប
- ធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ
- ផលប៉ះពាល់បរិស្ថានអវិជ្ជមាន
- និងកង្វះនគរូបនីយកម្ម។

### ដំណោះស្រាយ

- **ការកកស្ទះចរាចរណ៍នៅក្នុងទីក្រុងរណប** [41]
  - ធ្វើការណែនាំឱ្យក្រុមហ៊ុនសាងសង់ ធ្វើការបង្រួមរបងហ៊ុំព័ទ្ធការដ្ឋានឱ្យបានតូចបំផុត តាមលទ្ធ ភាពដែលអាចធ្វើបាន ដើម្បីទប់លំហូរចរាចរណ៍បានធំ។
  - ម្ចាស់អភិវឌ្ឍន៍ទីក្រុងរណបត្រូវតែស្នើសុំអាជ្ញាធរពាក់ព័ន្ធ ដោយត្រូវបន្ថែមកម្លាំងសមត្ថកិច្ចប្រចាំការ ដើម្បីជួយសម្រួលការដោះស្រាយបញ្ហាកកស្ទះចរាចរណ៍នូវពេលចរាចរណ៍មមាញឹក។
  - ធ្វើការអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋ ដែលកំពុងតែប្រើប្រាស់ចញ្ចើមផ្លូវ សម្រាប់ធ្វើការតាំងលក់ ក្នុងការបម្រើឱ្យអាជីវកម្មលក់ដូររបស់ខ្លួន ត្រូវបញ្ឈប់ការប្រើប្រាស់ចញ្ចើមផ្លូវទាំងនោះ។ ចំណែកឯ បងប្អូនប្រជាពលរដ្ឋអ្នកទិញទំនិញ មិនត្រូវឈប់ចតលើទ្រូវផ្លូវឡើយ ហើយសមត្ថកិច្ចនិងធ្វើការចុះ

---

[40] ដកស្រង់ចេញពី គេហទំព័រ https://kohsantepheapdaily.com.kh ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣។

[41] ដកស្រង់ចេញពី គេហទំព័រ https://freshnewasia.com ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣។

រៀបចំសណ្តាប់ធ្នាប់ ដោយចាត់វិធានការរដ្ឋបាលចំពោះអ្នកដែលនៅតែប្រើប្រាស់ចញ្ចើមផ្លូវសម្រាប់លក់ដូរ។

❖ **ធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ**

- ពង្រឹងវិធានការការពារ ទប់ស្កាត់ និងអភិរក្សធនធានទឹកតាមរយៈការពង្រឹងការគ្រប់គ្រង និងថែរក្សាអាងទន្លេ ស្ទឹង បឹងបួរ ព្រែក ប្រព័ន្ធធារាសាស្ត្រ និងផ្លូវទឹកធម្មជាតិ ដោយរៀបចំឱ្យបានច្បាស់លាស់នូវផែនទីកំណត់តំបន់គ្រប់គ្រង និងប្រើប្រាស់ទឹក ព្រមទាំងបន្តការអនុវត្តវិធីសាស្ត្រគ្រប់គ្រងធនធានទឹកចម្រុះ ដើម្បីធានាចីរភាពនៃធនធានទឹក។
- បន្តអភិវឌ្ឍន៍ និងជម្រុញការធ្វើទំនើបកម្មប្រព័ន្ធធារាសាស្ត្រ និងសំណង់សិល្បការទឹក តាមរយៈការបង្កើនទុនវិនិយោគសាធារណៈ ការទាក់ទាញជំនួយពីដៃគូអភិវឌ្ឍ និងការចូលរួមពីវិស័យឯកជន ក្នុងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ ការស្រាវជ្រាវ និងការប្រើប្រាស់បច្ចេកទេសវិទ្យាថ្មីៗ។
- បន្តស្តារជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រជាប្រចាំដើម្បីរក្សាបាននូវអត្ថិភាព និងចីរភាពនៃការផ្គត់ផ្គង់ទឹក និងបំពេញតម្រូវការនៃការប្រើប្រាស់ប្រចាំថ្ងៃ។
- បន្តជម្រុញលើកទឹកចិត្តក្នុងការចូលរួមទទួលខុសត្រូវលើការគ្រប់គ្រង ការប្រើប្រាស់ និងការថែទាំប្រព័ន្ធធារាសាស្ត្រនោះ។
- បន្តធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានជលសាស្ត្រ ឧត្តុនិយមព្យាករអាកាសធាតុ និងផ្តល់ព័ត៌មានធាតុអាកាសបានទាន់ហេតុការណ៍ ជាពិសេសព័ត៌មានស្តីពីបាតុភូតគ្រោះមហន្តរាយធម្មជាតិ ដែលអាចកើតមានឡើងដូចជា គ្រោះទឹកជំនន់ ខ្យល់ព្យុះ រាំងស្ងួត និងរលកកម្តៅដល់ប្រជាជនឱ្យប្រុងប្រយ័ត្ន និងចាត់វិធានការត្រៀមបង្ការ បញ្ចៀស ឆ្លើយតបទាន់ពេលនិងកាត់បន្ថយផលប៉ះពាល់។

❖ **ផលប៉ះពាល់បរិស្ថានអវិជ្ជមាន**

- កាត់បន្ថយការបំពុលបរិស្ថាន ដោយបន្តពង្រឹងការគ្រប់គ្រងកាកសំណល់ទីប្រជុំជន ប្លាស្ទិច និងសំណល់គ្រោះថ្នាក់ ធ្វើការត្រួតពិនិត្យការបំពុលទឹក ខ្យល់ និងសម្លេង ព្រមទាំងបន្តជម្រុញថាមពលស្អាត ប្រសិទ្ធិភាពថាមពល ការដឹកជញ្ជូនបៃតង ដំណើរការឧស្សាហកម្មស្អាត ការអនុវត្តសេដ្ឋកិច្ចចក្រាយន្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន វិញ្ញាបនកម្មបៃតង និងប្រតិបត្តិមេត្រីភាពបរិស្ថាន។
- បន្តលើកកម្ពស់ការអប់រំផ្សព្វផ្សាយអំពីបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ដោយបង្កើនមធ្យោបាយផ្សព្វផ្សាយនវានុវត្តន៍ និងជម្រុញការចូលរួមពីដៃគូ ដើម្បីលើកម្ពស់ការយល់ដឹង និងការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋចំពោះបរិស្ថាន។

- បន្តពង្រឹងរដ្ឋបាលទំនើប ពង្រីកហិរញ្ញវត្ថុប្រកបដោយចីរភាព និងកែលម្អក្របខណ្ឌគោលនយោបាយ ដើម្បីឆ្លើយតបនិងបញ្ហាប្រឈម និងនិន្នាការបរិស្ថាន តាមរយៈការធ្វើឱ្យប្រសើរឡើងនូវយន្តការស្ថាប័នមូលដ្ឋានសម្ភារៈបច្ចេកទេស ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ក្នុងនោះរួមមាន ការជម្រុញការចូលរួមចំណែកពីបណ្តាប្រភពហិរញ្ញប្បទានពាក់ព័ន្ធនិងបរិស្ថាន ដូចជាមូលបត្របៃតង ឥណទានកាបូន និងការទូទាត់ថ្លៃសេវាប្រព័ន្ធអេកូឡូស៊ីជាដើម។
- លើកកម្ពស់ការទូតបៃតង ដោយបន្តចូលរួមជាមួយសហគមន៍ប្រជាជាតិ ក្នុងការអនុវត្តកាតព្វកិច្ចអន្តរជាតិពាក់ព័ន្ធ និងបរិស្ថាន រួមចំណែកដោះស្រាយបញ្ហាបរិស្ថានសកល និងជម្រុញរបៀបវារៈបៃតង ការប្រែប្រួលអាកាសធាតុ អព្យាក្រឹត្យកាបូន ទីផ្សារកាបូន និងហិរញ្ញប្បទានអាកាសធាតុ សំដៅលើកស្ទួយកិត្យានុភាពរបស់កម្ពុជាលើឆាកអន្តរជាតិ និងទាញយកឧត្តមប្រយោជន៍ជូនជាតិមាតុភូមិ។

❖ **និងកង្វះនគរូបនីយកម្ម**

- បន្តពង្រឹងការកសាងផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីជាពិសេសនៅតាមតំបន់អាទិភាព ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាពក្នុងវិស័យនគរូបនីយកម្ម។
- បន្តបង្រឹងការអភិវឌ្ឍវិស័យនគរូបនីយកម្ម ដោយអនុលោមទៅតាមច្បាប់ស្តីពីសំណង់ និងបទដ្ឋានគតិយុត្តនគរូបនីយកម្ម និងបច្ចេកទេសដើម្បីធានាបាននូវគុណភាព សន្តិសុខ សុវត្ថិភាព សោភ័ណភាព សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថានព្រមទាំងចាត់វិធានការទប់ស្កាត់ការកសាងលើដីចំណីសាធារណៈ។
- ជម្រុញការសាងសង់លំនៅឋានតម្លៃសមរម្យសម្រាប់ជួល និងលក់ជូនប្រជាពលរដ្ឋដែលមានប្រាក់ចំណូលមធ្យម ចំណូលទាប ដោយស្របតាមគោលនយោបាយជាតិស្តីពីបរិស្ថាន។
- ការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ។ [42]

[42] ដកស្រង់ចេញពី គេហទំព័រ https://ocm.gov.kh ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

យោងតាមការស្រាវជ្រាវប្រធានបទខាងលើមកយើងមើលឃើញថា ការអភិវឌ្ឍទីក្រុងរណបកោះនរា គឺជាកត្តាលីករជម្រុញដ៏សំខាន់សម្រាប់ធ្វើឱ្យទីក្រុងគោល ក៏ដូចជាទីក្រុងរណបមានរបៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងមានបរិស្ថានល្អប្រសើរជាងមុន។ យ៉ាងណាមិញការអភិវឌ្ឍទីក្រុងរណបក៏ជាតំបន់សេដ្ឋកិច្ចឧស្សាហកម្មមួយយ៉ាងសំខាន់បន្ទាប់ពីទីក្រុងគោលដោយមានការរៀបចំប្រព័ន្ធគមនាគមន៍ ប្រព័ន្ធទឹកស្អាត សួនច្បារ មន្ទីរពេទ្យ សាលារៀន ព្រមទាំងអគារពាណិជ្ជកម្មជាច្រើនទៀតផង។ល។ ដែលទទួលបានការវិនិយោគពីបណ្តាប្រទេសនានាជុំវិញសកលលោក និងជួយឱ្យប្រទេសកម្ពុជាដែលជាប្រទេសកំពុងតែឆ្ពោះទៅរកការអភិវឌ្ឍយ៉ាងមានសន្ទុះ ព្រមទាំងមានការរីកចម្រើនខាងវិស័យសេដ្ឋកិច្ចខ្លាំងជាងមុន។

ទោះបីជាអភិបាលខណ្ឌ និងអាជ្ញាធរពាក់ព័ន្ធ ក៏ដូចជាម្ចាស់វិនិយោគលើគម្រោងនេះបានខិតខំប្រឹងប្រែងរៀបចំហេដ្ឋារចនាសម្ព័ន្ធ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈប្រកបដោយសមភាព ចីរភាព សមធម៌ របៀបរៀបរយក៏ពិតមែននៅតែមានចំណុចខ្វះខាតមួយចំនួននៅតែកើតមានឡើងដូចជាករណី ឃាតកម្ម អំពើហិង្សា លួច ប្លន់ និងកន្លែងកែលម្អមួយចំនួននៅមិនទាន់មានភាពរៀបរយ ម្យ៉ាងទៀតបញ្ហាអនាម័យក៏នៅមានកម្រិតក្នុងការបម្រើសេវាកម្មដល់ភ្ញៀវជាតិ និងអន្តរជាតិ។

បន្ថែមពីនេះទៅទៀតរាជរដ្ឋាភិបាលកម្ពុជា ទាំងរាជរដ្ឋាភិបាលអាណត្តិចាស់ និងរាជរដ្ឋាភិបាលអាណត្តិថ្មីតែងតែខិតខំប្រឹងប្រែងរៀបចំយុទ្ធសាស្ត្រដឹកនាំប្រទេសឱ្យឈានទៅរកសន្តិភាព ស្ថេរភាពនយោបាយ ដើម្បីឱ្យប្រទេសជាតិមានការរីកចម្រើនលូតលាស់ឈានទៅរកប្រទេសជាតិមួយដែលបណ្តាសកលលោកទទួលស្គាល់ថាជាប្រទេសតូច ប៉ុន្តែមានសក្តានុពលយ៉ាងខ្លាំងក្លាទៅលើគ្រប់វិស័យដូចបណ្តាប្រទេសដទៃទៀតដែរ។

សរុបសេចក្តីមកការអភិវឌ្ឍទីក្រុងរណបកោះនរា គឺពិតជាមានសារៈសំខាន់ពិតប្រាកដមែន ពីព្រោះការរៀបចំទីក្រុងរណបកោះនរាបានបង្កើតទីផ្សារការងារជាច្រើនជូនប្រជាពលរដ្ឋ និងកាត់បន្ថយការកកស្ទះចរាចរណ៍បានមួយផ្នែក ព្រមទាំងកាត់បន្ថយកំណើនប្រជាជននៅក្រុងគោលបានមួយកម្រិតថែមទៀតផង។ តួយ៉ាង ក៏បានរៀបចំនៅហេដ្ឋរចនាសម្ព័ន្ធផ្សេងៗជាច្រើនដើម្បីបម្រើដល់ប្រយោជន៍សាធារណៈជូនប្រជាពលរដ្ឋក្នុងការមកលំហែ កម្សាន្ត និងទាក់ទាញអ្នកវិនិយោគ មកវិនិយោគទុននៅកម្ពុជាកាន់តែច្រើន។

# អនុសាសន៍

# អនុសាសន៍

ឆ្លងតាមដំណាក់កាលនៃការស្រាវជ្រាវជាច្រើនមកយើងមើលឃើញថា នីតិនគរូបនីយកម្ម និងសំណង់ពិតជាមុខវិជ្ជាដ៏សំខាន់មួយមុខបានធ្វើឱ្យ យើងស្វែងយល់អំពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងសៀវភៅគោលបញ្ជីដីធ្លីក្នុងការរៀបចំដីធ្លីឱ្យកាន់តែមានសក្តានុពលខ្ពស់ជាងមុនដើម្បីជាទំនុកចិត្តដល់អ្នកវិនិយោគ មកធ្វើការបណ្តាក់ទុននៅកម្ពុជា ដោយទាំងអស់នេះគឺមានចែងនៅក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងសារាចរណែនាំជាដើម។

ការអភិវឌ្ឍទីក្រុងរណបកោះនរាមានទាំងគុណសម្បត្តិ និងគុណវិបត្តផ្សេងៗពីគ្នា ក៏ប៉ុន្តែយើងខ្ញុំទាំងពីរនាក់ក៏សូមសរសើរដល់អាជ្ញាធរពាក់ព័ន្ធ និងម្ចាស់គម្រោងវិនិយោគដែលបានខិតខំប្រឹងប្រែងរៀបចំក្នុងការអភិវឌ្ឍដូចជា ៖

- បានបង្កើតនូវសួនច្បារសាធារណៈ ដើម្បីទាក់ទាញអ្នកមកលេងកម្សាន្ត
- បានបង្កើតអគារពាណិជ្ជកម្មជាច្រើនដើម្បីជាការទាក់ភ្នែកដល់អ្នកវិនិយោគមកធ្វើការបណ្តាក់ទុន និង ធ្វើឱ្យប្រទេសជាតិមានការរីកចម្រើនខាងសេដ្ឋកិច្ចបានមួយកម្រិតទៀត
- កាត់បន្ថយនូវការកកស្ទះនៅចរាចរណ៍នៅក្នុងរាជធានីភ្នំពេញ
- ជួយបង្កើតការងារជូនប្រជាពលរដ្ឋ និងកំណើនសេដ្ឋកិច្ចជាតិ
- ប្រែក្លាយតំបន់ដែលនៅទំនេរទៅជាតំបន់ដែលអភិវឌ្ឍខាងអគារពាណិជ្ជកម្ម ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត
- សន្តិសុខសណ្តាប់ធ្នាប់សាធារណៈក៏មានភាពល្អប្រសើរជាងមុន
- ជួយបង្កើនកំណើនវិស័យទេសចរណ៍ឱ្យកាន់តែមានភាពលូតលាស់
- ការនាំចេញ នាំចូលទំនិញផ្សេងៗតាមផ្លូវទឹកកាន់តែមានភាពងាយស្រួល និងចំណាយតិច
- ការកាត់បន្ថយនូវសម្រាម ដែលធ្វើឱ្យបរិស្ថានកាន់តែល្អប្រសើរជាងមុន វាជាផ្នែកមួយជួយដល់ការអភិវឌ្ឍជាតិ។

# ឯកសារយោង

# ឯកសារយោង

## ១.ច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, អនុម័តនៅ ថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៨។
- ច្បាប់ស្តីពី ការគ្រប់គ្រង ទឹកស្អាត, ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣។
- អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍, លេខ២៥៦, អនក្រ.បក, ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦, ធ្វើនៅរាជធានីភ្នំពេញ។
- អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន, លេខ២៣៤, អនក្រ.បក, ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១, ធ្វើនៅរាជធានីភ្នំពេញ។
- អនុក្រឹត្យស្តីពី លិខិតអនុញ្ញាតសាងសង់, លេខ២២៤, អនក្រ.បក, ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០, ធ្វើនៅរាជធានីភ្នំពេញ។
- អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា, លេខ១៥៦, អនក្រ .បក, ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦, ធ្វើនៅរាជធានីភ្នំពេញ។
- អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម, លេខ៩១, អនក្រ.បក, ថ្ងៃទី ០១ ខែសីហា ឆ្នាំ២០០៧, ធ្វើនៅរាជធានីភ្នំពេញ។
- អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ, លេខ៧៨, អនក្រ.បក, ថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧, ធ្វើនៅរាជធានីភ្នំពេញ។
- អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល, លេខ៦៧, អនក្រ.បក, ថ្ងៃទី ២២ ខែតុលា ឆ្នាំ១៩៩៧, ធ្វើនៅរាជធានីភ្នំពេញ។
- អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌ ... 

- អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី, លេខ៤៧, អនក្រ.បក, ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២, ធ្វើនៅរាជធានីភ្នំពេញ។

- អនុក្រឹត្យស្តីពី នីតិវិធីនៃការសាងសង់ប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ៤៦, អនក្រ.បក, ថ្ងៃទី២២ ខែមីនា ឆ្នាំ២០០០, ធ្វើនៅរាជធានីភ្នំពេញ។
- អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល, លេខ៣៥, អនក្រ.បក, ថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩, ធ្វើនៅរាជធានីភ្នំពេញ។
- ប្រកាសស្តីពី ការអភិវឌ្ឍដី, លេខ០៨៧, នៅទីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨, ធ្វើនៅរាជធានីភ្នំពេញ។
- ប្រកាសស្តីពី តួនាទី និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងសុរិយោដីខេត្ត ក្រុង និងតួនាទីភារកិច្ចរបស់បណ្ដាការិយាល័យលក្រោមឱវាទ, លេខ៧៦, ធ្វើនៅរាជធានីភ្នំពេញ។
- សេចក្តីសម្រេចស្តីពី នីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ, លេខ០៤១, សសរ, នៅទីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤, ធ្វើនៅរាជធានីភ្នំពេញ។
- ប្រកាសអន្តរក្រសួងស្តីពី សេចក្តីណែនាំបច្ចេកទេសស្តីពី ការរៀបចំ និងការកសាងផែនការអភិវឌ្ឍក្រុង, ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ ២០១៧, ធ្វើនៅរាជធានីភ្នំពេញ។

## ២.ឯកសារយោងជាសៀវភៅ

- សៀវភៅនគរូបនីយវិទ្យារបស់សាស្ត្រាចារ្យ បណ្ឌិត អ៊ុន សក្កដា ឆ្នាំ២០២៣, ធ្វើនៅរាជធានីភ្នំពេញ។
- សៀវភៅកម្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងដីធ្លីរបស់សាស្ត្រាចារ្យ បណ្ឌិត ហាប់ ផល្លី ឆ្នាំ២០១៤, ធ្វើនៅរាជធានីភ្នំពេញ។
- សៀវភៅកម្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងដីធ្លី និងនគរូបនីយកម្មឆ្នាំ១៩៨៥ដល់ ២០១៥ របស់សាស្ត្រាចារ្យ ហាប់ ផល្លី, ធ្វើនៅរាជធានីភ្នំពេញ។
- វចនានុក្រមខ្មែរ,សម្តេចសង្ឃរាជ ជួន ណាត, ធ្វើនៅរាជធានីភ្នំពេញ។

## ៣.ឯកសារយោងជាគេហទំព័រ

- គេហទំព័រ https://propertyarea.asia/archives/101803
- គេហទំព័រ https://mlmupc.gov.kh

- គេហទំព័រ https://www.harbor-property.com/km/wiki/detail/544/
- គេហទំព័រhttps://gggi.org/wp-content/uploads/2019/06/SUBSTAINABLE-CITY-REPORT_KH_FA1.pdf
- គេហទំព័រhttps://m.compass.com.kh/kh/real-estate-encyclopedia-detail/146-390/?os=3
- គេហទំព័រhttps://opendevelopmentcambodia.net/km/topics/urban-administration-and-development/
- គេហទំព័រhttps://ncdd.gov.kh/wp-content/uploads/2018/10/2.-Municipality-DPFinal.pdf
- គេហទំព័រ https://nspc.gov.kh/social-security-cambodia
- គេហទំព័រ https://propertyarea.asia/archives/79392
- គេហទំព័រ https://www.harbor-property.com/km/wiki/detail/571/
- គេហទំព័រ https://www.hotnews-asia.com/detail/227887
- គេហទំព័រhttps://data.opendevelopmentcambodia.net/km/dataset/land-use-master-plan-of-phnom-penh-city-2035
- គេហទំព័រ https://kh.cc-times.com/posts/17042
- គេហទំព័រ https://cambodiapropertyreport.com/article/9341

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១.ឧបសម្ព័ន្ធគតិយុត្ត

**ឧបសម្ព័ន្ធទី១ ៖** អនុក្រឹត្យស្តីពី លិខិតអនុញ្ញាតសាងសង់, លេខ២២៤, អនក្រ.បក, ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០, ធ្វើនៅរាជធានីភ្នំពេញ។

**ឧបសម្ព័ន្ធទី២ ៖** អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី, លេខ៤៧, អនក្រ.បក, ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២, ធ្វើនៅរាជធានីភ្នំពេញ។

**ឧបសម្ព័ន្ធទី៣ ៖** អនុក្រឹត្យស្តីពី នីតិវិធីនៃការសាងសង់ប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ៤៦, អនក្រ.បក, ថ្ងៃទី២២ ខែមីនា ឆ្នាំ២០០០, ធ្វើនៅរាជធានីភ្នំពេញ។

**ឧបសម្ព័ន្ធទី៤ ៖** ប្រកាសស្តីពី ការអភិវឌ្ឍដី, លេខ០៨៧, នៅទីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨, ធ្វើនៅរាជធានីភ្នំពេញ។

**ឧបសម្ព័ន្ធទី៥ ៖** ប្រកាសស្តីពី តួនាទី និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងសុរិយោដីខេត្ត ក្រុង និងតួនាទីភារកិច្ចរបស់បណ្តាការិយាល័យលក្រោមឱវាទ, លេខ៧៦, ធ្វើនៅរាជធានីភ្នំពេញ។

**ឧបសម្ព័ន្ធទី៦ ៖** សេចក្តីសម្រេចស្តីពី នីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ, លេខ០៤១, សសរ, នៅទីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤, ធ្វើនៅរាជធានីភ្នំពេញ។

**ឧបសម្ព័ន្ធទី៧ ៖** ប្រកាសអន្តរក្រសួងស្តីពី សេចក្តីណែនាំបច្ចេកទេសស្តីពី ការរៀបចំ និងការកសាងផែនការអភិវឌ្ឍក្រុង, ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ ២០១៧, ធ្វើនៅរាជធានីភ្នំពេញ។

## ២.ឧបសម្ព័ន្ធជារូបភាព

**ឧបសម្ព័ន្ធទី១ ៖** ផែនទីខណ្ឌច្បារអំពៅ និងផែនទីតំបន់កោះនរា ។

**ឧបសម្ព័ន្ធទី២ ៖** ទីតាំងសំខាន់ៗនៅខណ្ឌច្បារអំពៅ និងទីក្រុងរណបកោះនរា ។

**ឧបសម្ព័ន្ធទី៣ ៖** សកម្មភាពរបស់រដ្ឋបាលខណ្ឌច្បារអំពៅ ដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍទីក្រុងរណប កោះនរា ។

# ឧបសម្ព័ន្ធគតិយុត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
លេខ:...០៤១...គណដ....

# សេចក្តីសម្រេច

## ស្តីពី

## នីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិង ផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-យោងតាមការចាំបាច់របស់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

សេចក្តីសម្រេចនេះមានគោលបំណងធានាគុណភាពនិងប្រសិទ្ធភាពនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និង/ឬផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ នៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

សេចក្តីសម្រេចនេះ  មានគោលដៅកំណត់គោលការណ៍និងនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ប្រការ ៣.-**

សេចក្តីសម្រេចនេះ  មានវិសាលភាពអនុវត្តចំពោះដីសាធារណៈរបស់រដ្ឋនិងដីឯកជនរបស់រដ្ឋ  ព្រមទាំងដីរបស់បុគ្គលឯកជននៅក្រុង ស្រុក ខណ្ឌ។

**ប្រការ ៤.-**

វាក្យស័ព្ទមួយចំនួនដែលប្រើក្នុងសេចក្តីសម្រេចនេះ មានន័យដូចតទៅ៖

- **ប្លង់គោលប្រើប្រាស់ដី** សំដៅដល់ផែនការដែលកំណត់អំពីចក្ខុវិស័យនិងយុទ្ធសាស្ត្រតម្រង់ទិសសម្រាប់ការអភិវឌ្ឍរូបវន្តនិងកំណត់អំពីប្រភេទនៃការប្រើប្រាស់ដី (ប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់) ព្រមទាំងបង្ហាញអំពីទម្រង់ បណ្តាញហេដ្ឋារចនាសម្ព័ន្ធនិងគមនាគមន៍សំខាន់ៗនៃក្រុង ស្រុក ខណ្ឌ និងការធ្វើសមាហរណកម្មក្រុង ស្រុក ខណ្ឌ និងតំបន់ជុំវិញ។ ប្លង់គោលប្រើប្រាស់ដី ត្រូវភ្ជាប់ជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍ និងអភិរក្សក្រុង ស្រុក ខណ្ឌ ទៅតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី មធ្យមនិងវែង។ ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ មានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង។
- **ផែនការប្រើប្រាស់ដី** សំដៅដល់ផែនការលម្អិតចេញពីប្លង់គោលប្រើប្រាស់ដី ដែលកំណត់អំពីប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី និងកំណត់អំពីបទបញ្ជានៃការប្រើប្រាស់ដីជាក់ស្តែង ការសាងសង់ ការអភិវឌ្ឍ និងការអភិរក្សក្នុងតំបន់នីមួយៗ។ ផែនការប្រើប្រាស់ដីបង្ហាញនូវបណ្តាញគមនាគមន៍ និងការធ្វើសមាហរណកម្មក្រុង ស្រុក ខណ្ឌ និងតំបន់ជុំវិញ។ ផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ មានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង។
- **ប្លង់លម្អិតនគរូបនីយកម្ម** សំដៅដល់ប្លង់វិលេចទីតាំងនៃតំបន់ណាមួយក្នុងទីក្រុង ឬជាគម្រោងអភិវឌ្ឍទីក្រុង ដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររូបវន្តលម្អិតនៃការរៀបចំផ្នែក ទីតាំង ឬតំបន់ប្រើប្រាស់ដីណាមួយ ឬច្រើននៃក្រុង ស្រុក ខណ្ឌ ដូចជា ការបង្ហាញអំពីការរៀបចំ ការរចនា ទម្រង់ រូបរាង និងសោភណភាពនៃរចនាសម្ព័ន្ធរូបវន្ត សម្រាប់ការអភិវឌ្ឍ ការអភិរក្ស និង[illegible]តាមរយៈគំនូរ ឬរូបសំណាក។

- **ចក្ខុវិស័យ** សំដៅដល់ការប្រមើលមើលទៅមុខក្នុងការរៀបចំក្រុង ស្រុក ខណ្ឌទៅអនាគតស្របតាមសក្ដានុពលនិងស្ថានភាពជាក់ស្ដែងនៃក្រុង ស្រុក ខណ្ឌ (ឧទាហរណ៍ កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ ដឹកជញ្ជូន...)។
- យុទ្ធសាស្ត្រ សំដៅដល់វិធីសាស្ត្រ ឬ មធ្យោបាយក្នុងការធ្វើឲ្យសម្រេចបាននូវចក្ខុវិស័យខាងលើ។ ចក្ខុវិស័យនិងយុទ្ធសាស្ត្រអាចមានច្រើនទៅតាមសក្ដានុពលជាក់ស្ដែងរបស់ក្រុង ស្រុក ខណ្ឌផ្ទាល់។
- **ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ** សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មានជាអាទិ៍ បណ្ដាញផ្លូវសាធារណៈ បរិក្ខារសាធារណៈ (ប្រព័ន្ធទឹកស្អាត ប្រព័ន្ធលូបង្ហូរទឹកកខ្វក់ លូទឹកភ្លៀង បណ្ដាញអគ្គិសនី បណ្ដាញទូរគមនាគមន៍...) ប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងនិងរាវ (ទីលានចាក់សំរាម រោងចក្រកែច្នៃសំរាម អាងប្រព្រឹត្តកម្មទឹកកខ្វក់...) ប្រព័ន្ធគ្រប់គ្រងអគ្គិភ័យនិងហានិភ័យផ្សេងៗ។ល។
- **សំណង់សម្រាប់ផ្ដល់សេវាជូនសាធារណជន** មានជាអាទិ៍ អគាររដ្ឋបាល អគារសិក្សា មន្ទីរពេទ្យ ស្ថានីយរថយន្ត ស្ថានីយរថភ្លើង ព្រលានយន្តហោះ កំពង់ផែ។ល។
- **លំហសាធារណៈ** សំដៅដល់សួនច្បារសាធារណៈ កន្លែងក្មេងលេង កន្លែងហាត់ប្រាណ ទីលានកីឡា ទីលានកម្សាន្ត។ល។
- **ផែនការរូបវន្ត** សំដៅដល់ការធ្វើសមាហរណកម្មផែនការប្រើប្រាស់ដី និងផែនការហេដ្ឋារចនាសម្ព័ន្ធរូបវន្តដើម្បីធានាការអភិវឌ្ឍ ការអភិរក្សនិងការសាងសង់នៅក្នុងក្រុង ស្រុក ខណ្ឌ ឲ្យមានចីរភាព តុល្យភាព សុខុមាលភាព សុខភាព សោភណភាពនិងសមធម៌។ ផែនការរូបវន្តក្រុង ស្រុក ខណ្ឌ មានប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម។
- **ទិន្នន័យបឋម** សំដៅដល់ទិន្នន័យដែលបានមកតាមរយៈការចុះទៅធ្វើសម្រង់ផ្ទាល់លើទីតាំងជាក់ស្ដែង ការចុះវាស់វែងនិងការជួបសម្ភាសន៍ផ្ទាល់ជាមួយប្រជាពលរដ្ឋនិងភាគីពាក់ព័ន្ធ ស្របតាមតម្រូវការនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិង/ឬផែនការប្រើប្រាស់ដី។
- **ទិន្នន័យទី២** សំដៅដល់ទិន្នន័យដែលបានកសាងរួចដោយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ មានជាអាទិ៍ សៀវភៅទិន្នន័យ កម្រងឯកសារទិន្នន័យ របាយការណ៍ពាក់ព័ន្ធ ឯកសារបណ្ណាល័យ បណ្ណាសារ សារព័ត៌មាន ទស្សនាវដ្ដី។ល។

## ជំពូកទី២
## គោលការណ៍

**ប្រការ ៥.-**

ការរៀបចំប្លង់គោលប្រើប្រាស់ដីនិង/ឬផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- មានការចូលរួមពីអ្នកពាក់ព័ន្ធ
- ស្របតាមគោលការណ៍វិមជ្ឈការនិងវិសហមជ្ឈការ
- គោរពតាមឋានានុក្រមនិងលក្ខណៈទ្វេទិសនៃរាល់ការសម្រេចចិត្ត
- មានកិច្ចសហការជាមួយគ្រប់សមត្ថកិច្ចជំនាញនិងអាជ្ញាធរដែនដីពាក់ព័ន្ធ
- យកផែនការរូបវន្តក្រុង ស្រុក ខណ្ឌជាមូលដ្ឋានបង្អែកសម្រាប់ការអភិវឌ្ឍ ការអភិរក្ស ការអភិវឌ្ឍន៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងការសាងសង់គ្រប់ប្រភេទក្នុងក្រុង ស្រុក ខណ្ឌ និងទាំងការធ្វើ

សមាហរណកម្ម ដើម្បីធ្វើឲ្យការប្រើប្រាស់ដីបានត្រឹមត្រូវ ចំទិសដៅ មានប្រសិទ្ធភាព មានចីរភាព មានគុណភាពនិងមានសមធម៌

- រួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុសកលនិងលើកកម្ពស់ការអភិវឌ្ឍបៃតង
- ត្រូវយកចិត្តទុកដាក់ដល់សុវត្ថិភាព សុខុមាលភាព និងភាពងាយស្រួលសម្រាប់មនុស្សទាំងអស់គ្នា រួមទាំងជនពិការ ជនចាស់ជរានិងជនងាយរងគ្រោះ។

## ជំពូកទី៣
## យន្តការ សមត្ថកិច្ចនិងភារកិច្ច

**ប្រការ ៦.-**

យន្តការ សមត្ថកិច្ចនិងភារកិច្ច ក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដីនិង/ឬផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមបទប្បញ្ញត្តិដែលមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ជំពូកទី៤
## ផែនការរូបវន្តសម្រាប់ក្រុង ស្រុក ខណ្ឌ

**ប្រការ ៧.-**

ផែនការរូបវន្តសម្រាប់ក្រុង ស្រុក ខណ្ឌ រួមមាន៖

- ថ្នាក់ក្រុង មានប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម
- ថ្នាក់ស្រុក ខណ្ឌ មានប្លង់គោលប្រើប្រាស់ដី។

## ផ្នែកទី១
## នីតិវិធីនៃការរៀបចំប្លង់គោលប្រើប្រាស់ដី

**ប្រការ ៨.-**

ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវមានទំហំការងារអប្បបរមាដូចខាងក្រោម៖

១.ការប្រមូលនិងវិភាគទិន្នន័យ : ត្រូវប្រមូលនិងវិភាគទិន្នន័យរូបវន្ត សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន វប្បធម៌ ប្រជាសាស្ត្រ និងការស្រង់មតិ។ល។

២.ការកំណត់ចក្ខុវិស័យ : ត្រូវសិក្សានិងកំណត់ចក្ខុវិស័យអភិវឌ្ឍនិងអភិរក្ស សម្រាប់រយៈពេលយ៉ាងតិច ១៥(ដប់ប្រាំ)ឆ្នាំ។

៣.ការកំណត់យុទ្ធសាស្ត្រ : ត្រូវសិក្សានិងកំណត់យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សដើម្បីសម្រេចបាននូវចក្ខុវិស័យ មានជាអាទិ៍៖

-យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្ស

-យុទ្ធសាស្ត្រប្រើប្រាស់ដី

-យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

-យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច
-យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ច
-យុទ្ធសាស្ត្រការពារបរិស្ថាន អភិវឌ្ឍបៃតង និងគ្រប់គ្រងកាកសំណល់
-យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ។

៤.គំនូសប្លង់សម្រាប់ប្លង់គោលប្រើប្រាស់ដី មានដូចជា៖

៤.១.ប្លង់សម្រង់ទិន្នន័យស្ថានភាពបច្ចុប្បន្ន
-ប្លង់បង្ហាញទីតាំង
-ប្លង់បង្ហាញព្រំប្រទល់សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដី
-ប្លង់ដង់ស៊ីតេប្រជាជន
-ប្លង់កំណត់ប្រភេទប្រើប្រាស់ដី
-ប្លង់បណ្តាញផ្លូវថ្នល់និងគមនាគមន៍ចម្បងៗ
-ប្លង់លំហសាធារណៈនិងផ្ទៃបៃតង
-ប្លង់និន្នាការនៃការរីករបស់ក្រុង ស្រុក ខណ្ឌ
-ប្លង់គ្រប់គ្រងកាកសំណល់រឹង
-ប្លង់គ្រប់គ្រងកាកសំណល់រាវ
-ប្លង់សរុប។

៤.២.ប្លង់អនាគតកាល ស្របតាមចក្ខុវិស័យ មានដូចជា៖
-ប្លង់បង្ហាញព្រំប្រទល់សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដី
-ប្លង់ដង់ស៊ីតេប្រជាជន
-ប្លង់បែងចែកប្រភេទប្រើប្រាស់ដី
-ប្លង់បណ្តាញផ្លូវថ្នល់និងគមនាគមន៍ចម្បងៗ
-ប្លង់លំហសាធារណៈនិងផ្ទៃបៃតង
-ប្លង់គម្រោងពង្រីកក្រុង ស្រុក ខណ្ឌ
-ប្លង់គ្រប់គ្រងកាកសំណល់រឹង
-ប្លង់គ្រប់គ្រងកាកសំណល់រាវ
-ប្លង់សរុប។

៥.សេចក្តីណែនាំអនុវត្តនិងគ្រប់គ្រងការអភិវឌ្ឍ : ត្រូវរៀបចំបញ្ជីគម្រោងនិងផែនការសកម្មភាពតាមលំដាប់អាទិភាពសម្រាប់ការអនុវត្តរយៈពេលខ្លី រយៈពេលមធ្យមនិងរយៈពេលវែង ព្រមទាំងមានសេចក្តីណែនាំសម្រាប់ការអនុវត្តនិងការគ្រប់គ្រង ការអភិវឌ្ឍ ការអភិរក្សនិងការសាងសង់។

៦.ឯកសារឧបសម្ព័ន្ធ។

៧.ឯកសារទាំងអស់ ត្រូវចងក្រងជារបាយការណ៍បច្ចេកទេស។

**ប្រការ ៥.-**

ការរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវគោរពតាមគោលការណ៍ដូចមានចែងក្នុងប្រការ៩ នៃសេចក្តីសម្រេចនេះ។ ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវផ្តួចផ្តើមនិងរៀបចំដោយគណៈកម្មាធិការ

រៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ និងសម្របសម្រួលដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

នីតិវិធីនិងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖

ជំហានទី១. ការផ្សព្វផ្សាយគម្រោងនិងការចុះសិក្សាបឋមលើទីតាំង

ជំហានទី២. ការចុះប្រមូលទិន្នន័យនិងព័ត៌មាន

ជំហានទី៣. ការវិភាគទិន្នន័យនិងការរៀបចំសេចក្តីព្រាងចក្ខុវិស័យនិងយុទ្ធសាស្ត្រ

ជំហានទី៤. ការរៀបចំសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី

ជំហានទី៥. ការប្រមូលធាតុចូលនិងការកែសម្រួលបឋម

ជំហានទី៦. ការបិទផ្សាយជាសាធារណៈ

ជំហានទី៧. ការកែសម្រួលចុងក្រោយ

ជំហានទី៨. ការរៀបចំគម្រោងអាទិភាព

ជំហានទី៩. ការសម្រេចលើប្លង់គោលប្រើប្រាស់ដី។

ក្នុងដំណើរការរៀបចំប្លង់គោលប្រើប្រាស់ដី ត្រូវរៀបចំសិក្ខាសាលានៅទីតាំងគម្រោងដើម្បីទទួលធាតុចូលឱ្យបានយ៉ាងតិច៣(បី)លើក ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ ១០.-**

ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើបច្ចុប្បន្នកម្មដោយត្រូវកត់ត្រាទុកជាប្រចាំនូវស្ថានភាពវិវត្តរបស់ក្រុង ស្រុក ខណ្ឌ ដើម្បីងាយស្រួលក្នុងការរៀបចំជាសេចក្តីព្រាងសំណើប្លង់គោលប្រើប្រាស់ដីសម្រាប់ស្នើសុំកែសម្រួលសរុបក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមនីតិវិធីដែលមានលក្ខណៈដូចដំណើរការធ្វើប្លង់គោលប្រើប្រាស់ដីថ្មីដែរ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ មុនពេលកំណត់នៃរយៈពេល៥ឆ្នាំ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ ឬតម្រូវការចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ប្លង់គោលប្រើប្រាស់ដីដែលត្រូវបានកែសម្រួលរួច ត្រូវស្នើសុំការសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការតាមនីតិវិធីដូចការសម្រេចប្លង់គោលប្រើប្រាស់ដីថ្មីដែរ។

## ជំហានទី១
## ការផ្សព្វផ្សាយគម្រោងនិងការចុះសិក្សាបឋមលើទីតាំង

**ប្រការ ១១.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផ្សព្វផ្សាយគម្រោងរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ នៅទីតាំងដែលត្រូវអនុវត្តគម្រោងនេះតាមរយៈ៖

- កិច្ចប្រជុំផ្សព្វផ្សាយឬសិក្ខាសាលាផ្សព្វផ្សាយ នៅទីតាំងដែលត្រូវអនុវត្តគម្រោង
- ការបិទផ្សាយគម្រោងនៅទីតាំងដែលត្រូវអនុវត្តគម្រោង
- ប្រព័ន្ធឃោសនានានា ដូចជាតាមវិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី និងបណ្តាញព័ត៌មានវិទ្យាផ្សេងៗ

ការផ្សព្វផ្សាយខាងលើនេះមានសារៈសំខាន់ណាស់ ដើម្បីឲ្យប្រជាពលរដ្ឋនៅទីតាំងនោះយល់ដឹងអំពីផលប្រយោជន៍ដែលខ្លួននឹងត្រូវទទួលបានពីគម្រោងនេះនិងចូលរួមសហការ ក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។ តំណាងប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធនានាត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយនេះ។

អាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងដល់អ្នកចូលរួមនិងអ្នកពាក់ព័ន្ធ ឲ្យបានយ៉ាងតិច១(មួយ)សប្តាហ៍ មុនកាលបរិច្ឆេទនៃការប្រជុំផ្សព្វផ្សាយ។

**ប្រការ ១២.-**

ការចុះសិក្សាបឋមលើទីតាំង ត្រូវត្រួតពិនិត្យស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ បរិស្ថាន ចរាចរណ៍ ការប្រើប្រាស់ដីនិងសំណង់ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងព័ត៌មានរូបវន្តមួយចំនួនដែលមានស្រាប់ ដើម្បីជាមូលដ្ឋាននិងដាក់ចេញនូវគោលគំនិតសំខាន់ៗក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដី នាពេលអនាគត។

អ្នកជំនាញបច្ចេកទេសចូលរួមក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដី មានជាអាទិ៍ នគរូបនីយវិទូ ស្ថាបត្យករ អ្នករៀបចំដែនដី វិស្វករ ប្រជាសាស្ត្រវិទូ អ្នកច្បាប់ សង្គមវិទូ ភូមិសាស្ត្រិន បរិស្ថានវិទូ សេដ្ឋកិច្ចវិទូ និងអ្នកជំនាញផ្សេងៗទៀត ដែលមានការពាក់ព័ន្ធ។ល។ អ្នកជំនាញទាំងនេះត្រូវសហការគ្នាលើកឡើងនូវគំនិតច្នៃប្រឌិតខ្ពស់ក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដី។ អ្នកជំនាញទាំងនេះត្រូវរៀបចំផែនការសកម្មភាពរបស់ខ្លួនស្របតាមវិសាលភាពការងារ ថវិកានិងពេលវេលាដែលបានកំណត់តាមជំហាននីមួយៗ។

ជំហានទី១នេះ មានរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃប្រជុំផ្សព្វផ្សាយជាសាធារណៈនូវគម្រោងរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

## ជំហានទី២
## ការចុះប្រមូលទិន្នន័យនិងព័ត៌មាន

**ប្រការ ១៣.-**

ការចុះប្រមូលទិន្នន័យ ដែលរួមមានទិន្នន័យបឋមនិងទិន្នន័យទី២ ត្រូវបានធ្វើឡើងក្នុងក្របខណ្ឌនៃដែនដីដែលត្រូវរៀបចំប្លង់គោលប្រើប្រាស់ដី ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។ ទិន្នន័យមានសារៈសំខាន់ជាមូលដ្ឋានគ្រឹះសម្រាប់សិក្សាវិភាគស្វែងយល់អំពីស្ថានភាពបច្ចុប្បន្នក្នុងគោលដៅរៀបចំប្លង់គោលប្រើប្រាស់ដីនាពេលអនាគត។

ទិន្នន័យនិងព័ត៌មានដែលត្រូវប្រមូលមានជាអាទិ៍ ទិន្នន័យរូបវន្ត សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន វប្បធម៌ ការប្រើប្រាស់ដីនិងសំណង់ ប្រជាសាស្ត្រ គម្រោងអភិវឌ្ឍ។ល។ ទិន្ន័យនិងព័ត៌មានទាំងនេះត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើរបាយការណ៍បច្ចេកទេសនិងប្លង់។

ជំហានទី២នេះ មានរយៈពេលចំនួន១៥០(មួយរយហាសិប)ថ្ងៃ។

## ជំហានទី៣
## ការវិភាគទិន្នន័យនិងការរៀបចំសេចក្តីព្រាងចក្ខុវិស័យនិងយុទ្ធសាស្ត្រ

**ប្រការ ១៤.-**

ការវិភាគទិន្នន័យមានគោលបំណងវិភាគពីលក្ខខណ្ឌមានស្រាប់ដើម្បីស្វែងរកបញ្ហាដែលធ្លាប់កើតមាន និងសក្តានុពលរបស់តំបន់។ លទ្ធផលនៃការវិភាគទិន្នន័យខាងលើនេះ ត្រូវបង្ហាញនៅលើប្លង់និងដ្យាក្រាមផ្សេងៗដោយធ្វើចំណោល (ប្រមើលមើលឬព្យាករណ៍) ដើម្បីកំណត់នូវការវិវឌ្ឍនិងការរៀបចំផែនការនាពេលអនាគត។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំទិន្នន័យនិងព័ត៌មានទៅតាមលំដាប់លំដោយនិងតាមប្រភេទនីមួយៗ បន្ទាប់មកធ្វើការវិភាគតាមវិធីសាស្ត្រ វិភាគបែបបរិមាណ និងវិភាគបែបគុណភាព។

**ប្រការ ១៥.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំសេចក្តីព្រាងចក្ខុវិស័យនិងយុទ្ធសាស្ត្រតាមស្ថានភាពនិងសក្តានុពលរបស់តំបន់នីមួយៗ។ ការរៀបចំចក្ខុវិស័យនិងយុទ្ធសាស្ត្រនេះធ្វើឡើងក្នុងគោលបំណងលើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋ ការអភិវឌ្ឍនិងការអភិរក្សប្រកបដោយប្រសិទ្ធភាព ចីរភាពនិងសមធម៌ ដោយធានាថា ក្រុង ស្រុក ខណ្ឌ ជាកន្លែងផ្តល់នូវសុខដុមនីយកម្មសម្រាប់ការរស់នៅ ការផ្តល់ការងារ ការរៀនសូត្រ និងការលំហែកម្សាន្ត។

បន្ទាប់ពីបានកំណត់នូវចក្ខុវិស័យនិងយុទ្ធសាស្ត្រ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំបង្ហាញតាមរយៈគំនូសបំព្រួញនិងសេចក្តីព្រាងប្លង់ដែលងាយស្រួលក្នុងការពិនិត្យ បកស្រាយ និងពិភាក្សាជាមួយនឹងភាគីពាក់ព័ន្ធ។

ជំហានទី៣នេះ មានរយៈពេល៩០(កៅសិប)ថ្ងៃ។

## ជំហានទី៤
## ការរៀបចំសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី

**ប្រការ ១៦.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវគិតគូរពិចារណាលើចក្ខុវិស័យនិងយុទ្ធសាស្ត្រសរុបសម្រាប់ការអភិវឌ្ឍរូបវន្ត និងកំណត់អំពីប្រភេទនៃការប្រើប្រាស់ដី ដែលក្នុងនោះមានប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់ ព្រមទាំងបង្ហាញអំពីទម្រង់ បណ្តាញហេដ្ឋារចនាសម្ព័ន្ធនិងគមនាគមន៍សំខាន់ៗនៃក្រុង ស្រុក ខណ្ឌព្រមទាំងការធ្វើសមាហរណកម្មក្រុង ស្រុក ខណ្ឌ ជាមួយតំបន់ជុំវិញសម្រាប់ពេលអនាគតដែលមានលក្ខណៈសមស្របតាមស្ថានភាពនិងសក្តានុពលជាក់ស្តែងរបស់ក្រុង ស្រុក ខណ្ឌ។

ជំហាននេះ គឺជាជំហានមានសារៈសំខាន់ណាស់ក្នុងការជំរុញការអភិវឌ្ឍ ត្រូវបង្ហាញពីអត្តសញ្ញាណនិងវប្បធម៌ក្រុង ស្រុក ខណ្ឌ ដែលជាកន្លែងរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋានយូរអង្វែង។ ការអភិវឌ្ឍត្រូវដើរទន្ទឹមនឹងការរក្សានូវកេរមរតកដ៏ថ្លៃថ្លារបស់ក្រុង ស្រុក ខណ្ឌ ការពារបរិស្ថាន និងការធានាស្ថេរភាពនៃធនធានធម្មជាតិឲ្យគង់វង្សយូរអង្វែងសម្រាប់មនុស្សជំនាន់ក្រោយ។

ការពិចារណាអំពីការបែងចែកតំបន់ប្រើប្រាស់ដីនិងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ត្រូវផ្អែកទៅលើលទ្ធផលនៃការសិក្សាអំពីកំណើនប្រជាសាស្ត្រ និងតម្រូវការនៃសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន។ល។ ដែលអាចគណនាឬព្យាករណ៍បានតាមរយៈរូបមន្ត ឬទិន្នន័យ ឬការសិក្សាតាមបែបវិទ្យាសាស្ត្រផ្សេងៗទៀតដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ មានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ។

**ប្រការ ១៧.-**

ក្នុងជំហាននេះ ការរៀបចំប្លង់គោលប្រើប្រាស់ដី ត្រូវសម្របសម្រួលជាមួយគោលនយោបាយ យុទ្ធសាស្ត្រ និងបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធជាធរមាន និងគម្រោងផែនការដែលមានស្រាប់។

រាល់ការប្រើប្រាស់ពណ៌និងនិមិត្តសញ្ញាដែលប្រើប្រាស់ក្នុងសន្លឹកប្លង់ទាំងអស់ត្រូវធ្វើតាមសេចក្តីសម្រេចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការដាក់ឲ្យប្រើប្រាស់បទដ្ឋានតំណាងនិងចំណាំសញ្ញា

សម្គាល់សម្រាប់អនុវត្តក្នុងគម្រោងរៀបចំប្លង់គោលប្រើប្រាស់ដីនៅកម្ពុជា ដែលត្រូវបានកំណត់ដោយសេចក្តីសម្រេចដោយឡែក។

ជំហានទី៤នេះ មានរយៈពេល១២០(មួយរយម្ភៃ)ថ្ងៃ។

## ជំហានទី៥
## ការប្រមូលធាតុចូលនិងការកែសម្រួលបឋម

**ប្រការ ១៨.-**

ការប្រមូលធាតុចូលត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំ ឬសិក្ខាសាលា ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។

ធាតុចូលដែលទទួលបានពីភាគីពាក់ព័ន្ធ ត្រូវយកមកពិនិត្យ ពិចារណា កែសម្រួល និងបំពេញបន្ថែមស្របតាមលក្ខណៈបច្ចេកទេសនិងស្ថានភាពជាក់ស្តែងនៃភូមិសាស្ត្រនីមួយៗ ក្នុងគោលបំណងរៀបចំប្លង់គោលប្រើប្រាស់ដីឲ្យកាន់តែចំទិសដៅ និងអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

ជំហានទី៥នេះ មានរយៈពេល៩០(កៅសិប)ថ្ងៃ។

## ជំហានទី៦
## ការបិទផ្សាយជាសាធារណៈ

**ប្រការ ១៩.-**

ការបិទផ្សាយជាសាធារណៈគឺជាការផ្សព្វផ្សាយនូវលទ្ធផលបឋមនៃការរៀបចំប្លង់គោលប្រើប្រាស់ដី ដើម្បីទទួលសំណើ ព្រមទាំងការតវ៉ាផ្សេងៗ។ មន្ត្រីជំនាញដែលប្រចាំការនៅទីតាំងបិទផ្សាយមានភារកិច្ចពន្យល់នូវសំណួរនិងការងឿងឆ្ងល់ទាំងឡាយរបស់សាធារណជនចំពោះសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដីដែលនឹងត្រូវអនុម័តក្រោយពេលបិទផ្សាយរួច។

**ប្រការ ២០.-**

ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបិទផ្សាយជាសាធារណៈនៅសាលាក្រុង ឬ ស្រុក ឬ ខណ្ឌ ផ្សព្វផ្សាយតាមគេហទំព័រផ្លូវការ និងតាមរយៈទូរទស្សន៍ វិទ្យុ។ល។ នៅទីកន្លែងបិទផ្សាយ ត្រូវមានក្រុមការងារនៅប្រចាំការដើម្បីពន្យល់និងកត់ត្រារាល់មតិ សំណើ និងការតវ៉ាផ្សេងៗរបស់សាធារណជន។ ការបិទផ្សាយជាសាធារណៈត្រូវធ្វើក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីបានបញ្ចប់ការបិទផ្សាយជាសាធារណៈ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំសំណុំឯកសាររួមមាន៖ របាយការណ៍បូកសរុបលទ្ធផលនៃការបិទផ្សាយ មតិយោបល់របស់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ និងសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី ដើម្បីផ្ញើជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ពិនិត្យ ផ្តល់យោបល់ និងបញ្ជូនមកគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដើម្បីពិនិត្យនិងផ្តល់អនុសាសន៍មុននឹងធ្វើការកែសម្រួលចុងក្រោយ។

ក្នុងករណីមានបណ្តឹងតវ៉ាផ្សេងៗពាក់ព័ន្ធដល់សេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី មន្ត្រីជំនាញដែលនៅប្រចាំការនៅទីកន្លែងបិទផ្សាយនោះ ត្រូវខិតខំសម្រុះសម្រួលនិងពន្យល់ដល់សាមីអ្នកប្តឹងតវ៉ានោះ។

ក្នុងករណីដែលមិនអាចសម្រុះសម្រួលបាន មន្ត្រីជំនាញត្រូវធ្វើរបាយការណ៍ជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីសម្រុះសម្រួលនិងពន្យល់បន្ថែមដល់សាមីអ្នកប្តឹងតវ៉ា ដើម្បី

លើកហេតុផលបច្ចេកទេស ច្បាប់ សេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌ ដើម្បីផលប្រយោជន៍របស់ប្រជាជនភាគច្រើននៅក្រុង ស្រុក ខណ្ឌ។

ក្នុងករណីដែលអ្នកប្តឹងតវ៉ានៅតែមិនព្រមទទួលយកនូវការសម្រុះសម្រួលខាងលើនេះ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ដោយភ្ជាប់នូវជម្រើសនៃដំណោះស្រាយជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ពិនិត្យនិងសម្រេចបញ្ជូនទៅគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិដើម្បីពិនិត្យនិងសម្រេចចុងក្រោយ។

ជំហានទី៦នេះមានរយៈពេល៦០(ហុកសិប)ថ្ងៃ។ ក្នុងករណីមានបណ្តឹងតវ៉ាផ្សេងៗ រយៈពេល៦០(ហុកសិប)ថ្ងៃនេះអាចត្រូវបានបន្ថែមរយៈពេលស្របតាមទំហំការងារជាក់ស្តែង ដែលត្រូវបានកំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

## ជំហានទី៧
## ការកែសម្រួលចុងក្រោយ

**ប្រការ ២១.-**

ការកែសម្រួលចុងក្រោយ ត្រូវធ្វើឡើងនៅពេលទទួលបានការសម្រេចពីគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដោយយោងទៅលើរបាយការណ៍របស់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ និងមតិយោបល់របស់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត និងដោយផ្អែកទៅលើទិដ្ឋភាពបច្ចេកទេស ច្បាប់ សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន វប្បធម៌ និងប្រពៃណីរស់នៅរបស់ប្រជាពលរដ្ឋនៅក្រុង ស្រុក ខណ្ឌ។

ក្រោយពីការកែសម្រួលចុងក្រោយរួចហើយ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនឯកសារទៅគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ តាមរយៈគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ដើម្បីសម្រេចដាក់ឲ្យប្រើប្រាស់ជាផ្លូវការ។

ឯកសារខាងលើនេះត្រូវផ្ញើជូន៖

- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ នៃសាមីប្លង់គោលប្រើប្រាស់ដី ដើម្បីអនុវត្ត
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលមានទីតាំងជាប់ព្រំក្រុង ស្រុក ខណ្ឌ សាមីប្លង់គោលប្រើប្រាស់ដី ដើម្បីសហការអនុវត្ត
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ដើម្បីតាមដានការអនុវត្ត
- រក្សាទុកមួយច្បាប់នៅគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដើម្បីតាមដានការអនុវត្ត
- ទីស្តីការគណៈរដ្ឋមន្ត្រីនិងក្រសួងមហាផ្ទៃ ដើម្បីជូនជ្រាបនិងរក្សាទុកជាឯកសារ។

ជំហានទី៧នេះ មានរយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ។

## ជំហានទី៨
## ការរៀបចំគម្រោងអាទិភាព

**ប្រការ ២២.-**

ការអនុវត្តគម្រោងត្រូវធ្វើទៅតាមលំដាប់អាទិភាពដែលបានសម្រេចជាផ្លូវការ។

គម្រោងអាទិភាពជាប្រភេទនៃប្លង់លម្អិតនគរូបនីយកម្មដែលមានសារៈសំខាន់សម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដី និងបង្កលក្ខណៈងាយស្រួលដល់អាជ្ញាធរមូលដ្ឋានក្នុងការបញ្ចូលគម្រោងទាំងនេះក្នុងផែនការស្នើសុំថវិកា ដើម្បីអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនទៅតាមលំដាប់អាទិភាព។

គម្រោងអាទិភាព ត្រូវបែងចែកឲ្យបានច្បាស់រវាងហេដ្ឋារចនាសម្ព័ន្ធមានស្រាប់និងហេដ្ឋារចនាសម្ព័ន្ធគ្រោងថ្មី។ ចំពោះហេដ្ឋារចនាសម្ព័ន្ធគ្រោងថ្មី ត្រូវបង្ហាញនៅលើប្លង់ដែលងាយស្រួលយល់ ហើយធ្វើចំណាត់ថ្នាក់ទៅតាមប្រភេទហេដ្ឋារចនាសម្ព័ន្ធដែលត្រូវកសាងរយៈពេលខ្លី រយៈពេលមធ្យមនិងរយៈពេលវែង (គម្រោងថ្មីអាចរៀបចំនៅលើទីតាំងថ្មី ឬអាចរៀបចំកែលម្អនៅលើទីតាំងចាស់)។ បន្ទាប់មកយកគម្រោងនីមួយៗរៀបតាមលំដាប់អាទិភាពនៅក្នុងបញ្ជីមួយ ដោយភ្ជាប់ជាមួយនឹងការបរិយាយពីមូលហេតុនៃការធ្វើចំណាត់ថ្នាក់នេះ ព្រមទាំងតម្លៃប៉ាន់ស្មាននៃគម្រោងនីមួយៗ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

ជំហានទី៨នេះ មានរយៈពេល៦០(ហុកសិប)ថ្ងៃ។

## ជំហានទី៩
## ការសម្រេចលើប្លង់គោលប្រើប្រាស់ដី

**ប្រការ ២៣.-**

ការសម្រេចលើសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី មានអត្ថប្រយោជន៍ក្នុងការធ្វើឲ្យមានតម្លៃជាផ្លូវការនិងជាមូលដ្ឋានបង្អែក ក្នុងការអនុវត្តជាក់ស្តែងប្រកបដោយប្រសិទ្ធភាពនិងតម្លាភាព។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី ព្រមទាំងសំណុំឯកសារពាក់ព័ន្ធ(របាយការណ៍បច្ចេកទេស ប្លង់នានា គម្រោងអាទិភាព ឯកសារឧបសម្ព័ន្ធនានា...)ក្នុងរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃ ដើម្បីដាក់ជូន៖

១. ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ពិនិត្យនិងឯកភាពក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ។

២. គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ពិនិត្យនិងឯកភាពក្នុងរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃ។

៣. ក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យនិងឯកភាពក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ។

៤. គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ពិនិត្យនិងសម្រេចដាក់ឲ្យប្រើប្រាស់ជាផ្លូវការក្នុងរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃ។

ជំហានទី៩នេះ មានរយៈពេលសរុបចំនួន១៥០(មួយរយហាសិប)ថ្ងៃ។

## ផ្នែកទី២
## ការរៀបចំផែនការប្រើប្រាស់ដី

**ប្រការ ២៤.-**

ផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវមានទំហំការងារអប្បបរមាដូចខាងក្រោម៖

១.ការប្រមូលនិងវិភាគទិន្នន័យ: ត្រូវប្រមូលនិងវិភាគទិន្នន័យរូបវន្ត នគរូបនីយកម្ម ការប្រើប្រាស់ដី សំណង់លំនៅឋាន សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន វប្បធម៌ ធនធានធម្មជាតិ ប្លង់និងរូបភាព។ល។

២.ការកំណត់យុទ្ធសាស្ត្រ: ត្រូវកំណត់យុទ្ធសាស្ត្រឲ្យស្របតាមប្លង់គោលប្រើប្រាស់ដី។

៣.គំនូសប្លង់ក្នុងផែនការប្រើប្រាស់ដី មានដូចជា៖

៣.១.ប្លង់សម្រង់ទិន្នន័យស្ថានភាពបច្ចុប្បន្ន

-ប្លង់បង្ហាញទីតាំង

-ប្លង់បង្ហាញព្រំប្រទល់សម្រាប់រៀបចំផែនការប្រើប្រាស់ដី

-ប្លង់ដង់ស៊ីតេប្រជាជន

-ប្លង់កំណត់ប្រភេទប្រើប្រាស់ដី

-ប្លង់កំណត់តំបន់ប្រើប្រាស់ដី

-ប្លង់បណ្តាញហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈ

-ប្លង់លំហសាធារណៈនិងផ្ទៃបៃតង

-ប្លង់ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍

-ប្លង់សន្ទស្សន៍ប្រើប្រាស់ដី

-ប្លង់ឆ្លាតម្លាតសំណង់និងប្លង់តម្រង់ជួរ

-ប្លង់កំណត់កម្ពស់សំណង់

-ប្លង់សរុប។

៣.២.ប្លង់អនាគតកាលមានដូចជា៖

-ប្លង់ដង់ស៊ីតេប្រជាជន

-ប្លង់បែងចែកតំបន់ប្រើប្រាស់ដី

-ប្លង់បណ្តាញហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈ

-ប្លង់លំហសាធារណៈនិងផ្ទៃបៃតង

-ប្លង់បង្ហាញពីទិសដៅប្រើប្រាស់ដី

-ប្លង់ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍

-ប្លង់សន្ទស្សន៍ប្រើប្រាស់ដី

-ប្លង់ឆ្លាតម្លាតសំណង់និងប្លង់តម្រង់ជួរ

-ប្លង់កំណត់កម្ពស់សំណង់

-ប្លង់សរុប។

៤.បទបញ្ញាប្រើប្រាស់ដី ការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់គ្រប់ប្រភេទ។

៥.ឯកសារនិងឧបសម្ព័ន្ធ។

**ប្រការ ២៥.-**

ការរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់អំពីប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី បទបញ្ញានៃការប្រើប្រាស់ដីជាក់ស្តែង ការសាងសង់ ការអភិវឌ្ឍដីនិងការអភិរក្សក្នុងតំបន់នីមួយៗ។ ការរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ក៏ត្រូវកំណត់អំពីបណ្តាញគមនាគមន៍និងការធ្វើសមាហរណកម្ម ព្រមទាំងកំណត់អំពីបទដ្ឋានបច្ចេកទេសនៃការសាងសង់ (កំណត់កម្ពស់អគារ ប្លង់តម្រង់ជួរ ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ សន្ទស្សន៍ប្រើប្រាស់ដី និងផ្ទៃសួន(សួនជ្រាបទឹកនិងសួនមិនជ្រាបទឹក...)) ស្របតាមចក្ខុវិស័យ យុទ្ធសាស្ត្រ និងប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

ការបែងចែកតំបន់ប្រើប្រាស់ដីក្នុងប្រភេទដីអាចសាងសង់បាន រួមមាន តំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់ដឹកជញ្ជូន តំបន់សេវាកម្មទេសចរណ៍ តំបន់រដ្ឋបាលនិងសេវាសាធារណៈ តំបន់លំហសាធារណៈនិងផ្ទៃបៃតង តំបន់វប្បធម៌និងសាសនា តំបន់ចម្រុះ និងតំបន់ផ្សេងៗមួយចំនួនទៀត ស្របតាមភូមិសាស្ត្រជាក់ស្តែង។ ការបែងចែកតំបន់ប្រើប្រាស់ដីក្នុងប្រភេទដីកម្រិតការសាងសង់ រួមមាន តំបន់កសិកម្ម តំបន់ព្រៃឈើ តំបន់ធនធានទឹក តំបន់ការពារ និងតំបន់ផ្សេងៗមួយចំនួនទៀត ស្របតាមភូមិសាស្ត្រជាក់ស្តែង។

ផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ មានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ។

**ប្រការ ២៦.-**

ការរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវគោរពតាមគោលការណ៍ដូចមានចែងក្នុងប្រការ៥ នៃសេចក្តីសម្រេចនេះ និងត្រូវអនុវត្តដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ។

នីតិវិធីនិងដំណើរការនៃការរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមជំហានដូចនីតិវិធី និងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌដែរ។

## ផ្នែកទី៣
## ការរៀបចំប្លង់លម្អិតនគរូបនីយកម្ម

**ប្រការ ២៧**

ប្លង់លម្អិតនគរូបនីយកម្ម គឺជាប្លង់វិលេចទីតាំងនៃតំបន់ណាមួយក្នុងក្រុង ស្រុក ខណ្ឌ ឬជាគម្រោងអភិវឌ្ឍក្រុង ស្រុក ខណ្ឌ ដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររូបវន្តលម្អិតនៃការរៀបចំផ្នែក ទីតាំង ឬតំបន់ប្រើប្រាស់ដីណាមួយ ឬច្រើននៃទីក្រុងដែលមានជាអាទិ៍ ការបង្ហាញអំពីការរៀបចំ ការរចនា ទម្រង់ រូបរាង និងសោភណភាពនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សម្រាប់ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ តាមរយៈគំនូរ ឬរូបសំណាក។ ប្លង់លម្អិតនគរូបនីយកម្ម ត្រូវគោរពតាមផែនការប្រើប្រាស់ដី។

ប្លង់លម្អិតនគរូបនីយកម្ម មានទំហំការងារអប្បបរមាដូចខាងក្រោម៖

-ប្លង់បង្ហាញទីតាំង
-ប្លង់សរុបដោយមានកំណត់ព្រំប្រទល់
-ប្លង់លម្អិតការប្រើប្រាស់ដី
-ប្លង់បណ្តាញផ្លូវថ្នល់
-ប្លង់លំហសាធារណៈនិងផ្ទៃបៃតង
-ប្លង់សន្ទស្សន៍ប្រើប្រាស់ដី
-ប្លង់ផលធៀបក្រឡាផ្ទៃបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍
-ប្លង់សួនច្បារដោយដីជ្រាបទឹកនិងផ្ទៃបៃតង
-ប្លង់ឆ្លាតម្លាតសំណង់និងប្លង់តម្រង់ជួរ
-ប្លង់កំណត់កម្ពស់សំណង់
-ប្លង់គំហើញសំណង់និងរចនាសម្ព័ន្ធ
-ប្លង់នេត្រាទស្សន៍ ឬ គំរូសំណាក
-បទប្បញ្ញត្តិនគរូបនីយកម្ម។

## ផ្នែកទី៤
## ការរៀបចំសិក្ខាសាលាទទួលធាតុចូល

**ប្រការ ២៨.-**

ក្នុងដំណើរការរៀបចំប្លង់គោលប្រើប្រាស់ដីនិង/ឬផែនការប្រើប្រាស់ដី ត្រូវរៀបចំសិក្ខាសាលានៅទីតាំងគម្រោងដើម្បីទទួលធាតុចូល ឲ្យបានយ៉ាងតិច៣(បី)លើក មានជាអាទិ៍៖

១. សិក្ខាសាលាផ្សព្វផ្សាយគម្រោងរៀបចំប្លង់គោលប្រើប្រាស់ដីនិង/ឬផែនការប្រើប្រាស់ដី ដល់ប្រជាពលរដ្ឋនិងភាគីពាក់ព័ន្ធនានាឲ្យបានដឹងឮ និងចូលរួមចំណែកក្នុងការផ្តល់ព័ត៌មាននិងទិន្នន័យដល់អ្នកជំនាញនៅជំហានបន្តបន្ទាប់ទៀតដើម្បីឈានដល់ការសម្រេចជោគជ័យ។ សិក្ខាសាលានេះ ត្រូវរៀបចំធ្វើឡើងក្រោយការចុះសិក្សាបឋមលើទីតាំង(ជំហានទី១)និងមានរយៈពេលយ៉ាងតិច១(មួយ)ថ្ងៃ។

២. សិក្ខាសាលាផ្ទៀងផ្ទាត់ទិន្នន័យដែលទទួលបានពីការចុះប្រមូលផ្ទាល់នៅមូលដ្ឋាន ទាំងទិន្នន័យបឋមនិងទិន្នន័យទី២។ សិក្ខាសាលានេះមានសារៈសំខាន់ក្នុងការបំពេញបន្ថែមទិន្នន័យ ព័ត៌មានក៏ដូចជាការកែតម្រូវទិន្នន័យព័ត៌មាន ឲ្យបានត្រឹមត្រូវដើម្បីជាមូលដ្ឋានក្នុងការវិភាគនិងការព្យាករណ៍សម្រាប់ពេលអនាគត។ សិក្ខាសាលានេះ ត្រូវរៀបចំធ្វើឡើងនៅពេលបញ្ចប់ការប្រមូលទិន្នន័យព័ត៌មាន និងការកំណត់ព្រំប្រទល់(ជំហានទី២) និងមានរយៈពេលយ៉ាងតិច១(មួយ)ថ្ងៃ។

៣. សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈដែលត្រូវធ្វើឡើងនៅទីតាំងគម្រោង ដើម្បីទទួលធាតុចូលពីភាគីពាក់ព័ន្ធ ក្នុងការរៀបចំនិងកែសម្រួលប្លង់គោលប្រើប្រាស់ដីនិង/ឬផែនការប្រើប្រាស់ដីឲ្យបានល្អ។ ក្នុងឱកាសសិក្ខាសាលានេះ គណៈកម្មាធិការអាចលើកឡើងនូវសំណូមពរដល់ភាគីពាក់ព័ន្ធឲ្យជួយផ្តល់ទិន្នន័យនិងព័ត៌មានបន្ថែមទៀត ក្នុងការបង្កើនភាពជាក់លាក់ក្នុងការវិភាគនិងការព្យាករណ៍ឲ្យចំទិសដៅនិងមានប្រសិទ្ធភាពខ្ពស់។ សិក្ខាសាលានេះ ត្រូវរៀបចំធ្វើឡើងនៅពេលបញ្ចប់ការរៀបចំសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដីនិង/ឬផែនការប្រើប្រាស់ដី(ជំហានទី៤) និងមានរយៈពេលយ៉ាងតិច១(មួយ)ថ្ងៃ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**ប្រការ ២៩.-**

លក្ខខណ្ឌដែលមានចែងក្នុងសេចក្តីសម្រេចនេះនឹងត្រូវយកទៅអនុវត្តចំពោះតែប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និង/ឬប្លង់លម្អិតនគរូបនីយកម្មដែលបានរៀបចំក្រោយពីថ្ងៃដែលសេចក្តីសម្រេចនេះចូលជាធរមាន។

ចំពោះប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និង/ឬប្លង់លម្អិតនគរូបនីយកម្ម ដែលកំពុងដំណើរការរៀបចំនិងបានរៀបចំហើយ ប៉ុន្តែមិនទាន់បានអនុម័តដាក់ឲ្យប្រើប្រាស់ ត្រូវបានអនុញ្ញាតឲ្យបន្តរៀបចំបញ្ចប់និងដាក់ស្នើសុំការអនុម័ត ឲ្យប្រើប្រាស់ជាផ្លូវការដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ត្រូវខិតខំជំរុញការរៀបចំបន្តបញ្ចប់ និងដាក់ស្នើសុំការអនុម័ត ឲ្យប្រើប្រាស់ជាផ្លូវការនូវប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និង/ឬប្លង់លម្អិតនគរូបនីយកម្ម នៅក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួនមិនឲ្យលើសពី២(ពីរ)ឆ្នាំ បន្ទាប់ពីសេចក្តីសម្រេចនេះចូលជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ ៣០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣១.-**

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ខែកក្កដាឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**អ៊ឹម ឈុនលឹម**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ
- សាលារាជធានី ខេត្ត
- ដូចប្រការ៣១
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃសេចក្ដីសម្រេចលេខ ០៤៦ សសរ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤
## ស្ដីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិង
## ផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

### នីតិវិធីនិងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដី
### និង/ឬផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ



ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ ០៤១សសរ ចុះថ្ងៃទី២២ ខែកក្កដាឆ្នាំ២០១៤
ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិង
ផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

ការគណនាឬព្យាករណ៍កំណើនប្រជាសាស្ត្រ

<u>វិធីសាស្ត្រទី១: គណនាចំនួនប្រជាជនតាមធម្មជាតិ</u>

$$\text{កំណើនប្រជាជននាពេលចុងក្រោយ} \times \left(\frac{\text{អត្រាកំណើនធម្មជាតិ}}{100} + 1\right)^{\text{ក}}$$

ក គឺជាផលដករវាងឆ្នាំចុងក្រោយ - ឆ្នាំមុន

ឧទាហរណ៍: យើងចង់គណនាចំនួនប្រជាជនឆ្នាំ២០០៩ ហើយគេមានតួលេខចំនួនប្រជាជនឆ្នាំ២០០៨ ចំនួន ១៣.៣៩៥.៦៨២នាក់ និងដឹងអត្រាកំណើន ១.៥៨%

តាមរូបមន្តខាងលើគេបាន៖

$$\text{ចំនួនប្រជាជនឆ្នាំ២០០៩} = \text{ចំនួនប្រជាជនឆ្នាំ២០០៨} \times \left(\frac{0.១៥៨}{១០០} + ១\right)^{១}$$

**ចំនួនប្រជាជនឆ្នាំ២០០៩ គឺ ១៣.៦០៧.៣៣៤នាក់**

<u>**វិធីសាស្ត្រទី២: គណនាចំនួនប្រជាជន**</u>

គណនាអត្រាកំណើនប្រចាំឆ្នាំ បែប Exponential

$$r = \frac{\log_e P^t - \log_e P_0}{t}$$

- $P_t = P_0 e^{rt}$
- $P_0$ ជាចំនួនប្រជាភាស្ត្រនៅឆ្នាំគោល
- $P_t$ ជាចំនួនប្រជាភាស្ត្រនៅឆ្នាំ t
- t ចំនួនឆ្នាំ រវាង $P_0$ និង $P_t$
- r អត្រាកំណើន។

ឧទាហរណ៍: យើងមានតួលេខចំនួនប្រជាជនឆ្នាំ១៩៩៨ ចំនួន ១១.៤៣៧.៦៥៦នាក់ និងចំនួនប្រជាជនឆ្នាំ២០០៨ ចំនួន ១៣.៣៩៥.៦៨២នាក់

$$r = \frac{\log_e(13,395,682) - \log_e(11,437,656)}{10}$$

ដោយ $\log_e(13,395,682) = 16.41044$ និង $\log_e(11,437,656) = 16.25242$

នាំឲ្យ $r = \dfrac{16.41044 - 16.25242}{10} = 0.0158$ ឬ 1.58%

ចំនួនប្រជាជនឆ្នាំ២០០៩ គឺ $P_{2009} = P_{2008}\,e^{0.0158*1}$ តែ $e^{0.0158*1} = 1.0159$

នាំឲ្យចំនួនប្រជាជនឆ្នាំ២០០៩ = ចំនួនប្រជាជនឆ្នាំ២០០៨ X 1.0159 = 13,609,044

**ដូច្នេះចំនួនប្រជាជនឆ្នាំ២០០៩ គឺ ១៣.៦០៩.០៤៤នាក់**

គម្លាតរវាងវិធីសាស្ត្រទី១ និងទី២ គឺខុសចំនួន ១.៧១០នាក់
សន្និដ្ឋានរូបមន្តទាំងពីរមានលក្ខណៈប្រហាក់ប្រហែលគ្នា។

<u>វិធីសាស្ត្រទី៣: យើងត្រូវការពត៌មានមួយចំនួនដើម្បីដាក់បញ្ចូលក្នុងកម្មវិធីកុំព្យូទ័រមានដូចខាងក្រោម:</u>

- ចំនួនប្រជាជនតាមក្រុមអាយុ៥ឆ្នាំ និងតាមភេទ
- អត្រាមរណភាព
- អាយុសង្ឃឹមរស់
- លទ្ធភាពបង្កើតកូនរបស់ស្ត្រី
- ចំនួនប្រជាជនដែលបម្លាស់ទីទាំងចេញ និងទាំងចូល
- ចុងក្រោយគឺយើង RUN Program

លទ្ធផលដែលគេបានគណនាគឺចំនួនប្រជាជនឆ្នាំ២០០៩ គឺ **១៤.០៨៥.៣២៨នាក់**
**គម្លាតរវាងវិធីសាស្ត្រទី៣ និងទី១ គឺ ៤៧៧.៩៩០នាក់**
**គម្លាតរវាងវិធីសាស្ត្រទី៣ និងទី២ គឺ ៤៧៦.២៨០០នាក់**

<u>សន្និដ្ឋាន</u>: វិធីសាស្ត្រទី៣មានលក្ខណៈស្មុគស្មាញ ប៉ុន្តែមានការសិក្សាស៊ីជម្រៅជាង ហើយភាគច្រើនប្រព័ន្ធ UN គេប្រើវិធីសាស្ត្រនេះច្រើនជាង។ វិទ្យាស្ថានជាតិស្ថិតិបានផលិតរួចគឺ Population Projection ដែលមានដល់ថ្នាក់ខេត្តផងដែរ។

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ ០៤១ សសរ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤
ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិង
ផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

ការរៀបចំគម្រោងអភិវឌ្ឍន៍និងផែនការសកម្មភាពតាមលំដាប់អាទិភាព




រូបភាពទី១: ប្លង់បង្ហាញពីគម្រោងអាទិភាពនិងគម្រោងអនុវត្ត ក្នុងទីប្រជុំជនអន្លង់វែង

តារាងទី១: បញ្ជីគម្រោងអភិវឌ្ឍនិងផែនការសកម្មភាពតាមលំដាប់អាទិភាព

<table>
<tr><td rowspan="2">ឈ្មោះគម្រោង: គម្រោងសាងសង់និងកែលម្អផ្លូវយុទ្ធសាស្ត្រការពារដីកសិកម្ម</td><td>អាទិភាព</td></tr>
<tr><td>ក</td></tr>
<tr><td colspan="2">ប្រវត្តិគម្រោង</td></tr>
<tr><td colspan="2">ទីប្រជុំជន គឺជាទីតាំងនៃកំណើនប្រជាជន សេដ្ឋកិច្ច និងសង្គមកិច្ច ដែលជាមូលហេតុនៃការរីករាលដាលនៃទីក្រុងទៅតំបន់ជាយក្រុង។ បាតុភាពនេះ បានធ្វើឱ្យអាជ្ញាធរមូលដ្ឋានលំបាកក្នុងការគ្រប់គ្រងរវាងប្រភេទដីអាចសាងសង់បាន និងប្រភេទដីគ្រប់គ្រងការសាងសង់។</td></tr>
<tr><td colspan="2">បរិយាយគម្រោង</td></tr>
<tr><td colspan="2"><u>សមាសភាគគម្រោង</u> ៖ ផ្លូវខ្សែក្រវាត់តំបន់នគរូបនីយកម្ម និងប្រព័ន្ធលូចំនួន០១ខ្សែ មានប្រវែងប្រមាណ២០គ.ម<br><u>រយៈពេលអនុវត្តគម្រោង</u>៖ គួរត្រូវបានអនុវត្ត ចាប់ពីឆ្នាំ២០១២-២០១៣<br><u>ទីតាំងគម្រោង</u> ៖ ស្ថិតនៅក្នុងទីប្រជុំជនអន្លង់វែង</td></tr>
<tr><td colspan="2">អង្គភាពអនុវត្តគម្រោង</td></tr>
<tr><td colspan="2">មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តឧត្តរមានជ័យ និងសាលាស្រុកអន្លង់វែង</td></tr>
</table>

| ឈ្មោះគម្រោងៈ គម្រោងសាងសង់និងកែលម្អផ្លូវយុទ្ធសាស្ត្រការពារប្រភពទឹក | អាទិភាព<br>ខ |
|---|---|

**ប្រវត្តិគម្រោង**

ប្រភពទឹកគឺជាទីតាំងដែលបង្កលក្ខណៈងាយស្រួលខ្លាំងដល់ការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ តាមរយៈការផ្គត់ផ្គង់នូវប្រភពទឹកសម្រាប់បរិភោគ ការនេសាទ ការស្រោចស្រព។ល។ ការសាងសង់លំនៅឋាននៅជាប់មាត់ទឹកជារឿយៗ តែងតែជះឥទ្ធិពលមិនល្អដល់ប្រភពទឹក តាមរយៈការបង្ហូរទឹកកខ្វក់ ការចាក់ដីលុបទន្រ្ទានផ្ទៃទឹកយកកន្លែងសាងសង់សំណង់បណ្តោះអាសន្ន...។

**បរិយាយគម្រោង**

<u>សមាសភាគគម្រោង</u> ៖ ផ្លូវខ្សែក្រវាត់បឹងអន្លង់វែង និងប្រព័ន្ធលូចំនួន០១ខ្សែ មានប្រវែងប្រមាណ១១គ.ម
ផ្លូវអមសងខាងអូរ ប្រឡាយ និងប្រព័ន្ធលូចំនួន០៤ខ្សែ មានប្រវែងប្រមាណ២០គ.ម
<u>រយៈពេលអនុវត្តគម្រោង</u>៖ គួរត្រូវបានអនុវត្ត ចាប់ពីឆ្នាំ២០១៣-២០១៥
<u>ទីតាំងគម្រោង</u> ៖ ស្ថិតនៅក្នុងទីប្រជុំជនអន្លង់វែង

**អង្គភាពអនុវត្តគម្រោង**

**មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តឧត្តរមានជ័យ និងសាលាស្រុកអន្លង់វែង**

| ឈ្មោះគម្រោងៈ គម្រោងសាងសង់ និងកែលម្អផ្លូវខ្សែក្រវាត់ទីប្រជុំជន | អាទិភាព<br>គ |
|---|---|

**ប្រវត្តិគម្រោង**

ទីប្រជុំជន ត្រូវបានបង្កើតឡើងដោយមានព្រំប្រទល់ច្បាស់លាស់ ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច ប្រជាសាស្ត្រ និងការងារធ្វើផែនការ។ ការងារអនុវត្តជាក់ស្តែងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអង្គភាពជំនាញ តែងតែមានភាពមិនច្បាស់លាស់រវាងព្រំប្រទល់ដែលមាននៅលើផែនទី និងនៅលើដីជាក់ស្តែង។

**បរិយាយគម្រោង**

<u>សមាសភាគគម្រោង</u> ៖ ផ្លូវខ្សែក្រវាត់ទីប្រជុំជន និងប្រព័ន្ធលូចំនួន០១ខ្សែ មានប្រវែងប្រមាណ២២គ.ម
<u>រយៈពេលអនុវត្តគម្រោង</u>៖ គួរត្រូវបានអនុវត្ត ចាប់ពីឆ្នាំ២០១៥-២០១៦
<u>ទីតាំងគម្រោង</u> ៖ ស្ថិតនៅក្នុងទីប្រជុំជនអន្លង់វែង

**អង្គភាពអនុវត្តគម្រោង**

**មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តឧត្តរមានជ័យ និងសាលាស្រុកអន្លង់វែង**

| ឈ្មោះគម្រោងៈ គម្រោងសាងសង់ និងកែលម្អផ្លូវមេសំខាន់ៗ | អាទិភាព<br>ឃ |
|---|---|

**ប្រវត្តិគម្រោង**

ទីប្រជុំជន គឺជាទីតាំងដែលអាចរស់នៅបាន ធ្វើចរាចរណ៍បាន ធ្វើការបាន និងសម្រាកកម្សាន្តបាន ដែលត្រូវការជាចាំបាច់នូវបណ្តាញផ្លូវថ្នល់ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា។ បណ្តាញផ្លូវថ្នល់ ត្រូវបានកើតចេញពីផ្លូវវៀរវង្វេង ឬផ្លូវរទេះ ដែលមានលក្ខណៈពុំសមស្របតាមបច្ចេកទេស និងពុំមានចំណាត់ថ្នាក់ត្រឹមត្រូវ។

*បរិយាយគម្រោង*

<u>**សមាសភាគគម្រោង**</u> ៖ ផ្លូវមេសំខាន់ និងប្រព័ន្ធលូចំនួន០៤ខ្សែ មានប្រវែងប្រមាណ១៧,២គ.ម
<u>**រយៈពេលអនុវត្តគម្រោង**</u>៖ គួរត្រូវបានអនុវត្ត ចាប់ពីឆ្នាំ២០១៦-២០១៨
<u>**ទីតាំងគម្រោង**</u> ៖ ស្ថិតនៅក្នុងទីប្រជុំជនអន្លង់វែង

*អង្គភាពអនុវត្តគម្រោង*

**មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តឧត្តរមានជ័យ និងសាលាស្រុកអន្លង់វែង**

**ឈ្មោះគម្រោង: គម្រោងសាងសង់ និងកែលម្អផ្លូវឃុំ សង្កាត់**

**អាទិភាព:** ង

*ប្រវត្តិគម្រោង*

ទីប្រជុំជន គឺជាទីតាំងដែលអាចរស់នៅបាន ធ្វើចរាចរណ៍បាន ធ្វើការបាន និងសម្រាកកម្សាន្តបាន ដែលត្រូវការជាចាំបាច់នូវបណ្តាញផ្លូវថ្នល់ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា។ បណ្តាញផ្លូវថ្នល់ ត្រូវបានកើតចេញពីផ្លូវថ្មើរជើង ឬ ផ្លូវរទេះ ដែលមានលក្ខណៈពុំសមស្របតាមបច្ចេកទេស និងពុំមានចំណាត់ថ្នាក់ត្រឹមត្រូវ។

*បរិយាយគម្រោង*

<u>**សមាសភាគគម្រោង**</u> ៖ ផ្លូវឃុំ សង្កាត់ និងប្រព័ន្ធលូចំនួន០៦ខ្សែ មានប្រវែងប្រមាណ១២,២គ.ម
<u>**រយៈពេលអនុវត្តគម្រោង**</u>៖ គួរត្រូវបានអនុវត្ត ចាប់ពីឆ្នាំ២០១៨-២០២០
<u>**ទីតាំងគម្រោង**</u> ៖ ស្ថិតនៅក្នុងទីប្រជុំជនអន្លង់វែង

*អង្គភាពអនុវត្តគម្រោង*

**មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តឧត្តរមានជ័យ និងសាលាស្រុកអន្លង់វែង**

**ឈ្មោះគម្រោង: គម្រោងរៀបចំទីលានចាក់សំរាម និងអាងប្រព្រឹត្តកម្មទឹកកខ្វក់**

**អាទិភាព:** គ

*ប្រវត្តិគម្រោង*

កំណើនប្រជាជន បានធ្វើឲ្យកើនឡើងនូវបរិមាណសំណល់រឹង និងសំណល់រាវ។ ដូច្នេះ កង្វះខាតការគ្រប់គ្រងឲ្យបានល្អនូវសំណល់រឹង និងសំណល់រាវ បានជះឥទ្ធិពលមិនល្អដល់បរិស្ថាន និងការរស់នៅរបស់ប្រជាពលរដ្ឋ។

*បរិយាយគម្រោង*

<u>**សមាសភាគគម្រោង**</u> ៖ ទីលានចាក់សំរាម និងអាងប្រព្រឹត្តកម្មទឹកកង្វក់ចំនួន០២កន្លែង
<u>**រយៈពេលអនុវត្តគម្រោង**</u>៖ គួរត្រូវបានអនុវត្ត ចាប់ពីឆ្នាំ២០១២-២០១៣
<u>**ទីតាំងគម្រោង**</u> ៖ ស្ថិតនៅក្នុងទីប្រជុំជនអន្លង់វែង

*អង្គភាពអនុវត្តគម្រោង*

**មន្ទីរបរិស្ថាន និងសាលាស្រុកអន្លង់វែង**

ប្រភព ៖ ក្រុមការងាររៀបចំផែនការប្រើប្រាស់ដីទីប្រជុំជនអន្លង់វែង ឆ្នាំ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ/បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០២

# ស ំ រ េ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់រចនាសម្ព័ន្ធ បេសកកម្ម និង មុខងារ របស់គណៈកម្មការសុរិយោដី ។

**មាត្រា ២.-**

អនុក្រឹត្យនេះអនុវត្តចំពោះវិវាទ ដែលទាក់ទងនឹងអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីសុរិយោដី ។ ក្នុងករណីនេះ គណៈកម្មការសុរិយោដីមានសិទ្ធិសំរេចមុនគេក្នុងការទទួលស្គាល់ភោគីស្របច្បាប់ ។

## ជំពូកទី ២
## រចនាសម្ព័ន្ធ និង បេសកកម្ម

**មាត្រា ៣.-**

គណៈកម្មការសុរិយោដី ត្រូវមានបេសកកម្មដោះស្រាយវិវាទទាក់ទងនឹងអចលនវត្ថុ ដែលមិនទាន់បានចុះបញ្ជីសុរិយោដី ដូចតទៅ :

១.-វិវាទដែលកើតមាននៅក្រៅតំបន់វិនិច្ឆ័យ

២.-វិវាទ ដែលកើតមាននៅក្នុងតំបន់វិនិច្ឆ័យ និងដែលមិនអាចសម្រុះសម្រួលបានដោយគណៈកម្មការរដ្ឋបាល ។

**មាត្រា ៤.-**

គណៈកម្មការសុរិយោដី មានរចនាសម្ព័ន្ធដូចតទៅ :

១.-គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានអក្សរកាត់ថា **គ.ស.ស.ខ** មានទីតាំងនៅក្នុងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ។

២.-គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានអក្សរកាត់ថា **គ.ស.ខ.ក** មានទីតាំងនៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ។

៣.-គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានអក្សរកាត់ថា **គ.ស.ជ** មានទីតាំងនៅក្នុងទីស្តីការក្រសួង

រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានលេខាធិការដ្ឋាន ជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត។

## ជំពូកទី ៣
## គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ

**មាត្រា ៥ ..**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដឹកនាំដោយប្រធានមួយរូបដែលជាប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ហើយត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានមន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ជាសមាជិក។

ប្រធានគណៈកម្មការនេះ ត្រូវអញ្ជើញតំណាងអាជ្ញាធរដែនដីស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ ដែលពាក់ព័ន្ធ ឬ/និង ចាស់ព្រឹទ្ធាចារ្យនៅក្នុងមូលដ្ឋានឱ្យចូលរួមជាសមាជិកអាដហុក។

**មាត្រា ៦ ..**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានភារកិច្ចសម្រុះសម្រួលវិវាទ ដែលកើតមានឡើងនៅក្រៅតំបន់វិនិច្ឆ័យ។ ការសម្រុះសម្រួលវិវាទ ត្រូវអនុវត្តតាមទម្លាប់ប្រពៃណី និងបច្ចេកទេសសុរិយោដី។

## ជំពូកទី ៤
## ការសម្រុះសម្រួលនៅថ្នាក់ស្រុក ខណ្ឌ

**មាត្រា ៧ ..**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ទំរង់បែបបទនៃពាក្យបណ្តឹង។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវចុះបញ្ជី និងបើកសំណុំរឿងនៃពាក្យវិវាទដែលបានទទួល។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវពន្យល់អំពីនីតិវិធីដល់ភាគីវិវាទ និងសាកសួរថាតើភាគីវិវាទយល់ព្រមធ្វើការដោះស្រាយសម្រុះសម្រួលតាមនីតិវិធីនេះឬទេ ។

**មាត្រា ៨ ..**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវស៊ើបអង្កេតលើវិវាទ ។ ការស៊ើបអង្កេតរួមមាន ការបញ្ជាក់អំពីទីតាំងនៃក្បាលដី ដែលមានវិវាទ និងភាគីពាក់ព័ន្ធ និងអំពីកម្មវត្ថុនៃវិវាទ និងការប្រមូលឯកសារ ដែលមានចម្លើយរបស់សាក្សី និងពត៌មានទាក់ទងនឹងក្បាលដីមានវិវាទ ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវថតចម្លង និងបញ្ជាក់លើឯកសារចម្លងនោះ សំរាប់ទុកជាសំណុំរឿង និងប្រគល់ច្បាប់ដើមឱ្យភាគីវិវាទ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវកសាង និង បញ្ចូលឯកសារស៊ើបអង្កេតទៅក្នុងសំណុំរឿងវិវាទ។

**មាត្រា ៩ ..**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវសម្រុះសម្រួលវិវាទក្រៅពីករណី ដែលមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ ។

ការសម្រុះសម្រួលត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ១០ ..**

បន្ទាប់ពីការស៊ើបអង្កេត ប្រសិនបើឃើញថា វិវាទមិនអាចត្រូវបានដោះស្រាយដោយសមធម៌នៅថ្នាក់ស្រុក ខណ្ឌ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំរឿងវិវាទទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង តាមការយល់ឃើញផ្ទាល់របស់ប្រធាន ឬតាមសំណើរបស់ភាគីវិវាទទាំងសងខាង ចំពោះករណីដូចតទៅ :

(១) ជនម្នាក់ទាមទារដីច្រើនក្បាល ដែលជាកម្មវត្ថុនៃការប្តឹងទាមទាររបស់ភោគីតូចតាចមួយចំនួនដែរ។

(២) ភាគីម្ខាងនៃវិវាទ គឺជាអាជ្ញាធរមានឋានៈខ្ពស់ ។

(៣) ករណីមានវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។

(៤) វិវាទដែលពាក់ព័ន្ធនឹងដីសាធារណៈរបស់រដ្ឋ ។

**មាត្រា ១១ ..**

ប្រសិនបើការដោះស្រាយអាចសំរេចបានដោយមានការព្រមព្រៀងជាឯកច្ឆន្ទពីភាគីវិវាទ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ជូនគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ហើយត្រូវចម្លងជូនការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌមួយច្បាប់ ដើម្បីចាត់ផ្តើមដំណើរការ



Scanned with CamScanner

អនុវត្តនីតិវិធីនៃការចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួច ។

ប្រសិនបើការដោះស្រាយមិនអាចសំរេចបាន គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបញ្ជូនវិវាទ រួមជាមួយនឹងរបាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីការសម្រុះសម្រួលជូនគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

## ជំពូកទី ៥
## គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង

**មាត្រា ១២ .-**

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានសមាសភាពដូចខាងក្រោម :

-អភិបាល ឬ អភិបាលរងខេត្ត ក្រុង ជាប្រធាន

-ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត ក្រុង ជាសមាជិក

ឈ្មោះប្រធាន និងសមាជិកនៃគណៈកម្មការសុរិយោដីនេះ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ប្រធានគណៈកម្មការសុរិយោដីខេត្ត ក្រុង អាចអញ្ជើញតំណាងស្រុក ខណ្ឌ ឃុំ សង្កាត់ ឬមន្ទីរជុំវិញខេត្ត ក្រុង ដែលពាក់ព័ន្ធឱ្យចូលរួមជាសមាជិកអាដហុក ។

**មាត្រា ១៣ .-**

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានភារកិច្ចសម្រុះសម្រួលវិវាទដូចមានចែងក្នុងមាត្រា ១០ និង មាត្រា ១១ វាក្យខ័ណ្ឌទី ២ នៃអនុក្រឹត្យនេះ ។

សមាជិកគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

**មាត្រា ១៤ .-**

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានលេខាធិការដ្ឋានមួយ ជាលេខាធិការ និងជាអង្គភាពស៊ើបអង្កេត ។

មន្ត្រីបំរើការងារនៅលេខាធិការដ្ឋាន ជាមន្ត្រីមុខងារសាធារណៈ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណើរបស់គណៈកម្មការសុរិយោដី ។



CS Scanned with CamScanner

លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានមុខងារ ភារកិច្ចដូចតទៅ :

-ទទួលសំណុំរឿងវិវាទពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និង រាល់ពាក្យបណ្ដឹងទាក់ទងនឹងវិវាទដីធ្លី

-ស៊ើបអង្កេតតាមការណែនាំរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង

-ធ្វើរបាយការណ៍ អំពីលទ្ធផលនៃការស៊ើបអង្កេត

-រៀបចំការប្រជុំរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង

-ធ្វើកំណត់ហេតុ អំពីដំណើរការសម្រុះសម្រួល និងធ្វើរបាយការណ៍អំពីលទ្ធផល នៃការសម្រុះសម្រួល

-បញ្ជូនកំណត់ហេតុ និងរបាយការណ៍ទាំងនេះ ទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ ក្នុងករណីការសម្រុះសម្រួលបានសំរេច ត្រូវផ្ញើលទ្ធផលនៃការសម្រុះសម្រួលទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ

-រៀបចំ និងតំកល់ទុកឯកសារ ។

## ជំពូកទី ៦

## ការសម្រុះសម្រួលនៅថ្នាក់ខេត្ត ក្រុង

**មាត្រា ១៥ ..**

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ពុំមានសិទ្ធិសំរេចលើករណីវិវាទណាមួយទេ ប៉ុន្តែអាចបញ្ចប់វិវាទបាន ក្នុងករណីភាគីវិវាទទាំងអស់ព្រមព្រៀងគ្នាជាឯកច្ឆន្ទ ។

ក្នុងករណីដែលវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង សំណុំរឿងវិវាទនេះ ត្រូវបានបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

**មាត្រា ១៦ ..**

ប្រសិនបើការសម្រុះសម្រួលអាចសំរេចបាន គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវផ្ញើលទ្ធផលជូនការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ដើម្បីចាប់ផ្ដើមដំណើរការអនុវត្តនីតិវិធីនៃការចុះបញ្ជីក្បាលដី ដែលបានដោះស្រាយរួច ។



Scanned with CamScanner

ប្រសិនបើការដោះស្រាយមិនអាចសំរេចបាន គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវបញ្ជូនសំណុំរឿងវិវាទ រួមជាមួយនឹងរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីការសម្រុះសម្រួល ជូនគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

## ជំពូកទី ៧
## គណៈកម្មការសុរិយោដីថ្នាក់ជាតិ

**មាត្រា ១៧ ..**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសមាសភាពដូចខាងក្រោម :

- -រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន
- -រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ ជាសមាជិក
- -រដ្ឋលេខាធិការនៃទីស្ដីការគណៈរដ្ឋមន្ត្រី ជាសមាជិក

ឈ្មោះប្រធាន និងសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវតែងតាំងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចអញ្ជើញក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ឱ្យមកចូលរួមជាសមាជិកអាដហុក ។

**មាត្រា ១៨ ..**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសមត្ថកិច្ចចេញសេចក្ដីសំរេចលើវិវាទដីភោគៈ ដែលគណៈកម្មការសុរិយោដីថ្នាក់ក្រោម ឬគណៈកម្មការរដ្ឋបាលពុំអាចសម្រុះសម្រួលបានដូចមានចែងក្នុងមាត្រា ១៦ និងវិវាទដែលមានចែងក្នុងចំណុចទី ២ នៃមាត្រា ៣ នៃអនុក្រឹត្យនេះ ។

សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

**មាត្រា ១៩ ..**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានលេខាធិការដ្ឋានមួយ ជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត ។ លេខាធិការដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់ ដែលត្រូវ



Scanned with CamScanner

តែងតាំងដោយរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

មន្ត្រីបំរើការងារនៅលេខាធិការដ្ឋាន ជាមន្ត្រីមុខងារសាធារណៈ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណើរបស់គណៈកម្មការសុរិយោដី ។

លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានតួនាទីដូចតទៅ :

-ទទួលសំណុំរឿងវិវាទពីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងរាល់ពាក្យបណ្ដឹងទាក់ទងនឹងវិវាទដីធ្លី

-ស៊ើបអង្កេតតាមការណែនាំរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ

-ធ្វើរបាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេត

-រៀបចំការប្រជុំរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ

-ធ្វើកំណត់ហេតុអំពីសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការដោះស្រាយ

-បញ្ជូនកំណត់ហេតុ និងភស្តុតាងទាំងអស់ទៅតុលាការ នៅពេលមានការប្ដឹងតវ៉ាលើសេចក្ដីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិទៅតុលាការ

-រៀបចំ និងតំកល់ទុកឯកសារ ។

## ជំពូកទី ៨
## ការដោះស្រាយនៅថ្នាក់ជាតិ

**មាត្រា ២០ ..**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានយុត្តាធិការពេញលេញក្នុងការធ្វើសេចក្ដីសំរេចទទួលស្គាល់ភោគី ឬកម្មសិទ្ធិករស្របច្បាប់ ។

ប្រសិនបើភាគីវិវាទ មិនយល់ព្រមតាមសេចក្ដីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ភាគីវិវាទមានសិទ្ធិប្ដឹងទៅតុលាការ ដូចមានចែងក្នុងមាត្រា ២៣ នៃអនុក្រឹត្យនេះ ។

**មាត្រា ២១ ..**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវពិនិត្យឡើងវិញនូវរាល់ឯកសារទាំងអស់ដែលទាក់ទងនឹងវិវាទ ហើយប្រសិនបើយល់ឃើញថាចាំបាច់ អាចបញ្ជាឱ្យមានការស៊ើបអង្កេតបន្ថែមទៀត ពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងរៀបចំបើកសវនាការមុនពេលធ្វើសេចក្ដីសំរេចលើវិវាទ ។



Scanned with CamScanner

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវពិនិត្យដើម្បីបើកសវនាការអំពីវិវាទ តាមការស្នើសុំរបស់ភាគីណាមួយ ។

ក្នុងករណីដែលគណៈកម្មការសុរិយោដីថ្នាក់ជាតិធ្វើការពិគ្រោះយោបល់ជាមួយភាគីណាមួយ នោះភាគីផ្សេង១ទៀត មានសិទ្ធិទទួលបានការជូនដំណឹងជាមុន អំពីការពិគ្រោះយោបល់នេះ ដើម្បីមានវត្តមាននៅក្នុងការពិគ្រោះយោបល់ ប្រសិនបើគណៈកម្មការសុរិយោដីថ្នាក់ជាតិយល់ឃើញថាចាំបាច់ ។

**មាត្រា ២២ ..**

សេចក្ដីសំរេចត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសេចក្ដីសង្ខេបអំពីករណីវិវាទ និងហេតុផលលំអិតនៃការធ្វើសេចក្ដីសំរេច ។

**មាត្រា ២៣ ..**

ភាគីវិវាទ មានសិទ្ធិស្នើឱ្យមានការពិនិត្យឡើងវិញផ្នែកច្បាប់ លើការសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ដោយប្ដឹងទៅតុលាការក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃ ចាប់ពីថ្ងៃទទួលបានសេចក្ដីសំរេច ។

ប្រសិនបើតុលាការបញ្ជូនរឿងក្ដីទៅគណៈកម្មការសុរិយោដីវិញ ដោយហេតុថាគណៈកម្មការសុរិយោដីមិនបានអនុវត្តតាមនីតិវិធីសមស្រប ឬដោយមានវិវាទអំពីផលប្រយោជន៍ ឬដោយមិនបានផ្ដល់ហេតុផលសមរម្យ ឬដោយអនុវត្តហួសពីសមត្ថកិច្ចរបស់ខ្លួន នោះគណៈកម្មការសុរិយោដី ត្រូវចាត់វិធានការអនុវត្តតាមសំណូមពររបស់តុលាការ ។

ភាគីដែលស្នើសុំការពិនិត្យឡើងវិញផ្នែកច្បាប់ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីបណ្ដឹង ទៅលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ លេខាធិការដ្ឋាន ត្រូវធានាការពារសេចក្ដីសំរេចរបស់គណៈកម្មការសុរិយោដីចំពោះតុលាការ ។

តុលាការ ត្រូវផ្ញើច្បាប់ចម្លងនៃសាលក្រម ឬសាលដីកា ដែលបានចូលជាស្ថាពរ មកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដើម្បីចាត់ចែងដំណើរការអនុវត្តនីតិវិធីនៃការចុះបញ្ជីដី ។

ប្រសិនបើគ្មានបណ្ដឹងក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃ ដូចបានកំណត់នៅក្នុងមាត្រានេះ នោះសេចក្ដីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចាត់ទុកជាស្ថាពរ ។



Scanned with CamScanner

## ជំពូកទី ៩
## ការចុះបញ្ជី

**មាត្រា ២៤ ..**

បន្ទាប់ពីសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសុពលភាពអាចអនុវត្តបាន គណៈកម្ម-ការសុរិយោដីថ្នាក់ជាតិ ត្រូវផ្ញើសេចក្តីសំរេចនោះ ទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ដើម្បីចាត់ចែងធ្វើការចុះបញ្ជីក្បាលដីតាមនីតិវិធីដែលបានកំណត់ ។

## ជំពូកទី ១០
## បទប្បញ្ញត្តិវង្គបាល

**មាត្រា ២៥ ..**

ប្រសិនបើសមាជិករបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិកនោះ ត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនេះ ហើយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវតែងតាំងសមាជិកថ្មីជំនួសវិញ ។

ប្រសិនបើសមាជិករបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬ ថ្នាក់ជាតិ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិកនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនេះ ។ ប្រសិនបើចាំបាច់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចតែងតាំងសមាជិកថ្មីជំនួសវិញ ។

ក្នុងករណីដែលវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវតែងតាំងសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិឱ្យធ្វើជាប្រធានអាជ្ញាកណ្តាល ដើម្បីដោះស្រាយករណីវិវាទនេះ ។

**មាត្រា ២៦ ..**

ជនដែលត្រូវបានបញ្ជាក់ថាជាកម្មសិទ្ធិករ ឬភោគីស្របច្បាប់ នៃក្បាលដី ដែលមានវិវាទក្រោមនីតិវិធីដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវបង់ថ្លៃសេវានៃការចុះបញ្ជីក្បាលដី អនុលោមតាមមាត្រា ២៣០ នៃច្បាប់ភូមិបាល ។



Scanned with CamScanner

មាត្រា ២៧ ..

ភាគីវិវាទ ត្រូវបានជូនដំណឹងជាមុនក្នុងរយៈពេលមួយសមហេតុផល អំពីការប្រជុំដើម្បីសម្រុះសម្រួល ឬសំរេចលើវិវាទក្រោមអនុក្រឹត្យនេះ ។

ភាគីវិវាទ មានសិទ្ធិចូលខ្លួនដោយខ្លួនឯង និងអាចរកជំនួយមនុស្ស ឬអង្គការណាមួយ ដើម្បីជួយខ្លួន ក្នុងពេលសម្រុះសម្រួលវិវាទនៅគ្រប់ថ្នាក់ ។

ភាគីវិវាទ មានសិទ្ធិចូលខ្លួនដោយខ្លួនឯង និងអាចរកជំនួយមនុស្ស ឬអង្គការណាមួយ ដើម្បីធ្វើជាតំណាងរបស់ខ្លួន ក្នុងពេលប្រជុំធ្វើសេចក្ដីសំរេចរបស់គណៈកម្មការសុរិយោដី ។

ភាគីវិវាទ មានសិទ្ធិបង្ហាញភស្តុតាងផ្ទាល់មាត់ ឬឯកសារជាក់ស្ដែងដែលទាក់ទងនឹងវិវាទ ដែលត្រូវចាត់ទុកជាចំណែកមួយនៃឯកសារផ្លូវការនៃវិវាទ ។

ការប្រជុំរបស់គណៈកម្មការសុរិយោដីត្រូវធ្វើឡើងជាសាធារណៈ ។

គណៈកម្មការសុរិយោដី ត្រូវរក្សាឯកសារផ្លូវការនៃវិវាទនីមួយៗ ដែលរួមមានឯកសារទាំងអស់ និងភស្តុតាងជាក់ស្ដែងផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរ អំពីវិវាទ ។ ឯកសារផ្លូវការដែលទាក់ទងនឹងវិវាទ ត្រូវបានបើកឱ្យភាគីពាក់ព័ន្ធពិនិត្យ ។

សេចក្ដីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវអមដោយរបាយការណ៍ស្ដីពីដំណើររឿង និងដំណើរការដោះស្រាយវិវាទ ដែលផ្អែកលើភស្តុតាងទាំងឡាយ ដែលអាចទុកចិត្តបាន និងត្រឹមត្រូវ ដែលជាផ្នែកនៃឯកសារផ្លូវការ ។

ច្បាប់ចម្លងនៃសេចក្ដីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្ដល់ឱ្យភាគី វិវាទនីមួយៗ ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញប្រកាសណែនាំអនុវត្តអនុក្រឹត្យនេះ ។

មាត្រា ២៨ ..

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានសិទ្ធិប្រើប្រាស់ត្រារបស់ការិយាល័យរៀបចំដែនដី នគរូប-នីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត ក្រុង ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។



Scanned with CamScanner

## ជំពូកទី ១១
## ប្រភពធនធាន

**មាត្រា ២៩ ..**

គណៈកម្មការសុរិយោដី មានខ្ទង់ថវិកាដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ៣០ ..**

ប្រភពធនធាន និងថវិកា របស់គណៈកម្មការសុរិយោដី ត្រូវបានផ្តល់ដោយ :

- ថវិកាជាតិ
- ហិរញ្ញប្បទានបានមកពីប្រទេសក្រៅ ឬអង្គការផ្តល់ជំនួយអន្តរជាតិ ។

## ជំពូកទី ១២
## អវសានប្បញ្ញត្តិ

**មាត្រា ៣១ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣២ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អភិបាលខេត្ត ក្រុងទាំងអស់ និងមន្ត្រី ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យរបស់សម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ៣២
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ០៩៧ ដ.ន.ស. ប្រក/ និក.

# ប្រកាស

## ស្តីពី

## ការអភិវឌ្ឍដី

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៕

- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៤១ អនក្រ.បក ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០១៦ ស្តីពីការបង្កើតនាយកដ្ឋានកិច្ចការវិវាទដីធ្លីចំណុះអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០ , មាត្រា ៣៤ , មាត្រា ៣៨ , មាត្រា ៥០ , មាត្រា ៦៦ , មាត្រា ៧៤ និង មាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៥ ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណង ÷

- លើកកម្ពស់ការរៀបចំដីឱ្យបានត្រឹមត្រូវនិងចំទិសដៅ ដើម្បីជានាការអភិវឌ្ឍដែនដីនិងនគរូបនីយកម្ម ប្រកបដោយចីរភាព តុល្យភាព និងប្រសិទ្ធភាព
- គ្រប់គ្រងការអភិវឌ្ឍដី បំបែកក្បាលដី ឬការបង្រួមក្បាលដី ទៅជាដីឡូត៍សម្រាប់លក់ និង/ឬសាងសង់លំនៅឋាន អគារឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍
- លើកកម្ពស់ការអភិវឌ្ឍបៃតងដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងទប់ស្កាត់គ្រោះមហន្តរាយធម្មជាតិជាយថាហេតុ។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅ ÷

- កំណត់យន្តការ បែបបទ និងនីតិវិធីសម្រាប់ការអភិវឌ្ឍដី
- កំណត់លក្ខខណ្ឌបច្ចេកទេសសម្រាប់ការអភិវឌ្ឍដី ដើម្បីធានាបាននូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ ផ្ទៃបៃតង និងបរិក្ខារសាធារណៈសមស្របសម្រាប់មនុស្សទាំងអស់គ្នា រួមទាំងជនពិការ ជនងាយរងគ្រោះ ចាស់ជរា និងកុមារ
- កំណត់លក្ខខណ្ឌនៃការអភិវឌ្ឍបៃតងនិងការបង្ការគ្រោះមហន្តរាយ។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការអភិវឌ្ឍដីទាំងដីរបស់បុគ្គលឯកជន ទាំងដីរបស់រដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានបទប្បញ្ញត្តិកំណត់ដោយឡែក។

**ប្រការ ៤.-**

វាក្យសព្ទបច្ចេកទេសដែលប្រើក្នុងប្រកាសនេះមានដូចខាងក្រោម ÷

- **ការអភិវឌ្ឍដី** សំដៅដល់ការរៀបចំដីតាមរយៈការប្ដូរប្រភេទនៃការប្រើប្រាស់ដី ការប្ដូរមុខងារតំបន់ប្រើប្រាស់ដី ការធ្វើសមាហរណកម្មក្បាលដី ការបង្រួមក្បាលដី ការបំបែកក្បាលដី ការកែប្រែរចនាសម្ព័ន្ធនៃដីនិង/ឬការបង្កើនដង់ស៊ីតេនៃការប្រើប្រាស់ដីសម្រាប់គោលដៅនៃការសាងសង់លំនៅឋាន អគារពាណិជ្ជកម្ម សេវាកម្ម ឬឧស្សាហកម្ម ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី
- **អ្នកអភិវឌ្ឍ** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលទទួលបានលិខិតអនុញ្ញាតអភិវឌ្ឍដីពីអាជ្ញាធរមានសមត្ថកិច្ច
- **ការប្ដូរប្រភេទនៃការប្រើប្រាស់ដី** សំដៅដល់ការផ្លាស់ប្ដូរប្រភេទនៃការប្រើប្រាស់ដី ពីប្រភេទ មួយទៅប្រភេទផ្សេងទៀតស្របតាមបទប្បញ្ញត្តិជាធរមាន
- **ការបង្រួមក្បាលដី ÷**
    - សំដៅដល់ការបញ្ចូលក្បាលដីច្រើនដែលជាប់គ្នាឱ្យក្លាយទៅជាក្បាលដីតែមួយ ដោយដីទាំងនោះមានម្ចាស់កម្មសិទ្ធិតែមួយ ជាប្រភេទដីតែមួយ និងស្ថិតក្នុងភូមិសាស្ត្ររដ្ឋបាលតែមួយ

- សំដៅដល់ការបញ្ចូលក្បាលដីច្រើនដែលជាប់គ្នាឱ្យក្លាយទៅជាក្បាលដីតែមួយ ដើម្បីធ្វើផែនការអភិវឌ្ឍ សម្រាប់ធ្វើសមាហរណកម្ម និងធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សេវាសាធារណៈ សំដៅធានាចីរភាព សមធម៌ តុល្យភាព សុខភាព និងភាពងាយស្រួលនៃទីក្រុង។ ការបង្រួមក្បាលដីប្រភេទនេះ អាចហៅថា ការធ្វើសមាហរណកម្មក្បាលដី

– **ការបំបែកក្បាលដី** សំដៅដល់ការបំបែកក្បាលដីមួយឱ្យទៅជាក្បាលដីច្រើនសម្រាប់ការសាងសង់លំនៅឋាន អគារពាណិជ្ជកម្ម ឧស្សាហកម្ម។ល។ ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ ផ្ទៃបៃតង និងសេវាសាធារណៈ សមស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី

– **ការកែសម្រួលក្បាលដី** សំដៅដល់ការរៀបចំក្បាលដីឡើងវិញដើម្បីធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ដោយមានការចូលរួម ព្រមទាំងបង្កើនលទ្ធភាពនិងប្រសិទ្ធភាព នៃការប្រើប្រាស់ដីស្របតាមបទប្បញ្ញត្តិជាធរមាន

– **អាជ្ញាធរមានសមត្ថកិច្ច** សំដៅដល់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

– **អង្គភាពមានសមត្ថកិច្ច** សំដៅដល់អគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម អគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ

– **លំនៅឋានជាលក្ខណៈគ្រួសារ** សំដៅដល់សំណង់លំនៅឋានដែលមិនមានគោលដៅពាណិជ្ជកម្ម

– **ឯកសាររឹង** សំដៅដល់ឯកសារដែលមានទម្រង់ជាក្រដាស

– **ឯកសារទន់** សំដៅដល់ឯកសារដែលមានទម្រង់ជាទិន្នន័យ ដែលត្រូវបានបង្កើត ប្រើប្រាស់ និងរក្សាទុកក្នុងប្រព័ន្ធកុំព្យូទ័រ។

**ប្រការ ៥.-**

ការអភិវឌ្ឍដីត្រូវមានលិខិតអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីធានាបាននូវភាពត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្ម និងជាគ្រឹះនៃភាពស្របច្បាប់នៅក្នុងការអនុវត្តគម្រោងអភិវឌ្ឍដី។

ការអភិវឌ្ឍដីក្នុងគោលបំណងពាណិជ្ជកម្ម សេវាកម្ម និងឧស្សាហកម្ម ត្រូវមានលិខិតអនុញ្ញាតអភិវឌ្ឍដី ទោះបីគម្រោងនេះស្ថិតក្នុងតំបន់ជនបទដាច់ស្រយាល ឬតំបន់ឆ្ងាយពីផ្លូវជាតិ ផ្លូវដែក តំបន់រមណីយដ្ឋានទេសចរណ៍ ឬតំបន់បេតិកភណ្ឌជាតិក៏ដោយ។

**ប្រការ ៦.-**

ការស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី ត្រូវបង់កម្រៃសេវាសាធារណៈជូនរដ្ឋ ស្របតាមប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ការកំណត់កម្រៃសេវាសាធារណៈសម្រាប់ការស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី ត្រូវអនុវត្តតាមអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៥ ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។

**ប្រការ ៧.-**

ការអភិវឌ្ឍដីដែលតម្រូវឱ្យមានលិខិតអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ច មានជាអាទិ៍ ÷

១- ការប្តូរប្រភេទនៃការប្រើប្រាស់ដីដើម្បីគម្រោងសាងសង់។

២- ការអភិវឌ្ឍដីដើម្បីគម្រោងកែសម្រួលក្បាលដី។

៣- ការអភិវឌ្ឍដីដើម្បីរៀបចំគម្រោងបែងចែកជាដីឡូត៍។

៤- ការអភិវឌ្ឍដីដើម្បីកែប្រែរចនាសម្ព័ន្ធដី។

៥- ការអភិវឌ្ឍដីដើម្បីគម្រោងអភិវឌ្ឍទីក្រុង។

៦- ការអភិវឌ្ឍដីដើម្បីរៀបចំគម្រោងអភិវឌ្ឍតំបន់លំនៅឋានបុរី និងអគារស្នាក់នៅ។

៧- ការអភិវឌ្ឍដីដើម្បីរៀបចំគម្រោងអភិវឌ្ឍតំបន់ពាណិជ្ជកម្មនិង/ឬសេវាកម្ម និងតំបន់ចម្រុះ។

៨- ការអភិវឌ្ឍដីដើម្បីរៀបចំគម្រោងអភិវឌ្ឍតំបន់ឧស្សាហកម្ម សួនឧស្សាហកម្ម និងរោងចក្រ។

៩- ការអភិវឌ្ឍដីដើម្បីរៀបចំគម្រោងអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស។

១០- ការអភិវឌ្ឍដីដើម្បីរៀបចំគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង។

១១- ការអភិវឌ្ឍដីដើម្បីរៀបចំគម្រោងអភិវឌ្ឍតំបន់ទេសចរណ៍។

១២- ការអភិវឌ្ឍដីដើម្បីរៀបចំគម្រោងអភិវឌ្ឍនានា។

ការអភិវឌ្ឍដីក្នុងតំបន់កសិកម្មសម្រាប់សាងសង់លំនៅឋានជាលក្ខណៈគ្រួសារ សាងសង់រោងចក្រក្នុងទីតាំងដីសម្បទានសេដ្ឋកិច្ច និងសាងសង់រោងសិប្បកម្មឬរោងចក្រសម្រាប់គោលដៅកសិកម្ម មិនតម្រូវឱ្យមានលិខិតអនុញ្ញាតអភិវឌ្ឍដីទេ លើកលែងតែតំបន់ណាដែលមានបទដ្ឋានគតិយុត្តកំណត់ដោយឡែក។

**ប្រការ ៨.-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវយកចិត្តទុកដាក់រក្សាការពារដីដែលមានជីជាតិសម្រាប់ជំរុញនិងលើកកម្ពស់ផលិតភាពកសិកម្ម។

## ជំពូកទី ២
## លក្ខខណ្ឌបច្ចេកទេសនិងផែនការសម្រាប់ការអភិវឌ្ឍដី

**ប្រការ ៩.-**

ដីដែលជាកម្មវត្ថុនៃការស្នើសុំអភិវឌ្ឍ ត្រូវជាដីដែលបានចុះបញ្ជី។

ការអភិវឌ្ឍដីក្នុងប្រភេទដីកម្រិតការសាងសង់ត្រូវអនុវត្តលើដីហិល ឬដីគ្មានជីជាតិ ឬដីដែលមានផលិតភាពកសិកម្មទាប ឬផ្អែកលើសេចក្តីត្រូវការនិងការអភិវឌ្ឍដីជាក់ស្តែង។

ការអភិវឌ្ឍដីត្រូវគោរពតាមលក្ខខណ្ឌបច្ចេកទេសដូចមានចែងក្នុងប្រកាសនេះ និងបទប្បញ្ញត្តិជាធរមាន។

### ផ្នែកទី ១
### លក្ខខណ្ឌបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្មសម្រាប់គម្រោងអភិវឌ្ឍដី

**ប្រការ ១០.-**

ការអភិវឌ្ឍដីត្រូវគោរពតាមបទប្បញ្ញត្តិប្រើប្រាស់ដី ឬប្លង់គោលប្រើប្រាស់ដី ឬផែនការប្រើប្រាស់ដីរាជធានី ក្រុង និងទីប្រជុំជន ដែលទីតាំងគម្រោងស្ថិតនៅ និងបទប្បញ្ញត្តិជាធរមាន។

ផែនការសម្រាប់ការអភិវឌ្ឍដីត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម÷

១-ត្រូវរក្សាទុកផ្ទៃដី ២៥ % នៃផ្ទៃដីសរុបសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា÷

- បណ្តាញផ្លូវសាធារណៈ
- បរិក្ខារសាធារណៈ មានជាអាទិ៍ ប្រព័ន្ធទឹកស្អាត ប្រព័ន្ធលូបង្ហូរទឹកកខ្វក់ លូទឹកភ្លៀង បណ្តាញអគ្គិសនី បណ្តាញទូរគមនាគមន៍

- ប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងនិងរាវ មានជាអាទិ៍ ទីលានចាក់សំរាម រោងចក្រកែច្នៃសំរាម ប្រព័ន្ធលូ អាងប្រព្រឹត្តិកម្មទឹកកខ្វក់ និង
- ប្រព័ន្ធគ្រប់គ្រងអគ្គិភ័យនិងហានិភ័យផ្សេងៗ។

២-ត្រូវរក្សាទុកផ្ទៃដី ១០ % នៃផ្ទៃដីសរុប ឬ ១០ ម៉ែត្រក្រឡាសម្រាប់មនុស្សម្នាក់ សម្រាប់រៀបចំលំហសាធារណៈនិងផ្ទៃបៃតង ដូចជា សួនច្បារសាធារណៈ កន្លែងក្មេងលេង កន្លែងហាត់ប្រាណ ទីលានកីឡា និងទីលានកម្សាន្ត។

៣-ត្រូវរៀបចំឱ្យមានសំណង់សម្រាប់ផ្តល់សេវាជូនសាធារណជន ឱ្យបានសមស្របទៅតាមតម្រូវការនៃគម្រោងអភិវឌ្ឍនីមួយៗមានដូចជា សាលារៀន មណ្ឌលសុខភាព អគាររដ្ឋបាល ផ្សារ ដើម្បីធានាការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាពនិងមានសមធម៌។

៤-ត្រូវរៀបចំឱ្យមានការអភិវឌ្ឍបៃតង ផែនការបន្សាំនិងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដោយកំណត់ឱ្យបានច្បាស់អំពីទីតាំងដែលងាយបង្កឱ្យមានគ្រោះអគ្គិភ័យនិងហានិភ័យផ្សេងៗជាយថាហេតុដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសុខុមាលភាពសាធារណៈ ការពារបរិស្ថាន និងលើកកម្ពស់តម្លៃវប្បធម៌និងអត្តសញ្ញាណជាតិ។ ត្រូវដាំដើមឈើ ១ ដើមយ៉ាងតិចលើផ្ទៃដី ១០០ ម៉ែត្រក្រឡា និងត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច ៣០ % នៃផ្ទៃដីនៅសល់ពីផ្ទៃដីសម្រាប់ការសាងសង់ ដូចក្នុងចំណុចទី ១ និងទី ២ ខាងលើ។

លក្ខខណ្ឌខាងលើនេះមិនអនុវត្តចំពោះការអភិវឌ្ឍដីតាមរយៈការប្តូរប្រភេទនៃការប្រើប្រាស់ដីដើម្បីគម្រោងសាងសង់លំនៅឋានរបស់ប្រជាពលរដ្ឋដែលមានហេដ្ឋារចនាសម្ព័ន្ធសមស្រប ប៉ុន្តែត្រូវគោរពតាមគោលការណ៍នគរូបនីយកម្ម ឬប្លង់គោលប្រើប្រាស់ដី ឬផែនការប្រើប្រាស់ដីរាជធានី ក្រុង និងទីប្រជុំជន។

## ផ្នែកទី ២
## លក្ខខណ្ឌបច្ចេកទេសសម្រាប់រៀបចំផែនការអភិវឌ្ឍដី

**ប្រការ ១១.-**

សម្រាប់សមត្ថកិច្ចរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសមត្ថកិច្ចអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អ្នកស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដីត្រូវរៀបចំផែនការដូចខាងក្រោម÷

១-ត្រូវរៀបចំផែនការប្រើប្រាស់ដី រួមមាន ÷

- ការសិក្សាអំពីទិន្នន័យប្រជាសាស្ត្រ រូបវន្ត និងការប្រើប្រាស់ដីជាក់ស្តែងក្នុងគម្រោង

- គោលបំណង និងគោលដៅនៃការអភិវឌ្ឍដីនិងការប្រើប្រាស់ដី
- ទិសដៅនៃការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងគម្រោង និងការធ្វើសមាហរណកម្មទៅក្នុងតំបន់
- ទិសដៅនៃកិច្ចការពារបរិស្ថាននិងការអភិវឌ្ឍបៃតង ដើម្បីរួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងការពារគ្រោះមហន្តរាយ
- គំនូរប្លង់ប្រើប្រាស់ដីនិងប្លង់លម្អិតដោយកំណត់ច្បាស់អំពីការបែងចែកប្រភេទនៃការប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី ដីឡូត៍ បណ្តាញផ្លូវ បណ្តាញទឹកស្អាតបណ្តាញអគ្គិសនី អាងប្រព្រឹត្តិកម្មទឹកកខ្វក់ ក្បាលបំពង់ទឹកនិងប្រព័ន្ធទឹកពន្លត់អគ្គិភ័យ ប្រព័ន្ធលូ សួនច្បារ លំហសាធារណៈ ផ្ទៃបៃតង ការដាំដើមឈើ ទីតាំងអគារផ្តល់សេវាសាធារណៈ បទប្បញ្ញត្តិប្រើប្រាស់ដី និងសេចក្តីណែនាំអនុវត្ត និង
- តារាងសង្ខេបពិពណ៌នាអំពីគំនូរប្លង់ប្រើប្រាស់ដី។

២- ត្រូវរៀបចំផែនការសកម្មភាពអភិវឌ្ឍដោយមានកំណត់ច្បាស់លាស់អំពីសកម្មភាពអនុវត្ត និងពេលវេលាអនុវត្តទៅតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងសម្រាប់រយៈពេលវែង។

៣- ត្រូវរៀបចំផែនការថវិកាសម្រាប់អនុវត្តគម្រោងស្របតាមផែនការសកម្មភាពនិងពេលវេលា។

**ប្រការ ១២.-**

សម្រាប់សមត្ថកិច្ចអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ អ្នកស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដីត្រូវរៀបចំផែនការដូចខាងក្រោម ÷

១- ត្រូវរៀបចំផែនការប្រើប្រាស់ដី រួមមាន ÷

- គោលបំណង និងគោលដៅនៃការអភិវឌ្ឍដីនិងការប្រើប្រាស់ដី
- ទិសដៅនៃការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងគម្រោងនិងការធ្វើសមាហរណកម្មទៅក្នុងតំបន់
- គំនូរប្លង់ប្រើប្រាស់ដីដោយកំណត់អំពី ទំហំដីឡូត៍ បណ្តាញផ្លូវ បណ្តាញទឹកស្អាត បណ្តាញ អគ្គិសនី អាងប្រព្រឹត្តិកម្មទឹកកខ្វក់ ក្បាលបំពង់ទឹកនិងប្រព័ន្ធទឹកពន្លត់អគ្គិភ័យ ប្រព័ន្ធលូ សួនច្បារ លំហសាធារណៈ ផ្ទៃបៃតង និងការដាំដើមឈើ និង
- តារាងសង្ខេបពិពណ៌នាអំពីគំនូរប្លង់ប្រើប្រាស់ដី។

២- ត្រូវរៀបចំគម្រោងពេលវេលាអនុវត្តសម្រាប់រយៈពេលខ្លីរយៈពេលមធ្យម និងរយៈពេលវែង។

៣- ត្រូវរៀបចំផែនការថវិកាសម្រាប់អនុវត្តគម្រោងស្របតាមផែនការសកម្មភាពនិងពេលវេលា។

## ជំពូកទី ៣
## សមត្ថកិច្ច

**ប្រការ ១៣.-**

គម្រោងអភិវឌ្ឍដីសម្រាប់គោលដៅបំបែកក្បាលដីមួយទៅជាក្បាលដីច្រើនសម្រាប់លក់និង/ឬ អភិវឌ្ឍ សាងសង់លំនៅឋាន ពាណិជ្ជកម្ម សេវាកម្ម ឧស្សាហកម្ម ទេសចរណ៍ អភិវឌ្ឍចម្រុះនិង/ឬរាល់ការអភិវឌ្ឍដីដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ត្រូវស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដីជាមុនពីអាជ្ញាធរមានសមត្ថកិច្ចដូចខាងក្រោម ÷

១- គម្រោងអភិវឌ្ឍដីដែលមានទំហំផ្ទៃដីធំជាង ៣០ ០០០ ម៉ែត្រក្រឡា ត្រូវស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដីពីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

២- គម្រោងអភិវឌ្ឍដីដែលមានទំហំផ្ទៃដីតូចជាងឬស្មើ ៣០ ០០០ ម៉ែត្រក្រឡា ត្រូវស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដីពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដែលទីតាំងគម្រោងនោះស្ថិតនៅ។

៣- គម្រោងអភិវឌ្ឍដីដែលមានទំហំផ្ទៃដីតូចជាងឬស្មើ ៥ ០០០ ម៉ែត្រក្រឡា ត្រូវស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដីពីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដែលទីតាំងគម្រោងនោះស្ថិតនៅ ក្នុងករណីដែលក្រុង ស្រុក ខណ្ឌ នោះមានប្លង់គោលប្រើប្រាស់ដីដែលត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការរួច។

## ជំពូកទី ៤
## បែបបទនិងនីតិវិធីនៃការស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី

### ផ្នែកទី ១
### ពាក្យស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី

**ប្រការ ១៤.-**

ពាក្យស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី ត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

- ឯកសារបញ្ជាក់អត្តសញ្ញាណម្ចាស់សំណើ
- ឯកសារបញ្ជាក់ការកាន់កាប់ដីស្របច្បាប់ មានដូចជា វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ បណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ បណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើ

ប្រាស់ដីធ្លី វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ វិញ្ញាបនបត្រសម្គាល់សិទ្ធិផលុបភោគ ឬគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល។ ក្នុងករណីសាមីសំណើមិនមែនជាកម្មសិទ្ធិករត្រូវមានការព្រមព្រៀងពីម្ចាស់ដី

- ប្លង់តំបន់និង/ ឬប្លង់ទីតាំងគម្រោងអភិវឌ្ឍ
- ឯកសារគម្រោងផែនការប្រើប្រាស់ដីនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឯកសារគម្រោងផែនការសកម្មភាពនិងពេលវេលា និងឯកសារគម្រោងផែនការថវិកា ដូចមានចែងក្នុងប្រការ ១១ និងប្រការ ១២ នៃប្រកាសនេះ និង
- ឯកសារពាក់ព័ន្ធផ្សេងទៀត។

ពាក្យស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដីនិងឯកសារភ្ជាប់ខាងលើនេះ ត្រូវធ្វើជាឯកសាររឹងយ៉ាងតិច ៨ (ប្រាំបី) ច្បាប់ និងឯកសារទន់។

## ផ្នែកទី ២
## នីតិវិធីក្នុងការពិនិត្យសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី

### អនុផ្នែកទី ១
### នីតិវិធីក្នុងការពិនិត្យសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី ស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ប្រការ ១៥.-**

គម្រោងស្នើសុំអភិវឌ្ឍដីដែលស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូប-នីយកម្ម និងសំណង់ ម្ចាស់សំណើត្រូវដាក់ពាក្យស្នើសុំនៅច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ ១៦.-**

ការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី ដែលស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានរយៈពេលយ៉ាងយូរ ៦០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ ក្នុងករណីដែលសំណុំឯកសារនោះមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ។

**ប្រការ ១៧.-**

បន្ទាប់ពីពិនិត្យលើពាក្យស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបិទផ្សាយជាសាធារណៈនូវសេចក្តីជូនដំណឹងនិងគំនូរប្លង់ប្រើប្រាស់ដី នៅទីតាំងដីដែលគម្រោងនោះស្ថិតនៅ, នៅសាលាឃុំ សង្កាត់, សាលាក្រុង ស្រុក ខណ្ឌ និងនៅសាលារាជធានី ខេត្ត នៃទីតាំងគម្រោងនោះស្ថិតនៅ ក្នុងរយៈពេល ១៥ ថ្ងៃ និងផ្សព្វផ្សាយជាសាធារណៈតាមប្រព័ន្ធព័ត៌មានផ្សេងៗទៀត មុននឹងសម្រេចចេញលិខិតអនុញ្ញាតអភិវឌ្ឍដីជូនម្ចាស់សំណើ។ រយៈពេលបិទផ្សាយជាសាធារណៈនេះមិនរាប់បញ្ចូលក្នុងបរិបទពិនិត្យនិងសម្រេចខាងលើនេះទេ។

## អនុផ្នែកទី ២
## នីតិវិធីក្នុងការពិនិត្យសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី ស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

**ប្រការ ១៨.-**

គម្រោងស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈ - អភិបាលរាជធានី ខេត្ត ម្ចាស់សំណើត្រូវដាក់ពាក្យស្នើសុំនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលគម្រោងនោះស្ថិតនៅ។

**ប្រការ ១៩.-**

ការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត មានរយៈពេលយ៉ាងយូរ ៤៥ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ ក្នុងករណីដែលសំណុំឯកសារនោះមានលក្ខណៈគ្រប់គ្រាន់និងត្រឹមត្រូវ។

**ប្រការ ២០.-**

បន្ទាប់ពីបានទទួលសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវបញ្ជូនសំណុំឯកសារស្នើសុំនេះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ក្នុងរយៈពេល ២ ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

**ប្រការ ២១.-**

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ដោយមានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្មជាសេនាធិការ ត្រូវពិនិត្យផ្តល់មតិនិងបញ្ជូនសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដីយ៉ាងយូរ ២៣ ថ្ងៃ នៃថ្ងៃធ្វើការ ទៅអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យសម្រេច។

**ប្រការ ២២.-**

បន្ទាប់ពីពិនិត្យលើសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបិទផ្សាយជាសាធារណៈនូវសេចក្តីជូនដំណឹងនិងគំនូរប្លង់ប្រើប្រាស់ដី នៅទីតាំងដីដែលគម្រោងស្ថិតនៅ នៅសាលាឃុំ សង្កាត់ សាលាក្រុង ស្រុក ខណ្ឌ និងសាលារាជធានី ខេត្ត នៃទីតាំងគម្រោងនោះស្ថិតនៅ ក្នុងរយៈពេល ១៥ ថ្ងៃ និងធ្វើការផ្សព្វផ្សាយជាសាធារណៈតាមប្រព័ន្ធព័ត៌មានផ្សេងៗទៀត មុននឹងសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី។ រយៈពេលបិទផ្សាយជាសាធារណៈនេះមិនរាប់បញ្ចូលក្នុងបរិបថពិនិត្យនិងសម្រេចខាងលើនេះទេ។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវពិនិត្យសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី និងត្រូវបញ្ជូនសំណុំឯកសារនេះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ ១០ ថ្ងៃ នៃថ្ងៃធ្វើការ។

**ប្រការ ២៣.-**

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវរៀបចំលិខិតអនុញ្ញាតអភិវឌ្ឍដី ស្របតាមសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងត្រូវបញ្ជូនលិខិតអនុញ្ញាតអភិវឌ្ឍដី និងសុំណុំឯកសារពាក់ព័ន្ធផ្សេងទៀតទៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ ១០ ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីប្រគល់ជូនម្ចាស់សំណើ។

### អនុផ្នែកទី ៣
### នីតិវិធីក្នុងការពិនិត្យសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី ស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

**ប្រការ ២៤.-**

គម្រោងស្នើសុំអភិវឌ្ឍដីដែលស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ម្ចាស់សំណើត្រូវដាក់ពាក្យស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

ឬការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ដែលគម្រោងនោះស្ថិតនៅ ក្នុងករណីដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌ នោះមិនទាន់មានច្រកចេញចូលតែមួយ។

**ប្រការ ២៥.-**

ការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដីដែលស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ មានរយៈពេលយ៉ាងយូរ ៣០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ ក្នុងករណីដែលសំណុំឯកសារនោះមានលក្ខណៈគ្រប់គ្រាន់និងត្រឹមត្រូវ។

**ប្រការ ២៦.-**

ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យផ្តល់មតិនិងបញ្ជូនសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដីទៅអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យសម្រេច ក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

**ប្រការ ២៧.-**

បន្ទាប់ពីការពិនិត្យលើសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបិទផ្សាយជាសាធារណៈនូវសេចក្តីជូនដំណឹងនិងគំនូរប្លង់ប្រើប្រាស់ដី នៅទីតាំងដីដែលគម្រោងនោះស្ថិតនៅ នៅសាលាឃុំ សង្កាត់ និងសាលាក្រុង ស្រុក ខណ្ឌ នៃទីតាំងគម្រោងនោះស្ថិតនៅ ក្នុងរយៈពេល ១៥ ថ្ងៃ មុននឹងសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី។ រយៈពេលបិទផ្សាយជាសាធារណៈនេះមិនរាប់បញ្ចូលក្នុងបរិបថពិនិត្យនិងសម្រេចខាងលើនេះទេ។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី និងត្រូវបញ្ជូនសំណុំឯកសារស្នើសុំនេះ ទៅការិយាល័យច្រកចេញចូលតែមួយ នៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ឬការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ក្នុងករណីដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌនោះមិនទាន់មានការិយាល័យច្រកចេញចូលតែមួយ ក្នុងរយៈពេលយ៉ាងយូរ ១០ ថ្ងៃ នៃថ្ងៃធ្វើការ។

**ប្រការ ២៨.-**

ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំលិខិតអនុញ្ញាតអភិវឌ្ឍដី ក្នុងរយៈពេល

៥ ថ្ងៃ នៃថ្ងៃធ្វើការ ស្របតាមសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីប្រគល់ជូនម្ចាស់សំណើ។

**ប្រការ ២៩.-**

គំរូទម្រង់ពាក្យស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី គំរូទម្រង់សេចក្តីជូនដំណឹងស្តីពីការបិទផ្សាយជាសាធារណៈ គំរូទម្រង់គំនូរប្លង់ប្រើប្រាស់ដី និងគំរូទម្រង់លិខិតអនុញ្ញាតអភិវឌ្ឍដី ជាឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសនេះ។

**ប្រការ ៣០.-**

ក្នុងអំឡុងពេលពិនិត្យសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី អាជ្ញាធរមានសមត្ថកិច្ចអាចបញ្ជូនសំណុំឯកសារស្នើសុំទៅម្ចាស់សំណើ ដើម្បីកែតម្រូវឬបំពេញបន្ថែមនៅពេលពិនិត្យឃើញថាសំណុំឯកសារមានចំណុចខ្វះខាតផ្នែកបច្ចេកទេស និង/ឬខ្វះឯកសារពាក់ព័ន្ធផ្សេងៗទៀត។

រយៈពេលដែលម្ចាស់សំណើកែតម្រូវឬបំពេញបន្ថែមសុំណុំឯកសារស្នើសុំអភិវឌ្ឍដីខាងលើនេះ មិនត្រូវបានរាប់បញ្ចូលក្នុងបរិបថពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដីរបស់អាជ្ញាធរមានសមត្ថកិច្ចដូចមានចែងក្នុងប្រការ ១៦ ប្រការ ១៩ និងប្រការ ២៥ នៃប្រកាសនេះឡើយ។

## ជំពូកទី ៥
## សិទ្ធិនិងភារកិច្ចរបស់អ្នកអភិវឌ្ឍដី និងសុពលភាពនៃលិខិតអនុញ្ញាតអភិវឌ្ឍដី

### ផ្នែកទី ១
### សិទ្ធិនិងភារកិច្ចរបស់អ្នកអភិវឌ្ឍដី

**ប្រការ ៣១.-**

ក្រោយទទួលបានលិខិតអនុញ្ញាតអភិវឌ្ឍដី អ្នកអភិវឌ្ឍត្រូវស្នើសុំលិខិតអនុញ្ញាតសាងសង់ស្របតាមនីតិវិធីជាធរមាន ប្រសិនបើគម្រោងអភិវឌ្ឍនេះជាគម្រោងសាងសង់។ មានតែអ្នកអភិវឌ្ឍដែលមានលិខិតអនុញ្ញាតអភិវឌ្ឍដីទេដែលមានសិទ្ធិស្នើសុំលិខិតអនុញ្ញាតសាងសង់។

**ប្រការ ៣២.-**

អ្នកអភិវឌ្ឍត្រូវលើកផ្ទាំងសញ្ញាអំពីគម្រោងអភិវឌ្ឍរបស់ខ្លួន ដោយបង្ហាញគំនូរប្លង់ប្រើប្រាស់ដីនៃគម្រោងអភិវឌ្ឍ នៅទីតាំងដែលគម្រោងអភិវឌ្ឍនោះស្ថិតនៅ។

**ប្រការ ៣៣.-**

អ្នកអភិវឌ្ឍដីអាចផ្ទេរលិខិតអនុញ្ញាតអភិវឌ្ឍដីឱ្យទៅបុគ្គលផ្សេងបាន ដោយត្រូវមានការយល់ព្រម ជាលាយលក្ខណ៍អក្សរពីអាជ្ញាធរមានសមត្ថកិច្ច។

## ផ្នែកទី ២
## សុពលភាពនៃលិខិតអនុញ្ញាតអភិវឌ្ឍដី

**ប្រការ ៣៤.-**

លិខិតអនុញ្ញាតអភិវឌ្ឍដីមានសុពលភាពរយៈពេល ២ ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត។

**ប្រការ ៣៥.-**

អ្នកអភិវឌ្ឍអាចស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតអភិវឌ្ឍដីបានរយៈពេល ១ ឆ្នាំ ។ ការស្នើសុំបន្តសុពលភាពនេះអាចធ្វើបានតែ ២ ដងគត់។

## ជំពូកទី ៦
## ការអភិវឌ្ឍដីរដ្ឋ

**ប្រការ ៣៦.-**

ការស្នើសុំអភិវឌ្ឍដីរដ្ឋ ត្រូវស្នើសុំគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល។

ក្រោយទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល អ្នកអភិវឌ្ឍត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដីទៅអាជ្ញាធរមានសមត្ថកិច្ច ដោយត្រូវគោរពតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសនេះ។

## ជំពូកទី ៧
## បណ្តឹងតវ៉ា

**ប្រការ ៣៧.-**

បុគ្គលដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីគម្រោងអភិវឌ្ឍដី មានសិទ្ធិប្តឹងតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ចចេញលិខិតអនុញ្ញាតអភិវឌ្ឍដី។

**ប្រការ ៣៨.-**

អំឡុងពេលពិនិត្យសម្រេចលើបណ្តឹងតវ៉ា មិនត្រូវបានរាប់បញ្ចូលក្នុងបរិបថពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដីរបស់អាជ្ញាធរមានសមត្ថកិច្ច និងរយៈពេលបិទផ្សាយជាសាធារណៈដូចមានចែងក្នុងប្រការ ១៦ ប្រការ ១៧ ប្រការ ១៩ ប្រការ ២២ ប្រការ ២៥ និងប្រការ ២៧ នៃប្រកាសនេះឡើយ។

## ជំពូកទី ៨
## ទណ្ឌកម្ម

**ប្រការ ៣៩.-**

អំពើដូចខាងក្រោម ត្រូវបានចាត់ទុកថាជាអំពើបំពាននឹងបទប្បញ្ញត្តិនៃប្រកាសនេះ ÷

១- ធ្វើការអភិវឌ្ឍដីដោយគ្មានលិខិតអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

២- ប្រើប្រាស់លិខិតអនុញ្ញាតអភិវឌ្ឍដីហួសសុពលភាព។

៣- ធ្វើការអភិវឌ្ឍដីខុសពីលិខិតអនុញ្ញាត។

៤- ធ្វើការផ្ទេរលិខិតអនុញ្ញាតអភិវឌ្ឍដីដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអាជ្ញាធរមានសមត្ថកិច្ច។

៥- តាំងបង្ហាញផ្ទាំងសញ្ញាអំពីគម្រោងអភិវឌ្ឍដីរបស់ខ្លួនខុសពីគំនូរប្លង់ប្រើប្រាស់ដីដែលបានទទួលការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

៦- ពុំអនុវត្តតាមការណែនាំជាលាយលក្ខណ៍អក្សររបស់អាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ ៤០.-**

បុគ្គលដែលធ្វើការអភិវឌ្ឍដីដោយគ្មានលិខិតអនុញ្ញាតអភិវឌ្ឍដីពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវទទួលរងទណ្ឌកម្មណាមួយឬច្រើនដូចខាងក្រោម ÷

១- ព្រមានជាលាយលក្ខណ៍អក្សរ។

២- បង្ខំឱ្យរៀបចំដីឱ្យដូចសភាពដើមវិញ។

៣- ផ្សព្វផ្សាយជាសាធារណៈនូវអំពើបំពាននេះ។

៤- ពិន័យអន្តរការណ៍ស្របតាមច្បាប់និងបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ ៤១.-**

អ្នកអភិវឌ្ឍដែលប្រើប្រាស់លិខិតអនុញ្ញាតអភិវឌ្ឍដីហួសសុពលភាព ត្រូវទទួលរងទណ្ឌកម្មណាមួយឬច្រើនដូចខាងក្រោម ÷

១- ព្រមានជាលាយលក្ខណ៍អក្សរ។

២- បង្ខំឱ្យរៀបចំដីឱ្យដូចសភាពដើមវិញ។

៣- ផ្សព្វផ្សាយជាសាធារណៈនូវអំពើបំពាន។

៤- ពិន័យអន្តរការណ៍ស្របតាមច្បាប់និងបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ ៤២.-**

អ្នកអភិវឌ្ឍដែលធ្វើការអភិវឌ្ឍដីខុសពីលិខិតអនុញ្ញាត ត្រូវទទួលរងទណ្ឌកម្មណាមួយឬច្រើនដូចខាងក្រោម ÷

១- ព្រមានជាលាយលក្ខណ៍អក្សរ។

២- ព្យួរលិខិតអនុញ្ញាតអភិវឌ្ឍដី។

៣- ដកហូតលិខិតអនុញ្ញាតអភិវឌ្ឍដី។

៤- បង្ខំឱ្យរៀបចំដីឱ្យដូចសភាពដើមវិញ។

៥- ផ្សព្វផ្សាយជាសាធារណៈនូវអំពើបំពាននេះ។

៦- ពិន័យអន្តរការណ៍ស្របតាមច្បាប់និងបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ ៤៣.-**

អ្នកអភិវឌ្ឍដែលធ្វើការផ្ទេរលិខិតអនុញ្ញាតអភិវឌ្ឍដីដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវទទួលរងទណ្ឌកម្មណាមួយឬច្រើនដូចខាងក្រោម ÷

១- ព្រមានជាលាយលក្ខណ៍អក្សរ។

២- ព្យួរលិខិតអនុញ្ញាតអភិវឌ្ឍដី។

៣- ដកហូតលិខិតអនុញ្ញាតអភិវឌ្ឍដី។

៤- ផ្សព្វផ្សាយជាសាធារណៈនូវអំពើបំពាននេះ។

៥- ពិន័យអន្តរការណ៍ស្របតាមច្បាប់និងបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ ៤៤.-**

អ្នកអភិវឌ្ឍដែលតាំងបង្ហាញផ្ទាំងសញ្ញាអំពីគម្រោងអភិវឌ្ឍដីរបស់ខ្លួន ខុសពីគំនូរប្លង់ប្រើប្រាស់ដីដែលបានទទួលការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ដែលអាចនាំឱ្យមានការយល់ច្រឡំ ត្រូវទទួលរងទណ្ឌកម្មណាមួយឬច្រើនដូចខាងក្រោម ÷

១- ព្រមានជាលាយលក្ខណ៍អក្សរ។

២- ព្យួរលិខិតអនុញ្ញាតអភិវឌ្ឍដី។

៣- ដកហូតលិខិតអនុញ្ញាតអភិវឌ្ឍដី។

៤- ផ្សព្វផ្សាយជាសាធារណៈនូវអំពើបំពាននេះ។

**ប្រការ ៤៥.-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចងក្រងសំណុំរឿងបញ្ជូនទៅតុលាការនិងអាចសម្រេចសុំរឹបអូសសម្ភារៈ បរិក្ខារ និងឧបករណ៍ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងអំពើល្មើស ដោយអនុលោមតាមនីតិវិធីជាធរមាន ក្នុងករណីបុគ្គលដែលទទួលទណ្ឌកម្មតាមបទប្បញ្ញត្តិនៃប្រកាសនេះ មិនព្រមអនុវត្តតាមសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**ប្រការ ៤៦.-**

រាល់សំណើសុំចុះបញ្ជីបំបែកក្បាលដី បង្រួមក្បាលដី និងប្ដូរប្រភេទនៃការប្រើប្រាស់ដីដែលបានទទួលការឯកភាពពីការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ រួចហើយ ត្រូវបន្តនីតិវិធីបញ្ចប់។

**ប្រការ ៤៧.-**

រាល់ការអភិវឌ្ឍដីដែលបានអនុវត្តចប់ជាស្ថាពរនិងការអភិវឌ្ឍដីដែលដំណើរការស្នើសុំលិខិតអនុញ្ញាតសាងសង់បានទទួលការឯកភាពពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត រួចហើយ ឬដំណើរការស្នើសុំកែប្រែរចនាសម្ព័ន្ធដីបានទទួលការឯកភាពពីអភិបាលក្រុង ស្រុក ខណ្ឌ រួចហើយ ត្រូវបន្តនីតិវិធីបញ្ចប់។

## ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**ប្រការ ៤៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៤៩.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានអង្គភាពចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១២ រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០១៨

**នេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  **"ដើម្បីជូនជ្រាប"**
- ដូចប្រការ ៤៩ **"ដើម្បីអនុវត្ត"**
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធជារូបភាព







**ឧបសម្ព័ន្ធទី២ ៖ ទីតាំងសំខាន់ៗនៅខណ្ឌច្បារអំពៅ និងទីក្រុងរណបកោះនរា**




ទីតាំង៖ ផ្សាររាត្រីនៅតំបន់ទីក្រុងរណបកោះនរា




ទីតាំង៖ Park Way



ទីតាំង៖ Coffee Brown



ទីតាំង៖ សួនច្បារកោះនរា

## ឧបសម្ព័ន្ធទី៣ ៖ សកម្មភាពរបស់រដ្ឋបាល ដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍទីក្រុងរណបកោះនរា





សកម្មភាព៖ ការកសាងស្ពានពីទីក្រុងរណបកោះពេជ្រ ទៅទីក្រុងរណបកោះនរា





សកម្មភាព៖ ការកសាង Park Ways និងការកសាងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ